ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក
# ការពិត



- កន្លែងកិត្តិយសក្នុងប្រវត្តិសាស្ត្រកម្ពុជានិងមនុស្សជាតិ
- តុលាការខ្មែរក្រហម : ជាការព្រមានដល់អ្នកដឹកនាំក្រោយ

[illegible]

លេខ ៥១ ខែមីនា ឆ្នាំ២០០៤

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៦៣ ខែមីនា ឆ្នាំ២០០៥


## មាតិកា


◆ សំបុត្រ៖ កន្លែងកិត្តិយសក្នុងប្រវត្តិសាស្ត្រកម្ពុជានិងមនុស្សជាតិ... ១

**ផ្នែកឯកសារ**

◆ ហាក់ ស៊ាងឡាយនី........................................ ២

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១........... ៦

◆ វៀតណាមនិងកម្ពុជាប្រជាធិបតេយ្យ៖ សត្រូវដ៏ជូរចត់............ ១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ មិនចង់ចងពៀរ ប៉ុន្តែនៅតែចងចាំ........................... ១៤

◆ ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម្ល៉េះ? ........... ១៦

◆ រសាយចិត្តទៅតាមពេលវេលា................................ ២៥

◆ សម្លឹងទៅអតីតកាល........................................ ២៨

**ផ្នែកច្បាប់**

◆ ការបង្កើតការទទួលខុសត្រូវ................................. ៣០

◆ ទម្រង់ទូទៅនៃអង្គជំនុំជម្រះវិសាមញ្ញ.......................... ៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆ ការអប់រំអំពីសន្តិភាព........................................ ៤២

◆ កិច្ចព្រមព្រៀងបង្កើតបណ្ណសារដ្ឋានប្រវត្តិសាស្ត្រ.................. ៤៨

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ តុលាការខ្មែរក្រហម៖ គឺជាការព្រមានអ្នកជំនាន់ក្រោយ.......... ៥១

◆ ជីវិតក្នុងភាពនឹងថ្កល់......................................... ៥៥




រូបក្រុង៖ ញ៉ែម សូផាន ថតជាមួយមិត្តភក្តិឈ្មោះ គា ក្នុងឆ្នាំ១៩៧៥




## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ៖** យិន នាន, ញាណ សុជាតិ, គីម សុផាន់នី, គីម កែវកន្និដ្ឋា, ដាវីដ ចឺយ, ម៉ូង សាន់យ៉ឺស, អូប្រី អាដេម៉ា **អ្នកនិពន្ធនិងស្រាវជ្រាវ៖** លី សុផល, សូហ្វារីណា **អ្នកបកប្រែ៖** ជី ទេវិទ្ធិ **និពន្ធនាយករង៖** សាន់ កល្យាណ **និពន្ធនាយកទូទៅ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ៖** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយ៖** មាស ប៊ុនថាន



Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រៈ*

# កន្លែងកិត្តិយសក្នុងប្រវត្តិសាស្ត្រកម្ពុជានិងមនុស្សជាតិ

អង្គការសហប្រជាជាតិនឹងបើកកិច្ចប្រជុំមួយ នៅទីស្នាក់ការកណ្តាលរបស់ខ្លួននៅទីក្រុងញូវយ៉កនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០០៥ ដើម្បីចាប់ផ្តើមយុទ្ធនាការរៃអង្គាសថវិកាសម្រាប់ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ រហូតមកដល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិប្រមូលថវិកាបានរួចហើយ យ៉ាងហោចណាស់គ្រប់គ្រាន់សម្រាប់រយៈពេលមួយឆ្នាំដំបូងនៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះ (៣៩លានដុល្លារនៃចំណាយសរុបដែលបានប៉ាន់ស្មាន៥៦លានដុល្លារសម្រាប់រយៈពេល៣ឆ្នាំ) តាមរយៈការរួមវិភាគទានពីប្រទេសជប៉ុន អូស្ត្រាលី ចក្រភពអង់គ្លេស ប្រទេសបារាំង និងរាជរដ្ឋាភិបាលកម្ពុជា ។



យើងស្ទើរតែបានធ្វើដំណើរមកដល់ផ្លូវមួយ ឆ្ពោះទៅរកការស្វែងរកយុត្តិធម៌ទៅហើយ កាលពីរយៈពេលប៉ុន្មានខែកន្លងទៅនេះ ប៉ុន្តែអង្គការសហប្រជាជាតិបានបញ្ជាក់ថាខ្លួននឹងមិនចាប់ផ្តើមដំណើរការអង្គជំនុំជម្រះវិសាមញ្ញនេះទេ ប្រសិនបើគ្មានថវិកាគ្រប់គ្រាន់សម្រាប់ដំណើរការទាំងមូលដែលមានរយៈពេល៣ឆ្នាំ ហើយនេះមានន័យថា ចាំបាច់ត្រូវតែរកឲ្យបានថវិកា១៧លានដុល្លារទៀតដើម្បីបង្គ្រប់ថវិកាទាំងស្រុង ។

ខ្ញុំបាទសុំឲ្យសហគមន៍ម្ចាស់ជំនួយជួយឧបត្ថម្ភដល់ប្រទេសកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីបង្កើតឲ្យចេញជារូបរាងពិតប្រាកដនូវអង្គជំនុំជម្រះវិសាមញ្ញនេះ ។ ដោយមើលឃើញប្រព័ន្ធយុត្តិធម៌ដ៏ទន់ខ្សោយនៅកម្ពុជា ប្រទេសជាច្រើនបានសម្តែងការព្រួយបារម្ភក្រែងថវិការបស់ខ្លួននឹងមិនត្រូវបានចំណាយឲ្យមានប្រសិទ្ធភាព ។ ឆ្លើយតបទៅនឹងការមន្ទិលសង្ស័យទាំងនេះ ម្ចាស់ជំនួយអាចពិចារណាក្នុងការឧបត្ថម្ភថវិកាសម្រាប់ឆ្នាំទី២ (ឬឆ្នាំទី៣) នៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ប្រទេសផ្តល់ជំនួយមិនចាំបាច់ត្រូវតែឧបត្ថម្ភនៅពេលនេះទេ ពោលគឺអាចឧបត្ថម្ភជំនួយថវិកានៅពេលដែលខ្លួនជឿជាក់ថាដំណើរការនៃឆ្នាំទី១របស់អង្គជំនុំជម្រះវិសាមញ្ញនេះមានយុត្តិធម៌ មានតម្លាភាព និងផ្តល់ឱកាសឲ្យជនរងគ្រោះបានបញ្ចេញសំឡេងរបស់ខ្លួន ។

បើទោះបីជាការជំទាស់ប្រាកដជាមានចំពោះការរៀបចំដំណើរការមួយឆ្នាំដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញនេះយ៉ាងណាក៏ដោយ ក៏នៅមានមធ្យោបាយជាច្រើនទៀតដើម្បីសម្រេចឲ្យបាននូវការព្រមព្រៀងគ្នាដ៏ទូលំទូលាយមួយ ។ នេះគឺប្រហែលជាតម្រូវឲ្យមានការចូលរួមវាយតម្លៃដោយអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា សេចក្តីរាយការណ៍នៅក្នុងសារព័ត៌មាន ការវាយតម្លៃរបស់អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ហើយដែលសំខាន់បំផុតនោះគឺជាទស្សនៈរបស់ប្រជាជនកម្ពុជាជុំវិញបញ្ហាថាតើអង្គជំនុំជម្រះវិសាមញ្ញនេះបានបម្រើផលប្រយោជន៍ខ្លួនបានត្រឹមត្រូវដែរឬទេ ។

ក្តីសង្ឃឹមរបស់ខ្ញុំគឺ សហគមន៍អន្តរជាតិនឹងចាប់ផ្តើមចូលរួមកាន់តែទូលំទូលាយ នៅក្នុងការដោះស្រាយអំពើរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសមួយនៅទ្វីបអាស៊ីនេះឲ្យដូចកាលដែលខ្លួនបានចូលរួមដោះស្រាយបញ្ហាប្រហាក់ប្រហែលគ្នានេះនៅក្នុងទ្វីបអឺរ៉ុបនិងអាហ្វ្រិកដូច្នេះដែរ ។ តាមរយៈការជួយប្រជាពលរដ្ឋកម្ពុជាឲ្យបានទទួលយុត្តិធម៌ចំពោះអំពើរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ នឹងធានាឲ្យប្រទេសដែលបានជួយ ជ្រោមជ្រែងមានកន្លែងកិត្តិយសមួយ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជានិងមនុស្សជាតិ ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# ហាក់ ស៊ានឡាយនី

ហាក់ ស៊ានឡាយនី ជានិស្សិតម្នាក់ដែលបានបញ្ចប់ការសិក្សាផ្នែកសំណង់អគ្គិសនីនៅប្រទេសសូវៀត និងបានស្ម័គ្រចិត្តត្រឡប់មកប្រទេសកម្ពុជានៅឆ្នាំ១៩៧៤ ដើម្បីចូលរួមការតស៊ូជាមួយខ្មែរក្រហម ។ នៅឆ្នាំ១៩៧៦ ឡាយនី ត្រូវអង្គការចាប់ខ្លួនបញ្ជូនទៅមន្ទីរឃុំឃាំងស-២១ សួរចម្លើយ និងសម្លាប់ចោល ។

ឡាយនី មានឈ្មោះបដិវត្តន៍ ឡូន កើតនៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤០ នៅឃុំទន្លេបិទ ខេត្តកំពង់ចាម ។ ឪពុកម្តាយរបស់ ឡាយនី គឺជាកសិករនៅភូមិតានង់ ប៉ុន្តែបានផ្លាស់មករស់នៅទន្លេបិទក្រោយឆ្នាំ១៩៤០ដើម្បីប្រកបរបរលក់ដូរទំនិញគ្រប់មុខ ហើយបានក្លាយជាអ្នកមានមធ្យមម្នាក់នៅក្នុងខេត្តកំពង់ចាម ។

ឡាយនី បានចូលរៀននៅសាលាបឋមសិក្សាទន្លេបិទ ។ ដោយសារ ឡាយនី ជាសិស្សពូកែ គាត់បានទទួលអាហារូបករណ៍មករៀនបន្តនៅទីរួមខេត្តកំពង់ចាម ។ ឆ្នាំ១៩៥៣ ឡាយនី បានមកបន្តការសិក្សានៅសាលាឯកជនកម្ពុជបុត្រនៅទីក្រុងភ្នំពេញ បន្ទាប់មកប្រឡងចូលវិទ្យាល័យព្រះស៊ីសុវត្ថិ ។

ឆ្នាំ១៩៥៧ ថាច់ គិមសឺន បាននាំឲ្យ ឡាយនី ស្គាល់ អៀង សារី ហើយ អៀង សារី បានយក ឡាយនី ទៅផ្ញើជាមួយ ខៀវ កុមារ អ្នកទទួលខុសត្រូវនៅវិទ្យាល័យស៊ីសុវត្ថិ ។ ខៀវ កុមារ ចាត់តាំងឲ្យ ឡាយ នីធ្វើជាប្រធានក្រុមសិស្សនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។

ចុងឆ្នាំ១៩៥៩ ប្រទេសសូវៀតបានផ្តល់អាហារូបករណ៍មួយចំនួនដល់និស្សិតកម្ពុជា ។ ឡាយនី ក៏ស្ថិតនៅក្នុងចំណោមនិស្សិតដែលត្រូវជ្រើសរើសឲ្យទៅសិក្សានៅប្រទេសសូវៀតដែរ ក្រោមការជួយជ្រោមជ្រែងរបស់ ខៀវ កុមារ ។ ឡាយនី បានចាកចេញពីប្រទេសកម្ពុជាទៅសូវៀតនៅឆ្នាំ១៩៦០ ។ នៅក្នុងឆ្នាំទី១ ឡាយនី រៀនភាសាសូវៀត ឆ្នាំទី២ ឡាយនី បានជ្រើសរើសយកឯកទេសសំណង់អគ្គិសនី ប៉ុន្តែគាត់បានទទួលចំណេះដឹងអំពីមុខវិជ្ជានេះតិចតួចបំផុត ព្រោះគាត់រវល់តែប្រឡូកក្នុងកិច្ចការនយោបាយ ។

នៅក្នុងអំឡុងឆ្នាំ១៩៦១ ឡាយនី បានខិតខំស្វែងយល់អំពីការតស៊ូបដិវត្តន៍របស់ប្រទេសសូវៀតក្រោមការបង្ហាត់បង្រៀនរបស់សាស្ត្រាចារ្យល្បីៗនៅរដ្ឋអ៊ុយក្រែន ។ ឆ្នាំ១៩៦២ ឡាយនី បានចាកចេញពីអ៊ុយក្រែនទៅបន្តការសិក្សានៅទីក្រុងមូស្គូ ។ ឆ្នាំ១៩៦៣ ឡាយនី បានចូលរួមបង្កើតសហភាពខេមរនិស្សិតមួយដែលមានសមាជិកចំនួន៦០នាក់ ក្រោមការដឹកនាំរបស់ ប៉ែន ថៅង អាន (និស្សិតពេទ្យនៅសាលាលុយមុំបា) ។

នៅចុងឆ្នាំ១៩៦៣ ក្រុមសម្ងាត់មួយទៀតត្រូវបានបង្កើតឡើងដែលក្នុងនោះមាន ប៉ែន ថៅងអាន, អ៊ាង សីហា, ឡោ ជិនហុង, តាន់ ឆៃហេង, គ្រិន លាន, ថាច់ សួង, ហៃ គិមស៊ាង, រឿង ម៉ាច, ហេង ពេជ្រ, ជា ខន, ប៊ូច មាយបូរី, ហាក់ ជាដេទ្ធ, កាំ ណងហាក់, អ៊ឹង វ៉ាក់ឈើវ, ម៉ែន មុនីង៉ាម និង ហាក់ ស៊ាង ឡាយនី ។ គោលបំណងនៃការបង្កើតក្រុមសម្ងាត់នេះគឺដើម្បីកសាងស្នូលបដិវត្តន៍និងប្រមូលកម្លាំងឲ្យបានកាន់តែច្រើន ។

ឡាយនី បានសុំឲ្យសូវៀតម្នាក់ឈ្មោះ ស៊ីហ្គេយ (ធ្វើការនៅក្នុងក្រសួងសិក្សាធិការរបស់សូវៀត) ជួយរកសាស្ត្រាចារ្យជំនាញខាងទស្សនវិជ្ជាមកបង្រៀនខ្លួនដោយឡែក ដើម្បីសម្រួលដល់ខ្លួនក្នុងការដឹកនាំក្រុមសម្ងាត់នេះ ។ សាស្ត្រាចារ្យរូបនោះបានបង្រៀនផងនិងបំពាក់បំប៉ន ឡាយនី ផង ជាមួយនឹងការលើកទឹកចិត្តឧបត្ថម្ភជាសម្ភារឲ្យគាត់ខិតខំកៀងគរនិស្សិតខ្មែរឲ្យបានច្រើនមកគាំទ្របក្សកុម្មុយនិស្តសូវៀត និងបញ្ចុះបញ្ចូល ឡាយនី ឲ្យធ្វើជាភ្នាក់ងារបង្កប់របស់ខ្លួន ។

ឆ្នាំ១៩៦៣ទំនាស់នៅក្នុងមជ្ឈដ្ឋានសហភាពខេមរនិស្សិត

នៅមូស្គូបានផ្ទុះឡើងបន្ទាប់ពី ឡាយនី ចេញផ្សាយអត្ថបទមួយទិតៀនរបបសក្តិភូមិនៅកម្ពុជាតាមព្រឹត្តិបត្ររបស់សហភាពខេមរនិស្សិត។ រស់ សាមិត និង ម៉ៅ ចយ បានធ្វើដំណើរទៅទីក្រុងមូស្គូដើម្បីដោះស្រាយទំនាស់នេះ ។

ឆ្នាំ១៩៦៥ ឡាយនី បានធ្វើដំណើរទៅទីក្រុងប៉ារីសជួបជួន មុម្ម ដើម្បីសួរនាំអំពីសភាពការណ៍នៅកម្ពុជានិងសុំមតិណែនាំខ្លះៗពីគាត់ ពិសេសជាងនេះទៅទៀតគឺដើម្បីរាយការណ៍អំពីបញ្ហានិស្សិតសហភាពសូវៀតផង ។ នៅទីក្រុងមូស្គូ ឡាយនី មិនបានយកចិត្តទុកអំពីការសិក្សារបស់ខ្លួនឡើយ គាត់គិតតែពីរកប្រកចេញទៅរកបដិវត្តន៍ជាមួយ ជួន មុម្ម, គង់ ស៊ីគឿន និងនិស្សិតមួយចំនួនទៀតដែលមានទស្សនៈដូចគាត់ ។ រហូតដល់ឆ្នាំបញ្ចប់ ឡាយនី បានសម្រេចចិត្តបោះបង់ចោលការសិក្សា ប៉ុន្តែសាស្ត្រាចារ្យសូវៀតបានឲ្យយោបល់ថា គួរតែសិក្សាបន្តនិងចាំយកសញ្ញាបត្រសិន ។

ក្រោយមក ឡាយនី បានរៀបចំភារកិច្ចមួយចំនួនសម្រាប់អ្នកដែលត្រូវត្រឡប់មកប្រទេសកម្ពុជាវិញនិងអ្នកនៅក្រៅប្រទេស ។ ភារកិច្ចសម្រាប់អ្នកចូលប្រទេសគឺ ទី១) សាមគ្គីជាមួយមិត្តមកពីទីក្រុងមូស្គូ ទី២) ស៊ើបរកបក្សបដិវត្តន៍នៅក្នុងប្រទេស បើមានត្រូវពុះពារចូលឲ្យបាន និងទី៣) បើគ្មានបក្សទេត្រូវទាក់ទងជាមួយអ្នកតស៊ូនៅក្នុងប្រទេសពីមុនមកមាន ជា គិមអាន, ហ៊ូ យន់, ស៊ាន អាន, ខៀវ កុមារ ដើម្បីបង្កបង្កើតលក្ខណៈសម្បត្តិបក្ស ។ បំណែកក្រុមនៅក្រៅប្រទេសមានភារកិច្ចពង្រីកការទាក់ទងជាមួយនិស្សិតខ្មែរនៅបរទេសទាំងអស់ ដោយប្រមូលសហគមន៍និស្សិតខ្មែរនៅគ្រប់ប្រទេសឲ្យចូលជាសហព័ន្ធនិស្សិតខ្មែរនៅបរទេស ។ បង្កើតឲ្យមានក្រុមសម្ងាត់រៀនលទ្ធិម៉ាក្សឡេនីនគ្រប់ទីកន្លែងដែលមាននិស្សិតខ្មែរចម្រើនរស់នៅនិងពង្រីងការទាក់ទងឲ្យបានល្អ




សារិន ឆាក និងគណៈប្រតិភូសូវៀត

ជាមួយបក្សកុម្មុយនិស្តនៃប្រទេសនីមួយៗដែលមាននិស្សិតខ្មែររស់នៅដើម្បីឲ្យជួយខបក្តម្ភគាំទ្រ។ ក្នុងពេលវិស្សមកាលជារៀងរាល់ឆ្នាំ ឡាយនី បានចាត់តាំងសមាជិកនិស្សិតខ្មែរនៅប្រទេសសូវៀតឲ្យទៅទាក់ទងនិស្សិតខ្មែរដែលសិក្សានៅបណ្តាប្រទេសផ្សេងៗទៀតនៅអឺរ៉ុបក្នុងគោលបំណងសម្រេចទិសដៅខាងលើនេះ ។

ស៊ីហ្គេយ បានណែនាំ ឡាយនី ឲ្យទាក់ទងជាមួយ វ៉ាឡូឌីយ៉ា ។ ឆ្នាំ១៩៦៧ ឡាយនី បានចូលរួមប្រជុំជាមួយយុវជនសាកលនៅទីក្រុងសូហ្វីយ៉ា ប្រទេសប៊ុលហ្គារី ។ មុនចេញដំណើរ វ៉ាឡូឌីយ៉ា បានប្រគល់ប្រាក់១០០រូប្លិ៍ឲ្យ ឡាយនី ។ នៅឆ្នាំដដែល វ៉ាឡូឌីយ៉ា បាននាំ ឡាយនី ទៅជួបមេធំម្នាក់ឈ្មោះ ប៉េត្រូវ ជាអ្នកទទួលខុសត្រូវខាងក្រុមស៊ើបការណ៍សូវៀតនិងធ្លាប់មានបទពិសោធន៍ច្រើននៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ ។ គោលបំណងរបស់ ប៉េត្រូវ គឺសុំឲ្យ ឡាយនី បន្លំខ្លួនស៊ើបការណ៍ពីចិន ។ តាមសេចក្តីស្នើសុំនេះ ឡាយនី បានដាក់សំណើទៅស្ថានទូតចិនថាគាត់ចង់ទៅលេងសាច់ញាតិនៅសៀងហៃ ។ ស្ថានទូតចិនបានស្វាគមន៍ ឡាយនី ដោយរីករាយ ក៏ប៉ុន្តែគាត់ត្រូវរង់ចាំមួយរយៈសិន ព្រោះថានៅក្នុងប្រទេសចិនកំពុងតែជាប់រវល់ធ្វើបដិវត្តន៍វប្បធម៌ ។ ឡាយនី រង់ចាំរហូតដល់ថ្ងៃរដ្ឋប្រហារ ១៨ មីនា ១៩៧០ ក៏នៅតែគ្មានចម្លើយពីស្ថានទូតចិនទៀត ។

ឆ្នាំ១៩៦៨-៦៩ ឡាយនី បានសរសេរសេចក្តីអំពាវនាវជាបន្តបន្ទាប់ឲ្យប្រជាជនកម្ពុជាសាមគ្គីគ្នាជាធ្លុងមួយ តស៊ូរំដោះជាតិរំដោះប្រជាជនចេញពីរណ្តៈកាន់អំណាច ។

នៅឆ្នាំ១៩៧០ និស្សិតខ្មែរមួយចំនួនបានបញ្ចប់ការសិក្សាហើយត្រូវត្រឡប់មកចូលប្រទេសវិញ មាន ប៉ែន ថៅងអាន, អ៊ាង សីហា, ឡោ ជិនហុង, ម៉ែន មុនីង៉ាម និង អ៊ឹង វ៉ាត់ឈឺវ ។

នៅពាក់កណ្តាលខែមេសា ឆ្នាំ១៩៧០ ដួន មុម្ម និង ឡាយនី បានធ្វើដំណើរទៅទីក្រុងប៉េកាំងដើម្បីចូលគាល់សម្តេច សីហនុ ។ ក្រោយពេលឮដំណឹងថា ឡាយនី នឹងចាកចេញពីមូស្គូ វ៉ាឡូឌីយ៉ា បានប្រគល់ម៉ាស៊ីនថតមួយគ្រឿងនិងសៀវភៅកំណត់ហេតុមួយក្បាលឲ្យ ឡាយនី ដោយសុំឲ្យ ឡាយនី ថតរូបនិងសរសេររបាយការណ៍មកឲ្យខ្លួនអំពីសភាពការណ៍នានានៅក្នុងប្រទេសចិននិងបញ្ហាផ្សេងៗរបស់កម្ពុជាដូចជា ស៊ើបរកចំនួនកម្លាំងដែលគាំទ្រសម្តេច សីហនុ និងជំនួយរបស់ចិនដែលផ្តល់ឲ្យកម្ពុជា ។ ពេលទៅដល់ប្រទេសចិនដំបូង ឡាយនី បានសរសេររបាយការណ៍ផ្ញើទៅឲ្យប៉េត្រូវ ប៉ុន្តែបន្ទាប់ពីបានចូលរួមស្តាប់បទខទេ្វសនាមរបស់ អៀង សារី ឡាយនី ក៏ផ្លាស់ប្តូរគោលជំហររបស់ខ្លួនហើយលែងផ្ញើរបាយការណ៍ឲ្យប៉េត្រូវតទៅទៀត ។

នៅពេលទៅដល់ប៉េកាំងភ្លាម ឡាយនី បានសរសេរលិខិតអញ្ជើញមិត្តភក្តិទាំងប៉ុន្មានដែលនៅទីក្រុងមូស្គូឲ្យមកទីក្រុងប៉េកាំងដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ។ បន្ទាប់ពីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាត្រូវបានបង្កើតឡើង ឡាយនី ត្រូវបានចាត់តាំងឲ្យបម្រើការនៅក្រសួងការបរទេស ។ ឡាយនី ពុំសូវមានវត្តមាននៅទីក្រុងប៉េកាំងទេ ច្រើនតែចេញទៅធ្វើទស្សនកិច្ចនៅប្រទេសមួយចំនួននៅខាងប៉ែកអាហ្វ្រិកជាមួយ សារិន ឆាក ដែលជារដ្ឋមន្ត្រីក្រសួងការបរទេស ។

ឆ្នាំ១៩៧១ ឡាយនី និងគណៈប្រតិភូរណសិរ្សរួបរួមជាតិកម្ពុជាដែលដឹកនាំដោយ ខ្ចូង សំអុល បានធ្វើដំណើរទៅទស្សនកិច្ចនៅប្រទេសសូវៀត ។ ក្នុងដំណើរទស្សនកិច្ចលើកនេះ ឡាយនី បានប្រគល់សម្ភារទាំងអស់ឲ្យវ៉ាឡូឌីយ៉ាវិញ និងសុំឲ្យ វ៉ាឡូឌីយ៉ា ទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ប៉ុន្តែ វ៉ាឡូឌីយ៉ា បដិសេធ ។ ជាមួយគ្នានោះ ប៉េត្រូវ នៅតែទទូចសុំឲ្យ ឡាយនី ទទួលយកផែនការមួយចំនួនរបស់ខ្លួនមាន ១) ជួយជំរុញសម្តេច សីហនុ និងរាជរដ្ឋាភិបាលព្រមចរចាជាមួយ លន់ ណុល ២) ណែនាំសម្តេច សីហនុ ឲ្យយាងទៅទីក្រុងហាណូយ និងលើករាជរដ្ឋាភិបាលទៅនៅហាណូយដើម្បីងាយស្រួលអូសទាញនិងទាក់ទងនិងគាំទ្រសហព័ន្ធឥណ្ឌូចិន ហើយប្រឆាំងនឹងសហព័ន្ធ៤ប្រទេសដែលមានកម្ពុជាវៀតណាម ឡាវ កូរ៉េ ចិន ៣) គាំទ្រកម្លាំងទីបី ដែលមានសឺន សាន ជាអ្នកដឹកនាំ និងទី៤ បន្តបង្កើតបក្សពួកក្នុងរណសិរ្សបន្តបង្កើតទំនាស់ ពិសេសធ្វើឲ្យសម្តេច សីហនុ និង ប៉ែន នុត មានទំនាស់ជាមួយគ្នា ដើម្បីធ្វើឲ្យចិនធុញទ្រាន់ ហើយសម្តេច សីហនុ នៅស្រុកចិនតទៅទៀតលែងបាន ។ ប៉េត្រូវ និយាយថា ប្រសិនបើ

ខាងរណសិរ្សឈ្មោះ គឺឲ្យ ឡាយនី និង ជួន មុម្ម និយាយជាមួយ អៀង សារី ឲ្យដាក់ទូតកម្ពុជានៅសូវៀត ឬប្រទេសដែលជាសមាជិកនៃបក្សសម្ព័ន្ធវ៉ាសូវីឲ្យបានឆាប់ដើម្បីងាយស្រួលក្នុងការទាក់ទងនិងជួយរារាំងចិនកុំឲ្យមានឥទ្ធិពលខ្លាំងមកលើកម្ពុជា និងសុំឲ្យ ជួន មុម្ម និង ស៊ាន អាន ក្តាប់ក្រសួងការបរទេសឲ្យជាប់ គឺធ្វើយ៉ាងណាឲ្យបក្ខពួករបស់ ជួន មុម្ម ដែលនៅក្រៅប្រទេស ចូលធ្វើការឲ្យបានច្រើនដើម្បីបង្កលក្ខណៈងាយស្រួលដល់សូវៀតក្នុងការបញ្ជូនអ្នកបច្ចេកទេសរបស់ខ្លួនមកកាន់កម្ពុជា ។ ឡាយនី បានបដិសេធផែនការនេះ ។

អង្គការបានទុកចិត្ត ឡាយនី និងប្រគល់ភារកិច្ចឲ្យធ្វើជាសមាជិកគណៈរណសិរ្សនៅប៉េកាំង ទទួលបន្ទុកមើលការខុសត្រូវជីវភាពសមាជិករណសិរ្សខ្មែរនៅប៉េកាំង ។

ខែឧសភា ឆ្នាំ១៩៧៣ ឡាយនី បានចូលជាសមាជិកបក្សកុម្មុយនិស្តកម្ពុជាក្រោមការទទួលនាមរបស់ ជួន មុម្ម និង ស៊ាន អាន ។

## ឡាយនី បន្ទាប់ពីមកដល់ប្រទេសកម្ពុជា

ឡាយនី បានទទួលការអនុញ្ញាតពីអង្គការចូលមកក្នុងប្រទេសកម្ពុជានៅចុងឆ្នាំ១៩៧៤ ។ ឡាយនី ត្រូវអង្គការបញ្ជូនទៅលត់ដំនៅមន្ទីរ ប-១៥ បន្ទាប់មកបញ្ជូនទៅមន្ទីរ ប-៣០០ ។

ក្រោយជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការចាត់តាំង ឡាយនី ឲ្យចុះធ្វើការនៅមូលដ្ឋានសង្កាត់មេសជ្រៃ ទទួលខុសត្រូវសហករណ៍ភូមិស្រែវាលនិងអាណិកជនចិនជាង ១០ភូមិ ។

ចាប់ពីខែ៨ ឆ្នាំ១៩៧៥ អង្គការបានប្រគល់ការងារឲ្យ ឡាយនី ធ្វើជាអ្នកពិធីការនៅក្នុងក្រសួងការបរទេស ។ ឡាយនី បានខិតខំបំពេញការងារដោយស្មោះត្រង់និងគោរពលក្ខការណ៍សម្ងាត់របស់បក្សជាប់ជានិច្ច ។ នៅក្នុងចម្លើយសារភាពរបស់គាត់ដែលធ្វើនៅមន្ទីរស-២១ ឡាយនី បានសារភាពជូនអង្គការថា «ក្រោយពីគាត់បានចូលបក្សកុម្មុយនិស្តកម្ពុជាមក ខ្ញុំគោរពស្មោះត្រង់បម្រើបក្សវណ្ណៈបដិវត្តគ្រប់ពេលវេលានិងគ្រប់ទីកន្លែង ។ ខ្ញុំមានមោទនភាពចំពោះបក្សដែលបានដឹកនាំប្រជាជននិងកងទ័ពបដិវត្តកម្ពុជាធ្វើសង្គ្រាមបានទទួលជ័យជម្នះនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដ៏មហាអស្ចារ្យមហាលោតផ្លោះ ហើយអាចដោះស្រាយស្បៀងបានគ្រប់គ្រាន់និងមានសល់ខ្លះ ក្នុងរយៈពេលជាងមួយឆ្នាំក្រោយសង្គ្រាម ដែលមិនដែលមានទេក្នុងសកលលោក ។ បដិវត្តកម្ពុជាបានជម្លៀសប្រជាជនទាំងអស់ចេញពីក្រុងនិងមិនចាយលុយ និយាយរួមគឺបក្សកុម្មុយនិស្តកម្ពុជាបានដោះស្រាយបញ្ហាគន្លឹះដ៏ស្មុគស្មាញបំផុតដែលកន្លងមកគ្មានបដិវត្តណាមួយអាចធ្វើបាន» ។

នៅចុងឆ្នាំ១៩៧៦ ឡាយនី ត្រូវអង្គការចាប់ខ្លួន ។ ឡាយនី ត្រូវអង្គការបញ្ជូនមកមន្ទីរឃុំឃាំងស-២១ និងសួរចម្លើយចំនួនបីលើក ។ នៅក្នុងចម្លើយសារភាពរបស់គាត់មានចំណាររមួយថា «ផ្តើមទារុណកម្មបន្ត១៦/១/៧៧» ។ នៅទំព័រមុខនៃចម្លើយសារភាពលើកទីបី ឌុច បានចារថា «ពួកមកពីសូវៀតដែលរាយការណ៍នៅក្នុងនេះចាប់អស់ហើយ នៅតែពួកមកពីបារាំងនិងអាល្លឺម៉ង់ ។ ពួកមកពីឆេកូចាប់នៅចុងឆ្នាំ៧៥និងដើមឆ្នាំ៧៦អស់ដែរ ។ ពួកអាល្លឺម៉ង់អាចមាន ចាំង ប៊ុងភាន ម្នាក់ទៀត» ។

## ប្រវត្តិគ្រួសារ

ឪពុករបស់ ឡាយនី ឈ្មោះ ម៉ុង ជាកសិករនៅភូមិតានួង ខេត្តកំពង់ចាម ។ ម្តាយឈ្មោះ ហាក់ អេង ជាមេផ្ទះ ។

ឡាយនី មានបងប្អូន៨នាក់ ១) ហាក់ ប៊ុនសេង(ប្រុស) ស្លាប់ដោយជំងឺ ២) ហាក់ ឆេងអ៊ួន (ស្រី) ជាគ្រូបង្រៀន ៣) ហាក់ ស៊ាង ឡាយនី ៤) ហាក់ ស៊ុនឡាយ (ប្រុស) ៥) ហាក់ គីមស្រ៊ាង (ប្រុស) ៦) ហាក់ ឆេងផន់ (ស្រី) ៧) ហាក់ ទ្រី (ប្រុស) និង៨) ហាក់ ស៊ីថា (ប្រុស) ។

ឡាយនី បានរៀបការជាមួយនារី ហាក់ ផាដេទ្ធ និងមានកូនពីរនាក់ ១) ឡាយនី ដេទ្ធារី (ស្រី) ឈ្មោះបដិវត្ត ណាត ២) ឡាយនី ចលនា (ប្រុស) ឈ្មោះបដិវត្ត ចន ។ នៅពេលត្រឡប់មកប្រទេសកម្ពុជា កុមារទាំងពីរត្រូវបញ្ជូនមកនៅមន្ទីរអង្គការនៅភូមិភាគឧត្តរ ។ លុះដល់ពាក់កណ្តាលឆ្នាំ១៩៧៦ អង្គការបានយកកុមារទាំងពីនេះមកដាក់នៅមន្ទីរសង្គមកិច្ចភ្នំពេញ ។

**លី សុផល**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៨៩៨ | គុន គូ | យុទ្ធជន | កងពល៣១០ | ២៤-២-៧៧ | ២៣-៣-៧៧ |
| ១៨៩៩ | នួន ចិត្ត ហៅ វ៉ើត | យុទ្ធជន | កងពល៣១០ | ១១-១-៧៧ | ២៣-៣-៧៧ |
| ១៩០០ | ហុង រា ហៅ វ៉ើត | យុទ្ធជន | កងពល៣១០ | ២៤-២-៧៧ | ២៣-៣-៧៧ |
| ១៩០១ | អ៊ុក រុន ហៅ យុន | មេក្រុមម៉ាស៊ីនបោកស្រូវ | កងពល៣១០ | ១០-៣-៧៧ | ២៣-៣-៧៧ |
| ១៩០២ | ម៉ែន ណូន ហៅ រុត | សមាជិកក្រុម | កងពល៣១០ | ៦-២-៧៧ | ២៣-៣-៧៧ |
| ១៩០៣ | ស៊ូ ទុយ ហៅ វ៉ីន | អនុក្រុម | កងពល៣១០ | ៦-២-៧៧ | ២៣-៣-៧៧ |
| ១៩០៤ | សុក នឿន ហៅ ណេន | សមាជិកក្រុម | កងពល៣១០ | ៦-២-៧៧ | ២៣-៣-៧៧ |
| ១៩០៥ | ស្រី ឡាំ ហៅ ភ័ព្វ | មេក្រុម | កងពល៣១០ | ៦-២-៧៧ | ២៣-៣-៧៧ |
| ១៩០៦ | ពេជ សំបុក ហៅ ភក្តិ | កងហា | កងពល៣១០ | ៦-២-៧៧ | ២៣-៣-៧៧ |
| ១៩០៧ | ដៃ សំអុល ហៅ សូ | យុទ្ធជនមន្ទីរវាយអគ្គីលេខ | កងពល៣១០ | ១៣-២-៧៧ | ២៣-៣-៧៧ |
| ១៩០៨ | នេត សឿង (ស្រី) | មើលកុមារ | កងពល៣១០ | ៩-៣-៧៧ | ២៣-៣-៧៧ |
| ១៩០៩ | នូ សេង (ស្រី) | មើលកុមារ | កងពល៣១០ | ៩-៣-៧៧ | ២៣-៣-៧៧ |
| ១៩១០ | នួន សន (ស្រី) | មើលកុមារ | កងពល៣១០ | ៩-៣-៧៧ | ២៣-៣-៧៧ |
| ១៩១១ | ប្រិប កិះ ហៅ យៀម (ស្រី) | មើលកុមារ | កងពល៣១០ | ៩-៣-៧៧ | ២៣-៣-៧៧ |
| ១៩១២ | ភិត ហម | យុទ្ធជន | កងពល៣១០ | ៩-២-៧៧ | ២៣-៣-៧៧ |
| ១៩១៣ | អ៊ុន សឿន ហៅ វ៉ាន់ | យុទ្ធជន | កងពល៣១០ | ៥-១-៧៧ | ២៣-៣-៧៧ |
| ១៩១៤ | សោម ហួត ហៅ ឌុក | មេក្រុម | កងពល៣១០ | ២៥-២-៧៧ | ២៣-៣-៧៧ |
| ១៩១៥ | នេត រិន ហៅ រុន | យុទ្ធជន | កងពល៣១០ | ២៥-២-៧៧ | ២៣-៣-៧៧ |
| ១៩១៦ | ដូ ហុច ហៅ ខាន់ | យុទ្ធជន | កងពល៣១០ | ២៥-១-៧៧ | ២៣-៣-៧៧ |
| ១៩១៧ | វៃ សាមឿន ហៅ ចាន់ ម៉ាវ៉ា | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩១៨ | កែវ ហាក់ ហៅ រដ្ឋ | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩១៩ | ញ៉ែម ឡី | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩២០ | ស៊ុន លីមផេង ហៅ សុភី | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩២១ | ថៅង ដុន ហៅ ភីន | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩២២ | ឈីម លីម | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩២៣ | គង់ សំអោក ហៅ សំអុល | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩២៤ | សូត មីន ហៅ ម៉ុល | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ១៩២៥ | តាំង ម៉េងឈាង ហៅ ដេត | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩២៦ | លឹម ស្រ៊ី | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩២៧ | លាង ស៊ិន | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩២៨ | ជា ជីន | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩២៩ | វ៉ាន់ សន | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩៣០ | ឡុង ណាគ្រី | យុទ្ធជន | កងពល១៧០ | ១០-៣-៧៧ | ២៣-៣-៧៧ |
| ១៩៣១ | ដួង ម៉ុន | នយោបាយ | កងពល១៧០ | ២៥-១-៧៧ | ២៣-៣-៧៧ |
| ១៩៣២ | ឈាង ពេជ ហៅ ឆៃ សាខន | យុទ្ធជន | កងពល១៧០ | ១៦-៣-៧៧ | ២៣-៣-៧៧ |
| ១៩៣៣ | ប៊ី ហ៊ាង ហៅ សារឿន | មេក្រុម | កងពល១៧០ | ១៦-៣-៧៧ | ២៣-៣-៧៧ |
| ១៩៣៤ | មិន សុភី | មេក្រុម | កងពល១៧០ | ១៦-៣-៧៧ | ២៣-៣-៧៧ |
| ១៩៣៥ | អ៊ុម សៀប | ជាងក្រឡឹង | កងពល១៧០ | ១៦-៣-៧៧ | ២៣-៣-៧៧ |
| ១៩៣៦ | តូច សាំ ហៅ ចន្ទ្រា | សេដ្ឋកិច្ច | កងពល១៧០ | ១៦-៣-៧៧ | ២៣-៣-៧៧ |
| ១៩៣៧ | ឆាយ យូ | មេពួក | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩៣៨ | ថៃ អៀវ ហៅ ណាំ | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩៣៩ | ដេង ហ៊ុន | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩៤០ | ចាយ វ៉ាន់ថា | យុទ្ធជន | កងពល១៧០ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩៤១ | ឈុន ចយ | ប្រធានកងហា | កងពល១៧០ | ២-១-៧៧ | ២៣-៣-៧៧ |
| ១៩៤២ | អ៊ិន សំអុន | ប្រធានកងហា | កងពល១៧០ | ២-១-៧៧ | ២៣-៣-៧៧ |
| ១៩៤៣ | សុស ទត ហៅ សាវ៉ាម៉ាត់ | មេក្រុម | កងពល២៩០ | ១២-១-៧៧ | ២៣-៣-៧៧ |
| ១៩៤៤ | រាល ឡាំ ហៅ នី | យុទ្ធជន | កងពល៤៥០ | ១១-៣-៧៧ | ២៣-៣-៧៧ |
| ១៩៤៥ | គាន់ លីម ហៅ សឿន | យុទ្ធជន | កងពល៤៥០ | ១១-៣-៧៧ | ២៣-៣-៧៧ |
| ១៩៤៦ | ជា ដួប ហៅ សាវុធ | មេក្រុម | កងពល៥០២ | ១៧-៣-៧៧ | ២៣-៣-៧៧ |
| ១៩៤៧ | ជា ប៉ោក ហៅ យ៉ាន | យុទ្ធជន | កងពល៥០២ | ១៨-៣-៧៧ | ២៣-៣-៧៧ |
| ១៩៤៨ | សេក អឿន | យុទ្ធជន | កងពល៥០២ | ១៨-៣-៧៧ | ២៣-៣-៧៧ |
| ១៩៤៩ | អ៊ុំច ថន | យុទ្ធជន | កងពល៥០២ | ១៨-៣-៧៧ | ២៣-៣-៧៧ |
| ១៩៥០ | ឡាច យឹន (ស្រី) | យុទ្ធនារីពេទ្យ | មន្ទីរពេទ្យ ព-៩៨ | ៦-១-៧៧ | ២៣-៣-៧៧ |
| ១៩៥១ | ហ៊ុយ វណ្ណា ហៅ ភា (ស្រី) | យុទ្ធនារីពេទ្យ | មន្ទីរពេទ្យ ព-៩៨ | ៦-១-៧៧ | ២៣-៣-៧៧ |
| ១៩៥២ | សន ឈឹម | យុទ្ធជនពេទ្យ | មន្ទីរពេទ្យ ព-៩៨ | ៦-១-៧៧ | ២៣-៣-៧៧ |
| ១៩៥៣ | ខៀវ ស្រ៊ឹម ហៅ ទួន | មេក្រុម | មន្ទីរពេទ្យ ព-៩៨ | ៦-១-៧៧ | ២៣-៣-៧៧ |
| ១៩៥៤ | ម៉ៅ ភេន | យុទ្ធជន | មន្ទីរពេទ្យ ព-៩៨ | ៦-១-៧៧ | ២៣-៣-៧៧ |
| ១៩៥៥ | ឆន សារិន ហៅ ញូតិ | យុទ្ធនារី | មន្ទីរពេទ្យ ព-៩៨ | ៦-១-៧៧ | ២៣-៣-៧៧ |

**(នៅមានត)**

# អ្នកទោសជនជាតិវៀតណាមនៅមន្ទីរស-២១


លឿន កុន ភ៉ាយ អាយុ ២៨ឆ្នាំ


ង្វៀម ថាញ់ សុង អាយុ ២៣ឆ្នាំ


ង្វ វ៉ាន់ ឡឹយ អាយុ ២០ឆ្នាំ


ង្វៀម ថាញ់ សុង អាយុ ២៣ឆ្នាំ


ចៀវ ឡុក អាយុ ៣០ឆ្នាំ









# វៀតណាម និង កម្ពុជាប្រជាធិបតេយ្យៈ សត្រូវដ៏ជូរចត់

វៀតណាមនិងកម្ពុជាដែលធ្លាប់ជាសម្ព័ន្ធភាពនឹងគ្នាក្នុងសង្គ្រាមប្រឆាំងបារាំងនិងសហរដ្ឋអាមេរិកនៅក្នុងអំឡុងពេលសង្គ្រាមឥណ្ឌូចិនបានក្លាយទៅជាសត្រូវស្លាប់រស់នឹងគ្នានៅមិនយូរប៉ុន្មានបន្ទាប់ពីការឡើងកាន់អំណាចរបស់កម្ពុជាប្រជា-ធិបតេយ្យនៅឆ្នាំ១៩៧៥ ។ កម្ពុជាប្រជាធិបតេយ្យបានចោទប្រកាន់វៀតណាមថាមានបំណងលេបយកទឹកដីកម្ពុជា ហើយនេះជាមូលហេតុដែលបង្កទៅជាជម្លោះនៅតាមព្រំដែនឥតឈប់ឈរនៅទូទាំងឆ្នាំ១៩៧៧និងឆ្នាំ១៩៧៨ រហូតដល់មានការផ្តួលរំលំរបបគ្រប់គ្រងនៅកម្ពុជាដោយវៀតណាមនៅឆ្នាំ១៩៧៩ ។

នៅពេលដែលជម្លោះព្រំដែនកាន់តែមានសភាពខ្លាំងក្លា កម្ពុជាប្រជាធិបតេយ្យបានប្រកាសថាខ្លួនបានកាត់ផ្តាច់ទំនាក់ទំនងជាមួយទីក្រុងហាណូយហើយ ។ ឯកអគ្គរដ្ឋទូតរបស់វៀតណាមមានពេលមួយសប្តាហ៍ដើម្បីចាកចេញពីប្រទេសកម្ពុជា ។ សេចក្តីប្រកាសនេះបានធ្វើឡើងបន្ទាប់ពីមានការវាយប្រហារយ៉ាងខ្លាំងក្លាមួយនៅតាមព្រំដែន ។ វិទ្យុទីក្រុងភ្នំពេញបានផ្សាយថា វៀតណាមកំពុងតែគំរាមកំហែងនិង "បានលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា" ។ យោងទៅតាមកាសែត "ថៃម" ចេញនៅឆ្នាំ១៩៧៨ ប៉ុល ពត បាននិយាយនៅក្នុងបទសម្ភាសន៍ជាមួយអ្នកកាសែតប្រទេសលោកខាងលិច (អេលីហ្សាប៊ែត ប៊ែកយ័រ និង ដាដមែន) ថា "វៀតណាមមានមហិច្ឆតាលេបយកប្រទេសកម្ពុជា ។ ប្រសិនបើយើងក្លាយជាប្រទេសរណបរបស់វៀតណាមនោះនឹងមានគ្រោះថ្នាក់ដល់តំបន់អាស៊ី-អាគ្នេយ៍ទាំងមូល ព្រោះថាវៀតណាមជាអាយ៉ងរបស់សូវៀតដែលកំពុងតែអនុវត្តនយោបាយវាតទីនិយម" ។

កាសែត "វ៉ាស៊ីនតោនប៉ុស្តិ៍" (កាលបរិច្ឆេទមិនដឹង) បានសរសេរថា វៀតណាមបានរាយការណ៍ថា ការបះបោរបានកើតឡើងនៅទូទាំងប្រទេសកម្ពុជា ។ ចំណែករដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានទទួលស្គាល់ថាយ៉ាងហោចណាស់មានប្រជាជនកម្ពុជាមួយចំនួនបានប្រឆាំងនឹងខ្លួន ហើយបានប្រកាសថាមាន"ជនក្បត់" និង "ភ្នែកដែលលួចរត់"ទៅជួយប្រទេសវៀត-ណាមដ៏គួរឲ្យស្អប់ខ្ពើម ។ កាសែតនេះបន្ថែមថា រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានអះអាងជាយូរមកហើយថា ជម្លោះព្រំដែនគឺមានប្រភពមកពីការប៉ុនប៉ងរបស់ទីក្រុងហាណូយក្នុងការធ្វើឲ្យទីក្រុងភ្នំពេញក្លាយជារណបរបស់ខ្លួនដូចដែលវៀតណាមធ្លាប់បានធ្វើជាមួយប្រទេសឡាវ ។

តាំងពីឆ្នាំ១៩៧៥ ប្រជាជនកម្ពុជាមួយចំនួនដែលរស់នៅក្បែរព្រំដែនកម្ពុជា-វៀតណាមបានភៀសខ្លួនចូលទៅក្នុងទឹកដីវៀតណាម ។ នៅចន្លោះខែមេសា ឆ្នាំ១៩៧៥ និងខែមេសា ឆ្នាំ១៩៧៦ ប្រទេសវៀតណាមបានបញ្ជូនជនភៀសខ្លួនកម្ពុជារាប់ពាន់នាក់ឲ្យត្រឡប់ទៅប្រទេសកម្ពុជាវិញតាមការស្នើសុំរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលទង្វើនេះត្រូវបានចាត់ទុកថាជាភ័ស្តុតាងនៃសុឆន្ទៈរបស់ភាគីវៀតណាម ។ ចាប់តាំងពីពេលមានជម្លោះព្រំដែនមក វៀតណាមបានចាប់ផ្តើមទទួលយកជនភៀសខ្លួនដែលហូរចូលពីប្រទេសកម្ពុជា ។ គោលនយោបាយនេះបង្ហាញពីការផ្លាស់ប្តូរឥរិយាបថរបស់ប្រទេសវៀតណាម ។

កាសែតញូវយ៉កថែមស៍បានរាយការណ៍ថា អ្នកយកសារពត៌មានរបស់ប្រទេសលោកខាងលិចម្នាក់ដែលទទួលបានការអនុញ្ញាតពីអាជ្ញាធរវៀតណាមទៅត្រួតពិនិត្យតំបន់ដែលនៅជាប់ព្រំដែនជាមួយប្រទេសកម្ពុជាកាលពីដើមឆ្នាំ១៩៧៨ បាននិយាយថា ស្ថានភាពនៅក្នុងជំរំគឺសែនលំបាក ។ ជនភៀសខ្លួនកម្ពុជានៅក្នុងប្រទេសវៀតណាមស្ទើរតែគ្មានអាហារបរិភោគ ។ ស្ត្រីភៀសខ្លួនម្នាក់និងកូនតូចៗពីនាក់របស់គាត់បានប្រាប់អ្នកឆ្លើយឆ្លងសារពត៌មានរបស់ទស្សនាវដ្តី "ឌីស្តីហែរល" របស់អាល្លឺម៉ង់ថា "យ៉ាងហោចណាស់យើងមិនចាំបាច់ព្រួយបារម្ភជា

វៀងរាល់យប់ខ្លាចត្រូវគេសម្លាប់ដែរ» ។

កម្ពុជាបានផ្សព្វផ្សាយសារមួយថាវៀតណាមកំពុងតែអនុវត្តនយោបាយឈ្លានពានកម្ពុជា ប៉ុន្តែវៀតណាមបានព្យាយាមពន្យល់ពិភពលោកថា កងកម្លាំងយោធារបស់ប្រទេសកម្ពុជាកំពុងតែប្រព្រឹត្តអំពើឃោរឃៅនិងសម្លាប់មនុស្សយ៉ាងវង្វេង ។ កាសែត «ញូវយ៉កថែមស៍» ចេញផ្សាយថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៨ បានរាយការណ៍ថា ឯកអគ្គរដ្ឋទូតរបស់ប្រទេសវៀតណាមប្រចាំនៅប្រទេសស្រីលង្កាបាននិយាយថា កម្ពុជាប្រជាធិបតេយ្យបានបង្កើនការវាយប្រហារនៅតាមព្រំដែន ហើយគាត់បានចោទប្រកាន់កងទ័ពកម្ពុជាថាបានប្រព្រឹត្ត «អំពើសាហាវយង់ឃ្នង» ។ លោកឯកអគ្គរដ្ឋទូតរូបនោះបានប្រាប់សន្និសីទសារព័ត៌មានថា «កងទ័ពកម្ពុជាបានចាប់រំលោភស្ត្រីកាត់ក្បាលបុរសនិងកុមារ ហើយប្រព្រឹត្តអំពើសាហាវឃោរឃៅចំពោះជនស៊ីវិលស្លូតត្រង់វៀតណាម» ។ គាត់បានបន្ថែមទៀតថា កម្ពុជាប្រជាធិបតេយ្យបានបង្កជម្លោះនៅតាមព្រំដែនដោយចេតនានិងបានឈ្លានពានចូលទឹកដីវៀតណាម ។

យោងតាមព័ត៌មានក្នុងកាសែត «ញូវយ៉កថែមស៍» កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៧៨ អៀង សារី បានធ្វើដំណើរទៅប្រទេសជាច្រើនក្នុងគោលបំណងស្វែងរកសម្ព័ន្ធមិត្តប្រឆាំងនឹងប្រទេសវៀតណាមនិងដើម្បីស្តារឡើងវិញនូវកេរ្តិ៍ឈ្មោះរបស់កម្ពុជាចំពោះការចោទប្រកាន់ដែលថារដ្ឋាភិបាលកុម្មុយនិស្តបានសាបព្រោះអំពើមហាប្រល័យនិងអំពើអមនុស្សធម៌ផ្សេងៗទៀត ។ អៀង សារី ថែមទាំងបានអញ្ជើញលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ខឺត វ៉ល ដែម និងអ្នកកាសែតឲ្យមកធ្វើទស្សនកិច្ចដោយផ្ទាល់ដើម្បីមើលឲ្យឃើញអំពីការពិតថាតើកម្ពុជាពិតជាបានរំលោភសិទ្ធិមនុស្សមែនដែរឬទេ ។

អ្នកកាសែតជនជាតិអ៊ីតាលី (ទីហ្សីយ៉ាណូ ទែហ្សានី) ដែលជាអ្នកឆ្លើយឆ្លងព័ត៌មានរបស់ទស្សនាវដ្តីនេះប្រចាំនៅអាស៊ី-អាគ្នេយ៍បានរាយការណ៍ថា នៅក្នុងរយពេលបីសប្តាហ៍ដំបូងនៃខែមីនា ឆ្នាំ១៩៧៨ នៅពេលដែលវៀតណាមធ្វើយុទ្ធនាការ



ឃោសនាប្រឆាំងទៅនឹងអ្វីដែលរដ្ឋាភិបាលនេះបរិយាយថាជាអំពើសាហាវយង់ឃ្នងរបស់រដ្ឋាភិបាលកម្ពុជា វៀតណាមបានអនុញ្ញាតឲ្យអ្នកកាសែតមួយក្រុមធ្វើទស្សនកិច្ចនៅតំបន់ព្រំដែនភាគខាងត្បូងរបស់ខ្លួនដើម្បីមើលការបំផ្លិចបំផ្លាញដែលបង្កឡើងដោយការវាយប្រហារជាបន្តបន្ទាប់របស់កម្ពុជា ។ នៅពេលត្រឡប់មកពីទស្សនកិច្ចវិញ អ្នកកាសែតទាំងនោះបានរាយការណ៍ថា វៀតណាមកំពុងតែរៀបចំធ្វើសង្គ្រាមដ៏យូរអង្វែងមួយ ។ ហ្វ្រេដ អែស ហូហ្វមែន អ្នកសរសេរព័ត៌មានយោធាឲ្យកាសែត «អេភី» បានរាយការណ៍ពីទីក្រុងវ៉ាស៊ីនតោន កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៧៨ថា យោងតាមប្រភពពីភ្នាក់ងារសម្ងាត់របស់សហរដ្ឋអាមេរិក វៀតណាមបានបញ្ជូនកងទ័ពជំនួយបន្ថែមជាច្រើនទៀតទៅតំបន់ដែលកំពុងមានជម្លោះនៅក្នុងក្ដីរំពឹងទុកថាការវាយប្រហារដ៏ខ្លាំងមួយនឹងកើតមានឡើងនៅក្នុងរយៈពេលប៉ុន្មានសប្ដាហ៍ទៀត ។

ណាយ៉ាន់ ចាន់ដា អ្នកយកព័ត៌មានរបស់ទស្សនាវដ្ដី «សេដ្ឋកិច្ចចុងបូព៌ា» បានឲ្យដឹងថា កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ មានសញ្ញាមួយចំនួនដែលអាចបញ្ជាក់អំពីការរៀបចំខ្លួនរបស់ទីក្រុងហាណូយដើម្បីធ្វើសង្គ្រាមជាមួយប្រទេសកម្ពុជា ដែលក្នុងនោះរួមមានៈ ការជម្លៀសប្រជាជនចេញពីតំបន់ព្រំដែន, ទស្សនកិច្ចរបស់លោកឧត្ដមសេនីយ៍ វ៉ៃ ង្វៀង យ៉ាប់ ទៅកាន់តំបន់យោធភូមិភាគទី៧ (ជាប់នឹងព្រំដែនប្រទេសកម្ពុជាមានខេត្តស្វាយរៀង ព្រៃវែង និងកំពង់ចាម ជាកន្លែងទើបតែទទួលរងការវាយប្រហារថ្មីៗ) និងការរៀបចំធ្វើសន្និសីទមួយនៅយោធភូមិភាគទី៧ក្រោមអធិបតីភាពរបស់លោកឧត្ដមសេនីយ៍ ជូ ហ៊ុយ ម៉ាន ។ ទីក្រុងហាណូយបាននិយាយថា ការវាយប្រហាររបស់វៀតណាមត្រូវបានស្នើឡើងដើម្បីបញ្ចប់ «ឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនខ្លួនឯង» របស់អាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ ។ នៅចុងឆ្នាំ១៩៧៨ កាសែត «ញូវយ៉កថែមស៍» បានរាយការណ៍ថា ទាហានវៀតណាមចំនួន ៦កងពលបានលុកចូលយ៉ាងជ្រៅទៅក្នុងទឹកដីកម្ពុជានៅតំបន់ «ចំពុះទា»នៃខេត្តស្វាយរៀង ។

កម្ពុជាប្រជាធិបតេយ្យបានទទួលជំនួយឧបត្ថម្ភសព្វាវុធមួយផ្នែកធំអំពីប្រទេសចិនដែលជាមិត្តភក្ដិជិតស្និទ្ធបំផុត ។ ដោយសារតែមូលហេតុនេះ វៀតណាមបានចោទប្រកាន់ប្រទេសចិនថាជា«មេខ្លោងធំបំផុត»នៅក្នុងជម្លោះព្រំដែនរវាងកម្ពុជានិងវៀតណាម ។ កាសែត«ញូវយ៉កថែមស៍» កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៨ បានរាយការណ៍ថា កាសែតញិនហ្សិនរបស់បក្សកុម្មុយនិស្តវៀតណាមបានចោទប្រកាន់មេដឹកនាំកម្ពុជាថាបាន «បង្ហូរឈាមប្រជាជនកម្ពុជានិងប្រជាជនវៀតណាម» ។ កាសែតនេះបាននិយាយថា ប្រទេសចិនជាមេខ្លោងធំបំផុតនៅពីក្រោយរឿងនេះ ហើយមេដឹកនាំចិនកំពុងតែអនុវត្តនយោបាយវាតទីនិយម ។

ទាំងទីក្រុងប៉េកាំងនិងទីក្រុងម៉ូស្គូហាក់បីដូចជារួញរាក្នុងការលូកដៃចូលក្នុងជម្លោះព្រំដែនរវាងកម្ពុជាប្រជាធិបតេយ្យនិងវៀតណាម ដោយសារតែរដ្ឋាភិបាលទាំងពីរនេះភ័យខ្លាចជួបនឹងលទ្ធផលដ៏អាក្រក់ដូចដែលប្រទេសបារាំងនិងសហរដ្ឋអាមេរិកធ្លាប់ជួបប្រទះនៅក្នុងសង្គ្រាមឥណ្ឌូចិន ។ ហ្វ្រេង ឈីង អ្នកយកព័ត៌មានរបស់កាសែត «វ៉លស្ទ្រីតជ័រណល» បានរាយការណ៍កាលពីថ្ងៃទី៤ ខែមករាឆ្នាំ១៩៧៨ថា ទាំងចិននិងសូវៀតហាក់បីដូចជាខ្លាចរអាក្នុងការដាក់ខ្លួនចូលទៅក្នុងជម្លោះនៅក្នុងតំបន់ឥណ្ឌូចិន ។ អ្នកយកសារព័ត៌មានរូបនេះបានបន្ថែមទៀតថា ប្រសិនបើវៀតណាមតែឯងប៉ុនប៉ងផ្ដួលរំលំរដ្ឋាភិបាលកម្ពុជានៅពេលនោះ ហើយបង្កើតរដ្ឋាភិបាលអាយ៉ងមួយ ប្រទេសចិនប្រាកដជាលូកដៃចូលជាមិនខាន ។ ផ្ទុយទៅវិញ ដោយសារតែវៀតណាមមានទីក្រុងម៉ូស្គូនៅពីក្រោយ ទីក្រុងប៉េកាំងបានប្រកាន់យកនូវគោលជំហរមួយថ្មីទៅវិញគឺមិនលូកដៃចូលដោយផ្ទាល់ទៅក្នុងជម្លោះយោធារបស់កម្ពុជាទេនៅពេលដែលសង្គ្រាមនៅតាមព្រំដែនកម្ពុជា-វៀតណាមមានសន្ទុះកាន់តែខ្លាំងឡើង ។ សម្រាប់ប្រទេសចិន បញ្ហានេះជាបញ្ហាយ៉ាងធ្ងន់ធ្ងរ ប្រសិនបើប្រទេសដែលនៅក្រោមការឧបត្ថម្ភរបស់ខ្លួនត្រូវឈ្លានពានពីទីក្រុងហាណូយ នោះឥទ្ធិពលរបស់ទីក្រុងប៉េកាំងនៅក្នុងតំបន់នឹងដល់ទីបញ្ចប់ជាមិនខាន ។ ផ្ទុយទៅវិញ សហរដ្ឋអាមេរិកមានពេលទំនេរដើម្បីអង្គុយមើលជម្លោះនេះ ។

**ឌី ឆេរិទ្ធិ**

# មជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរករូបថតជនរងគ្រោះ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា "ជីវិតក្នុងភាពនឹងថ្កល់" ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ *FM102MHz* ទីក្រុងភ្នំពេញ វិទ្យុ *FM93.25MHz* ខេត្តកំពត វិទ្យុ *FM99MHz* ខេត្តព្រះវិហារ និងវិទ្យុ*FM* ១០៣.២៥*MHz* ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី "ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ" ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះ យើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ




យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួន ។ រូបថតទាំងនោះចាំបាច់ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នកបន្ទាប់មកនឹងប្រគល់រូបថតដើមជូនទៅលោកអ្នកវិញ ។

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រ លេខ១១១០ ភ្នំពេញ ឬទាក់ទងតាមអ៊ីមែល *truthwynne@dccam.org* ឬ *truthpivoine@dccam.org* ។

សូមអរគុណ ។

# មិនចង់ចងពៀរ ប៉ុន្តែនៅតែចងចាំ



សោម សាមៀន

សោម សាមៀន កើតនៅឃុំតាកែម ស្រុកត្រាំកក់ ខេត្តតាកែវ ។ សាមៀន មានបងប្អូន ៦នាក់ ។ ម្តាយឈ្មោះ ទឹម សៅ និងឪពុកឈ្មោះ សោម ប៊ិន ។ ក្រុមគ្រួសាររបស់ សាមៀន ប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត ។ កាលពីកុមារ សាមៀន បានចូលរៀននៅសាលាក្នុងភូមិកំណើត ។

នៅឆ្នាំ១៩៧០ សាមៀន បានឮថា សិស្សសាលា១ខសកាធ្វើបាតុកម្មប្រឆាំងនឹងរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ប៉ុន្តែនៅក្នុងភូមិរបស់គាត់មិនមានការប្រឆាំងណាមួយឡើយ ។ ឆ្នាំ១៩៧១ ឃុំតាកែមក្លាយជាតំបន់ប្រទាញប្រទង់រវាងកងទ័ពខ្មែរក្រហម និងទាហានលន់ណុល ។ ដោយសារតែភ័យខ្លាចការប្រយុទ្ធគ្នានេះ នៅឆ្នាំ១៩៧២ ក្រុមគ្រួសាររបស់ សាមៀន ព្រមទាំងអ្នកភូមិត្រពាំងកប្បាសជាច្រើនគ្រួសារទៀតបានចាកចេញពីភូមិទៅរស់នៅឃុំអង្គតាសោម ។ ប្រហែលឆ្នាំ១៩៧៣ នៅពេលដែលខ្មែរ-ក្រហមដណ្តើមកាន់កាប់បានឃុំតាកែមនិងឃុំអង្គតាសោម ខ្មែរ-ក្រហមបានចាប់ផ្តើមចោទអ្នកដែលរត់ចោលភូមិថាជាសក្តិភូមិនាយទុននិងជាអ្នកទោស ហើយបានចាប់ខ្លួនបុរសដែលមានអាយុចាប់ពី១៨ឆ្នាំឡើងយកទៅសម្លាប់ ។ សាមៀន និយាយថា “គេ (ខ្មែរក្រហម) ចងស្លាបសេកឪពុកនិងបងប្រុសព្រមទាំងបងប្រុសជីដូនមួយពីរនាក់របស់ខ្ញុំ បណ្តើរយកទៅសម្លាប់នៅឃុំពពេល ។ ខ្មែរក្រហមដាក់គាត់នៅចំពោះមុខយើង ប៉ុន្តែយើងរកជួយគាត់មិនកើតបានត្រឹមតែយំ ហើយត្រូវគេហាមឃាត់មិនឲ្យយើងយំទៀត ខ្ញុំខ្លោចផ្សារណាស់” ។ ខ្មែរក្រហមប្រើដំបងឫស្សីវាយក្បាលបុរសៗទាំងនោះ ហើយច្រានទម្លាក់ក្នុងរណ្តៅគ្រាប់នៅក្នុងឃុំពពេល រួចហើយយកស្ត្រីនៅក្នុងភូមិទៅដាក់នៅក្នុងមន្ទីរលត់ដំខ្លួននៅព្រៃក្ទួច ហៅមន្ទីរ២០៥ ។ សាមៀន បញ្ជាក់ថា “ខ្ញុំនិងម្តាយខ្ញុំព្រមទាំងអ្នកភូមិស្រីៗទាំងអស់ត្រូវរស់នៅក្នុងមន្ទីរលត់ដំ ។ វាមិនមែនជាមន្ទីរឃុំឃាំងទេ តែដូចជាមន្ទីរឃុំឃាំងដែរ ព្រោះអីយើងអត់បានដើរទៅណាទេក្រៅពីបរិវេណដែលគេកំណត់ ។ គេប្រើយើងឲ្យធ្វើការធ្ងន់ឥតឈប់ឈរ ដូចជារែកដីកាប់ដី គាស់រំលើងគល់ឈើធំៗជាដើម គេថាយើងជាមនុស្សពេញកម្លាំងត្រូវធ្វើការដូចមនុស្សប្រុសដែរ ។ យើងហេវហត់ណាស់” ។ ការងារធ្ងន់និងកង្វះខាតអាហារបានសម្លាប់ក្មួយស្រីរបស់ សាមៀន អស់៤នាក់ ។ សាមៀន ដោយរស់នៅជួបជុំម្តាយនៅមន្ទីរ២០៥បានមួយខែ ក៏ត្រូវខ្មែរក្រហមបំបែកគាត់ឲ្យទៅធ្វើការនៅឯជើងភ្នំ(ក្នុងព្រៃក្ទួច) ។ ការងាររបស់គាត់គឺកាប់អុស កាប់ដី លើកទំនប់ គាស់គល់ឈើ និងជួនកាលទៅកាប់ឫស្សីនៅលើភ្នំ ។ រស់នៅព្រៃក្ទួចបានប្រហែល៧ខែ ខ្មែរក្រហមក៏ចាត់តាំងឲ្យ សាមៀន និងអ្នកភូមិត្រឡប់ទៅរស់នៅភូមិកំណើតវិញដើម្បីធ្វើពលកម្ម ដោយប្រកាសគោលនយោបាយ “ធ្វើស្រែ១ហិកតាឲ្យបាន៣តោន” ។ សាមៀន មកដល់ភូមិធ្វើការងារបង្កបង្កើនផលដូចជា រែកដីដាក់ស្រែ ដកស្ទូង ដាំបន្លែ រែកទឹកស្រោចបន្លែៗល ។ គាត់និយាយថា “ទោះបីជាការងារនៅភូមិស្រាលជាងការងារនៅកន្លែងដែលខ្ញុំរស់នៅពីមុនក៏ដោយ ក៏ការរស់នៅនិងការហូបចុកពិបាកណាស់ ។ ខ្មែរក្រហមចែករបបអាហារទៅតាមកម្លាំងគឺ កម្លាំងទី១ជាមនុស្សពេញកម្លាំងហើយធ្វើការច្រើនបានបាយទៅ កម្លាំងទី២ជាកម្លាំងល្មមដូចជាអ្នកទន់ខ្សោយនិងអ្នកជំងឺ បានបបរទៅ ។ កាលហ្នឹងខ្ញុំអាយុ១៦ឆ្នាំ គេ(ខ្មែរ-ក្រហម)ថា ខ្ញុំជាមនុស្សពេញកម្លាំងស្ថិតនៅក្នុងកម្លាំងទី១ ដូច្នេះខ្ញុំបានបាយ ប៉ុន្តែហូបមិនឆ្អែតទេ” ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យអ្វីក៏ចាត់ទុកជាកំហុសដែរ ហើយអ្នកដែលធ្វើខុសត្រូវយកទៅសម្លាប់ចោលឬយកទៅកសាង ។ សាមៀន និយាយថា “សូម្បីតែយើងធ្វើការមិនទាន់

ផែនការក៏ជាកំហុស ដាំបាយក្រឆ្និតក៏ជាកំហុស ស្អីៗក៏ជាកំហុសដែរ ។ គ្រាន់តែថាទោសនារីស្រាលជាងទោសបុរស ។ បុរសខុសតែម្តងត្រូវយកទៅសម្លាប់ ប៉ុន្តែនារីទាល់តែខុសបីដងទើបយកទៅសម្លាប់ បើខុសតែម្តងគ្រាន់តែយកទៅកសាងខ្លួនប៉ុណ្ណោះ ។ កាលហ្នឹងរកតែព្រលឹងមិនឃើញទេ គេមិនវាយដំយើងទេ ប៉ុន្តែគេប្រើយើងឥតឈប់ឈរ ប្រើទាំងយប់ប្រើទាំងថ្ងៃ ។ ពេលមួយនោះខ្ញុំបានឮថា ខ្មែរក្រហមសម្លាប់បុរសម្នាក់ដោយសារតែបុរសនោះបដិសេធមិនព្រមភ្ជក់លាមកដែលលាយធ្វើជីដាក់ចម្ការ» ។

ខ្មែរក្រហមចាប់ផ្តើមធ្វើប្រវត្តិរូបឡើងវិញដោយឃោសនាថា «បើអ្នកធ្លាប់ធ្វើការងារអីសូមឆ្លើយតាមត្រង់ អង្គការនឹងឲ្យទៅកាន់តំណែងដដែលវិញ» ។ អ្នកដែលឆ្លើយថាធ្លាប់មានបុណ្យសក្តិធំចេញមកសារភាពត្រូវខ្មែរក្រហមចាត់ឲ្យទៅដឹកអំបិលនៅខេត្តកំពត ។ សាមឿន និយាយថា «ប្រាកដជាខ្មែរក្រហមសម្លាប់ចោលអ្នកទាំងនោះហើយ ព្រោះមិនឃើញនរណាម្នាក់វិលត្រឡប់មកវិញសោះ» ។

នៅពេលភ្លៀងម្តងៗ សាមឿន បន់ឲ្យតែរបបខ្មែរក្រហមផុតរលត់ទៅឆាប់ៗ ព្រោះគាត់ស្ទើរតែទ្រាំមិនបាននឹងការរស់នៅក្នុងសភាពភ័យរន្ធត់គ្រប់ពេលវេលាដូច្នេះ ។ ថ្ងៃមួយនៅពេលដែល សាមឿន កំពុងធ្វើការងារ គាត់បានឮស្នូរគ្រាប់កាំភ្លើង ។ សាមឿន បានរត់គៀសខ្លួនទៅស្រុកលើកដែកនៅក្បែរជើងភ្នំជាមួយម្តាយ លុះដល់សភាពការណ៍ស្ងប់ស្ងាត់ គាត់ក៏ត្រឡប់មកភូមិវិញ ហើយក្រោយមកទើបគាត់បានជួបជុំបងប្អូនរបស់គាត់ ។

សាមឿន ប្រៀបធៀបរបបខ្មែរក្រហមទៅនឹងគុកឥតជញ្ជាំង ។ ទោះបីខ្មែរក្រហមប្រកាសថារបបរបស់ខ្លួនគ្មានគុកមែន ប៉ុន្តែទំហំការងារ របបហូបចុក ការវាស់ដីឲ្យដើរ ការគំរាមកំហែងយកទៅសម្លាប់ លើសពីអ្នកទោសដែលជាប់ក្នុងគុកទៅទៀត ។

មកដល់សព្វថ្ងៃនេះ សាមឿន ជាស្ត្រីម៉េម៉ាយកូន៥នាក់ ។ ប្តីរបស់គាត់ឈ្មោះ ទូច ប៉ាក ដែលខ្មែរក្រហមផ្សំផ្គុំឲ្យនៅឆ្នាំ ១៩៧៨ បានស្លាប់ដោយជំងឺគ្រុនចាញ់នៅពេលគាត់ទៅប្រកបរបររកស៊ីនៅក្រុងប៉ៃលិនកាលពី៧ឆ្នាំមុន ។ ចំណែកម្តាយរបស់គាត់ស្លាប់ដោយសារជំងឺកាលពី១០ឆ្នាំមុននេះ ។

សាមឿន រស់នៅជាមួយអតីតកាលនៃរបបខ្មែរក្រហមអស់រយៈពេលជាង៣០ឆ្នាំហើយ ។ ពេលណាដែលគាត់សម្រាន្តមិនលក់ រូបភាពទាំងឡាយនៅក្នុងរបបខ្មែរក្រហមក៏ផុសឡើងវិញ ជាពិសេសទិដ្ឋភាពខ្មែរក្រហមចាប់ឪពុកនិងបងប្រុសរបស់គាត់យកទៅសម្លាប់ ។ រឿងរ៉ាវទាំងអស់នោះហាក់ដូចជានៅថ្មីៗនៅឡើយចំពោះគាត់ ។ សាមឿន និយាយថា «ខ្ញុំមិនចង់ចងពៀរទេណា៎ ប៉ុន្តែកំហឹងឈឺចាប់នៅតែមានអ្វីចឹងមិនអាចបំភ្លេចបានទេ» ។ សព្វថ្ងៃនេះ អ្វីដែលអាចជួយ សាមឿន ឲ្យធូរស្រាលចិត្តបានគឺព្រះពុទ្ធសាសនា ។ រាល់ពេលដែលគាត់តានតឹងក្នុងចិត្ត គាត់ទៅវត្តសូត្រធម៌ ធ្វើបុណ្យទាន ហើយគាត់ក៏បានធូរស្រាល ។

**សុ ហ្សារីណា**

# កាណាដាប្រកាសឧបត្ថម្ភអង្គជំនុំជម្រះវិសាមញ្ញ

កាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៥ ប្រទេសកាណាដាបានប្រកាសថាខ្លួននឹងឧបត្ថម្ភថវិកាចំនួន២លានដុល្លារកាណាដាដែលត្រូវជា១,៦៤លានដុល្លារអាមេរិកដល់អង្គការសហប្រជាជាតិដើម្បីរួមចំណែកដល់ការបង្កើតនិងដំណើរការអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ ។ សម្រាប់អង្គជំនុំជម្រះវិសាមញ្ញដែលមានរយៈពេលបីឆ្នាំ ថវិកាចំនួន២លានដុល្លារកាណាដានេះនឹងត្រូវបែងចែកជាពដំណាក់កាលគឺ ១លានដុល្លារកាណាដាសម្រាប់រយៈពេលមួយឆ្នាំដំបូង ៥០ម៉ឺនដុល្លារកាណាដាសម្រាប់ឆ្នាំទីពីរ និង៥០ម៉ឺនដុល្លារកាណាដាទៀតសម្រាប់ឆ្នាំចុងក្រោយ ។

# ហេតុអ្វីខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម្ល៉េះ?

**(តពីលេខមុន)**

### ឃ) ភាពចាំបាច់ក្នុងការរៀបចំប្រវត្តិសាស្ត្រ

នៅខែមីនា ឆ្នាំ១៩៧៦ គណៈកម្មាធិការមជ្ឈិមបានសម្រេចកាត់ផ្តាច់រាល់ទំនាក់ទំនងជាមួយបក្សកុម្មុយនិស្តវៀតណាម ។ ឆ្នាំកំណើតរបស់បក្សត្រូវបានប្តូរទៅឆ្នាំ១៩៦០ ។ ទស្សនាវដ្តី «ទង់បដិវត្ត» បានពន្យល់ថា «ចាប់ពីពេលឥឡូវនេះទៅ យើងត្រូវតែរៀបចំប្រវត្តិសាស្ត្រឲ្យទៅជាអ្វីមួយដែលស្អាតនិងឥតខ្ចោះ ឲ្យស្របទៅនឹងគោលនយោបាយឯករាជ្យនិងគ្រប់គ្រងខ្លួនឯង» ។ អ្នកទាំងឡាយដែលបានចូលបក្សមុនឆ្នាំ១៩៦០ លែងរាប់ថាជាសមាជិកបក្សទៀតហើយ ។ ប្រសិនបើអ្នកទាំងនោះយល់ព្រម គណៈកម្មាធិការមជ្ឈិមបក្សនឹងពិចារណាដាក់បេក្ខភាពរបស់គាត់សាជាថ្មី ។ ប្រសិនបើមិនព្រមទេ គាត់អាចនឹងត្រូវបញ្ជូនទៅកន្លែងលត់ដំកសាងខ្លួន ។ នៅខែធ្នូ ថ្នាក់ដឹកនាំបានពិភាក្សាថាតើបក្សគួរតែបើកចំហឲ្យដឹងជាសាធារណៈដែរឬទេ ។ ពីខែកញ្ញាដល់ខែតុលា ថ្នាក់ដឹកនាំបក្សបានគិតថានឹងធ្វើយ៉ាងនេះ ប៉ុន្តែឯកសារបានបង្ហាញថាមានសត្រូវដែលចង់យកឈ្នះបក្សកុម្មុយនិស្តកម្ពុជា ហេតុដូច្នេះហើយបានជាមេដឹកនាំបក្សសម្រេចចិត្តថាមិនទាន់ដល់ពេលវេលាដែលត្រូវបើកចំហបក្សឲ្យដឹងជាសាធារណៈនៅឡើយទេ ។ នៅខែកញ្ញាឆ្នាំ១៩៧៧ បក្សកុម្មុយនិស្តកម្ពុជាបានបង្ហាញខ្លួនជាសាធារណៈ ។ ក្រោយមកទៀត ប្រជាជនបានត្រឹមតែឈ្មោះ «អង្គការ» ប៉ុណ្ណោះ ។

### ង) ឧបករណ៍សន្តិសុខ

នៅខែមីនាឆ្នាំ១៩៧៦ មជ្ឈិមបក្សបានផ្តល់អំណាចឲ្យគណៈកម្មាធិការអចិន្ត្រៃយ៍ភូមិភាគក្នុងការកំណត់ថាអ្វីដែលត្រូវតែកម្ទេចទាំងខាងក្នុងនិងខាងក្រៅបក្ស ។ ជាក់ស្តែង អំណាចនេះត្រូវបានអនុវត្តជាញឹកញាប់ដោយលេខាបក្សនៅតាមភូមិភាគ ។ អំណាចនេះក៏ត្រូវបានផ្ទេរទៅឲ្យប្តូងណ្តើមយកដោយកម្មាភិបាលថ្នាក់ស្រុក ឬថ្នាក់ទាបជាងនេះ រួមទាំងគណៈសហករណ៍ផង ។ បណ្តាញគុកត្រូវបានបង្កើតនៅថ្នាក់ភូមិភាគ តំបន់ ស្រុក ឃុំ និងភូមិ ។ មានមន្ទីរឃុំឃាំងចំនួន១៨៥ នៅទូទាំងប្រទេស ។ ទិន្នន័យបានបង្ហាញថា ជាមធ្យមមន្ទីរឃុំឃាំងនីមួយៗមានអ្នកទោសជិត១ម៉ឺននាក់ ហើយចំនួនអ្នកទោសខុសគ្នាពីខេត្តមួយទៅខេត្តមួយ ។ លេខកូដ «ស-២១» ចាប់ផ្តើមលេចរូបរាងនៅខែកញ្ញា ឆ្នាំ១៩៧៥ ។ «ស» ហាក់បីដូចជាតំណាងឲ្យ«សាលា» ឬ«សាល» ។ «២១» គឺជាលេខកូដដែលប្រើសំដៅទៅ «សន្តិបាល» មកពី «សន្តិសុខ + នគរបាល» ។ នៅខែឧសភាឆ្នាំ១៩៧៦ «ស-២១» បានប្តូរឈ្មោះទៅជា «ទួលស្លែង» នៅភ្នំពេញ ។

### ច) បន្សុទ្ធកម្ម

កង្វល់ដ៏ធំបំផុតរបស់មជ្ឈិមបក្សគឺសត្រូវដែលលាក់ខ្លួននៅក្នុងបក្សខ្លួនឯងតែម្តង ។ នៅខែធ្នូឆ្នាំ១៩៧៥ ទស្សនាវដ្តីទង់បដិវត្តបាននិយាយថា «សត្រូវបានព្យាយាមធ្វើឲ្យបដិវត្តន៍ប្តូរពណ៌» ។ មានព្រឹត្តិការណ៍ពីរនៅក្នុងឆ្នាំ១៩៧៦ដែលនាំឲ្យមានសកម្មភាពស្វែងរកសត្រូវនៅក្នុងបក្ស ។ នៅថ្ងៃទី២៥ ខែកុម្ភៈ មានហេតុ-ការណ៍ផ្ទុះគ្រាប់ជាច្រើនកន្លែងនៅក្នុងខេត្តសៀមរាប ។ ស្ថានភាពនៅពេលនោះមិនច្បាស់លាស់ទេ ប៉ុន្តែមានសញ្ញាបង្ហាញថាការផ្ទុះនោះជាប់ទាក់ទងនឹងការប៉ុនប៉ងរៀបចំការបះបោរ ។ នៅខែមេសាមានការគប់គ្រាប់បែកដៃមួយនៅក្បែរព្រះបរមរាជវាំង ។ ក្រុមសន្តិបាលបានវាយតម្លៃថា គោលបំណងនៃការបោកគ្រាប់បែកគឺដើម្បីបន្ថុចកេរ្តិ៍ឈ្មោះរបស់បក្សដោយការធ្វើគុតសម្តេចសីហនុ ។ ហេតុការណ៍នេះមានជាប់ទាក់ទងជាមួយនឹងនាយទាហានក្នុងកងពលធំលេខ១៧០ ។ មេបញ្ជាការរបស់កងពលនេះដែលជាអតីតមេបញ្ជាការកងពលភូមិភាគបូព៌ា ត្រូវបានបង្ខំឲ្យសារភាពនៅក្នុងគុកទួលស្លែងថាជាសមាជិកនៃបណ្តាញស៊ើបការណ៍ដែលបញ្ជាដោយវៀតណាម សេ.អ៊ី.អា និងសូវៀត ។ «ស-២១» បានរកឃើញអង្គការស៊ើបការណ៍សម្ងាត់ដ៏ធំមួយគឺ «បណ្តាញចម្ការកៅស៊ូ» ។ ពាក្យនេះគឺសំដៅទៅភូមិភាគបូព៌ា ។ មួយភាគបីនៃអ្នកទោសដែលបញ្ជូនចូលទួលស្លែងពីខែកក្កដាដល់ខែកញ្ញាគឺមកពីកងពលធំលេខ១៧០ ។

*នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦ សេនាធិការមានភារកិច្ចដោះស្រាយការបះបោរនៅភូមិភាគនិរតីដែលបង្កដោយអ្នកគាំទ្រព្រះពុទ្ធសាសនា អ្នកប្រឆាំងកុម្មុយនិស្ត និងចលនាប្រឆាំងនឹងសមូហភាពនិយមដែលលើកពាក្យស្លោក "ជយោរណសិរ្សខ្មែរសេរីដោះជាតិពីសីុអន្តរកំប៉ុង" ។ មនុស្សប្រហែល ១៦០នាក់ត្រូវចាប់ខ្លួន។ សុន សេន បានផ្តល់យោបល់ទៅឲ្យកម្មាភិបាលយោធាជាន់ខ្ពស់ថា ត្រូវតែជម្រុះចោល "សមាសភាពមិនល្អ"ពីក្នុងកងរបស់ខ្លួន ហើយឃុំខ្លួនសមាសភាពមិនល្អនៅក្នុងកន្លែងផ្សេងៗគ្នា ។*

*សភាពការណ៍នេះកើតឡើងនៅពេលដែលមជ្ឈិមបក្សធ្វើផែនការយុទ្ធសាស្ត្ររបស់បក្សជាលម្អិត ។ សេចក្តីព្រាងផែនការនេះត្រូវបានយកមកពិចារណាពីខែកក្កដាដល់ខែសីហាបីសប្តាហ៍ក្រោយមក ប៉ុល ពត បានពន្យល់នៅក្នុងកិច្ចប្រជុំមួយ ។ អង្គប្រជុំបានស្នើភូមិភាគ តំបន់ និងអង្គការផ្សេងៗ ឲ្យផ្តល់យោបល់ទៅអង្គប្រជុំមជ្ឈិមបក្សនៅក្នុងខែកញ្ញាដែលរៀបចំឡើងដើម្បីដាក់ចេញនូវផែនការនេះ ។*

## ៥) ផែនការរបស់បក្សក្នុងការកសាងសង្គមនិយម

*ផែនការ៤ឆ្នាំ (១៩៧៧-១៩៨០) របស់បក្សដើម្បីកសាងសង្គមនិយមលើគ្រប់វិស័យទាំងអស់ មានមូលដ្ឋាននៅលើគោលការណ៍ប្រាំ ពោលគឺ "ចំណុចយុទ្ធសាស្ត្រ" របស់បក្សកុម្មុយនិស្តកម្ពុជា÷*

*១) ឯករាជ្យភាព មានជំនាញ ពឹងពាក់លើខ្លួនឯងនិងគ្រប់គ្រងលើជោគវាសនាប្រទេសដោយខ្លួនឯង ។*

*២) ស្នេហាបដិវត្តន៍និងមោទកភាពបដិវត្តរបស់ជាតិ របស់ប្រជាជន និងបក្ស ។*

*៣) ជឿជាក់យ៉ាងពេញលេញទៅលើបក្ស បដិវត្តន៍ កសិករ កម្មករ និងកងកម្លាំងប្រដាប់អាវុធបដិវត្ត ។*

*៤) បង្កើនចលនាបដិវត្តប្រជាជនជាមួយនឹងល្បឿនមហាលោតផ្លោះមហាអស្ចារ្យ ។*

*៥) ជានិច្ចកាលត្រូវតែសន្សំសំចៃ បង្កើននិងស្វែងរកគំនិតថ្មីដើម្បីជ័យជម្នះ និងឆ្ពោះទៅមុខយ៉ាងស្វាហាប់ ។ ប្រើទុនរបស់ជាតិតិច តែផលិតបានច្រើនហើយមានគុណភាព ។*

*គោលបំណងនៃផែនការនេះគឺដើម្បីធ្វើទំនើបកម្មវិស័យកសិកម្មដែលអន់ថយក្នុងរយៈពេលពី៥ទៅ១០ឆ្នាំ និងដើម្បីប្រែក្លាយប្រទេសកម្ពុជាឲ្យក្លាយទៅជាប្រទេសឧស្សាហកម្មក្នុងរយៈពេលពី១៥ទៅ២០ឆ្នាំ ។ កសិកម្មទំនើបមានន័យថា ទទួលផលស្រូវបានខ្ពស់ពី១០ទៅ១១តោនក្នុងមួយហិកតាដោយពុំចាំបាច់ប្រើប្រាស់គ្រឿងម៉ាស៊ីន ។*

*កម្ពុជាប្រជាធិបតេយ្យនឹងមិនទទួលយកជំនួយពីប្រទេសខាងក្រៅណាមួយទេ ដោយសារតែយល់ថាជំនួយអាចធ្វើឲ្យខូចខ្សែបន្ទាត់នយោបាយរបស់បក្ស ។ បក្សបានទទួលយកជំនួយរបស់ប្រទេសចិនខ្លះដែរ ប៉ុន្តែមិនច្រើនប៉ុន្មានទេបើប្រៀបធៀបទៅនឹងប្រទេសផ្សេងៗទៀតដែលទទួលជំនួយពីចិនដូចគ្នា ។ បក្សមិនស្នើសុំជំនួយពីសូវៀតទេ ដោយនិយាយថាៈ "វៀតណាមអង្វរសុំជំនួយពីសូវៀត យើងមិនធ្វើតាមវៀតណាមទេ ។ ប្រសិនបើយើងសុំជំនួយពីសូវៀតតិចឬច្រើន សូវៀតប្រាកដជាដាក់លក្ខខណ្ឌនយោបាយជាមួយយើងជាមិនខាន" ។*

*ត្រូវតែមានផែនការមួយជាចាំបាច់ ពីព្រោះថាបើមិនដូច្នោះទេ កម្មាភិបាលនឹងមិនដឹងថាត្រូវធ្វើអ្វីខ្លះនោះទេ "ធ្វើនេះបន្តិច ធ្វើនោះបន្តិច មិនច្បាស់ថាធ្វើអ្វីខ្លះ" ។ ប្រសិនបើមានផែនការមួយច្បាស់លាស់ កម្មាភិបាលនឹងដឹងថាតើត្រូវទិញអ្វីខ្លះ ហើយទិញប៉ុន្មាន ។*

*បក្សកុម្មុយនិស្តកម្ពុជាបានសិក្សាអំពីផែនការរបស់ប្រទេសសង្គមនិយមមួយចំនួន ប៉ុន្តែមិនសូវយល់ប៉ុន្មានទេ ព្រោះផែនការទាំងនោះសរសេរទុកសម្រាប់ឲ្យអ្នកជំនាញសេដ្ឋកិច្ចមើល ។ មេដឹកនាំបក្សមិនបានគិតថាតើខ្លួនអាចធ្វើបានប៉ុន្មានភាគរយនៃផែនការនោះទេ។ មេដឹកនាំបក្សត្រូវការផែនការមួយដែលជ្រួតជ្រាបរហ័សទៅក្នុងចំណោមប្រជាជននិងកងទ័ព ដោយសារតែខ្លួនយល់ថា "ការកសាងសង្គមនិយមគួរតែធ្វើបន្តិចម្តងៗទៅក្នុងចំណោមប្រជាជន" ដែល "មានភាពពុះកញ្ជ្រោលនៅក្នុងចិត្ត ហើយបន្ទាប់មកប្រជាជននឹងអាចធ្វើឲ្យអ្វីៗដែលនៅជុំវិញខ្លួនញ័ររញ្ជួយដោយល្បឿនមហាលោតផ្លោះមហាអស្ចារ្យ" ។ មេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាបានជ្រើសរើសយកផ្លូវដើរដោយខ្លួនឯង ។ ប៉ុល ពត បាននិយាយថា "កុំជឿជាក់លើគោល*

នយោបាយពីបរទេស» ។ បក្សកុម្មុយនិស្តកម្ពុជាមិនដូចជាបក្សកុម្មុយនិស្តដទៃទៀតទេ មិនដូចជាប្រទេសចិនដែលទើបតែចាប់ផ្តើមអនុវត្តគោលនយោបាយសមូហភាពនៅឆ្នាំ១៩៥៥ ហើយក៏មិនដូចប្រទេសកូរ៉េខាងជើងដែលមិនបានបង្កើតសហករណ៍រហូតដល់ឆ្នាំ១៩៥៨ដែរ ។ ចរិតរបស់បក្សកុម្មុយនិស្តកម្ពុជាគឺផ្សេងពីនេះ ។ បក្សកុម្មុយនិស្តកម្ពុជាបានដើរលឿនជាងបដិវត្តសង្គមនិយមដទៃទៀតពី៤ទៅ១០ឆ្នាំ ។ ប៉ុល ពត បាននិយាយដោយលើកឡើងអំពីសេចក្តីសម្រេចនៅខែតុលាឆ្នាំ១៩៧០ ក្នុងការដណ្តើមយកជ័យជម្នះឲ្យបានឆាប់រហ័ស ហើយបក្សកុម្មុយនិស្តកម្ពុជាក៏ធ្វើបានមែន ។ ការអភិវឌ្ឍប្រទេសជាតិក៏ដូចគ្នាដែរ ។

ប្រទេសសង្គមនិយមជាច្រើនដូចជាចិននិងកូរ៉េខាងជើងបានអនុញ្ញាតឲ្យមានកម្មសិទ្ធិឯកជនខ្លះៗ និងមានការចាយវាយលុយកាក់ ។ ផ្នែកឯកជននិងមូលធនកំពុងតែរីកចម្រើននៅទីនោះ ។ បក្សកុម្មុយនិស្តកម្ពុជាបានរៀបចំអនុវត្តសមូហភាពនិយមយ៉ាងដាច់ខាតដោយមិនឲ្យមានស្លាកស្នាមមូលធននិយមណាមួយទេ ។ «ស្លាកស្នាមនេះរួមជាមួយនឹងទស្សនៈមូលធននិយមអាចនាំមកនូវគ្រោះថ្នាក់ដល់ប្រព័ន្ធសមូហភាពនិយមនិងប្រព័ន្ធសង្គមនិយមសម្រាប់រយៈពេលខ្លីឬវែង ដោយសារសង្គ្រាម ឬដោយសន្តិវិធី» ។ ប្រសិនបើយើងមានប្រាក់មួយលានរៀល យើងនឹងប្រើប្រាស់ប្រាក់ទាំងអស់ដើម្បីកសាងនិងការពារប្រទេសយើង ។ ប្រសិនបើប្រទេសមូលធននិយមមានប្រាក់មួយលានរៀលវិញ ប្រទេសនោះនឹងចំណាយពាក់កណ្តាលនៃប្រាក់នេះលើបៀវត្សរ៍ ហើយនៅសល់ប្រាក់តែពាក់កណ្តាលប៉ុណ្ណោះសម្រាប់កសាងនិងការពារប្រទេសជាតិ ។ ប៉ុល ពត បានពន្យល់ថា ការណ៍នេះនាំឲ្យយើងមានប្រាក់កន្លះលានរៀលច្រើនជាងមូលធននិយម ។ ប្រសិនបើមានប្រាក់ខែ មនុស្សគិតតែចំណាយប្រាក់នេះទៅលើម្ហូបអាហារទិញសម្លៀកបំពាក់ ។ល ។ ហើយសកម្មភាពនេះនឹងនាំឲ្យមានអំពើពុករលួយ ។ បក្សកុម្មុយនិស្តកម្ពុជានឹងមិនធ្វើដូច្នេះទេ ។ ប៉ុល ពត បន្ថែមថា កម្ពុជាគួរតែមានប្រព័ន្ធសមូហភាពមួយដូច្នេះចក្រពត្តិនិយមនឹងមិនអាចជ្រៀតចូលប្រទេសយើងបានឡើយ ។ ហេតុដូច្នេះហើយយើងត្រូវហូបរួមគ្នា ។ បក្សកុម្មុយ-និស្តកម្ពុជានឹងមិនប្រើប្រាស់បុគ្គលិកដែលមានអាយុច្រើនទេព្រោះថា «ប្រសិនបើមិនបានជ្រើសរើសនិងបណ្តុះបុគ្គលិកជាមុនទេ អាចនាំឲ្យមានបញ្ហាស្មុគស្មាញផ្នែកនយោបាយដែលអាច


មណ្ឌលខុក្រិដ្ឋកម្មប្រល័យពូជសាសន៍ ខេត្តស្វាយរៀង

បន្តការលំបាកផ្សេងៗសម្រាប់យើង» ។

ត្រូវតែបង្កើនកម្រិតជីវភាពរស់នៅឲ្យបានឆាប់រហ័ស ព្រោះថាកម្ពុជាប្រជាធិបតេយ្យកំពុងតែត្រូវសត្រូវនៅភូមិភាគបូព៌ានិងបស្ចិមធ្វើទុក្ខបុកម្នេញ ។ ជាពិសេសនៅភូមិភាគបូព៌ា បក្សបានខិតខំស្រាវជ្រាវរកដើម្បីបំបែកបំបាក់សត្រូវទាំងនេះ ប៉ុន្តែមិនបានទទួលជ័យជម្នះទេ ដោយសារតែសត្រូវមានកម្លាំងខ្លាំងហើយកម្លាំងកងទ័ពរបស់បក្សមិនគ្រប់គ្រាន់ ។ ប្រសិនបើបក្សអាចដោះស្រាយបញ្ហាជីវភាពរបស់ប្រជាជនបានឆាប់រហ័ស នោះកេរ្តិ៍ឈ្មោះរបស់កម្ពុជាប្រជាធិបតេយ្យនឹងល្បីសុសសាយទៅលើពិភពលោក ។

### ក) យុទ្ធសាស្ត្រជាមូលដ្ឋានក្នុងការនាំចេញ

កសិកម្មជាផ្នែកសំខាន់បំផុតនៅក្នុងផែនការរបស់បក្ស ។ នៅក្នុងផែនការដែលវាយអង្គុលីលេខចំនួន១១០ទំព័រមាន៦៥ទំព័រនិយាយអំពីបញ្ហាកសិកម្ម ចំណែកឯបញ្ហាផ្សេងៗទៀតនិយាយដោយសង្ខេបៗតែប៉ុណ្ណោះ ។ យុទ្ធសាស្ត្រដែលសរសេរនៅក្នុងផែនការនោះគឺ ការឧបត្ថម្ភជាថវិកាដល់ការអភិវឌ្ឍនិងការនាំចេញផលិតផលកសិកម្ម ។ ២៩ភាគរយនៃផលិតផលស្រូវត្រូវនាំចេញទៅក្រៅប្រទេស ។ ផែនការដែលបានកំណត់អំពីបរិមាណនៃការនាំចេញនិងចំណូលដែលរកបានគឺ÷

◆ឆ្នាំ១៩៧៧ នាំចេញអង្ករ ១.៣០៤.៨០០តោន ចំណូល ២៧៧,៦៨លានដុល្លារអាមេរិក

◆ឆ្នាំ១៩៧៨ នាំចេញអង្ករ ១.៦២៨.៩០០តោន ចំណូល ៣២៥,១០លានដុល្លារអាមេរិក

◆ឆ្នាំ១៩៧៩ នាំចេញអង្ករ ១.៨៤៨.៨០០តោន ចំណូល ៣៦៨,៧០លានដុល្លារអាមេរិក

◆ឆ្នាំ១៩៨០ នាំចេញអង្ករ ២.១២៨.៩០០តោន ចំណូល ៤២៤,១០លានដុល្លារអាមេរិក

នេះជាការកើនឡើងយ៉ាងសម្បើម ។ កាលពីឆ្នាំ១៩៦៥ កម្ពុជានាំស្រូវចេញតែ៤៩ម៉ឺនតោនប៉ុណ្ណោះ ។ នៅក្នុងផែនការ៤ឆ្នាំ ការនាំកៅស៊ូចេញនឹងកើនឡើង ហើយរកចំណូលបាន៧០លានដុល្លារអាមេរិក ដែលត្រូវជា៩ភាគរយនៃចំណូលសរុបបានពីវិស័យនាំចេញ ។ សូម្បីតែប្រទេសអាណានិគមនិយមក៏ចង់ទិញកៅស៊ូរបស់បក្សកុម្មុយនិស្តកម្ពុជាដែរ ។ ការដាំដើមក្រចៅនឹងត្រូវពង្រីកបន្ថែម ព្រោះក្រចៅត្រូវបានប្រើសម្រាប់ធ្វើជាបាវប្រចកស្រូវ ។ នៅឆ្នាំ១៩៧៧ តាមផែនការនាំស្រូវចេញវាងពី៨សែនតោនទៅ១លានតោន ហើយនឹងត្រូវការបាវចំនួនពី៨លានទៅ១០លានបាវ ។ ត្រីទឹកប្រៃ បង្កង និងក្តាមសមុទ្រ នឹងអាចរកបាន១៥លាន៥សែនបាត (ប្រាក់ថៃ) នៅឆ្នាំ១៩៨០ ។ ប្រភេទសត្វខ្លះនឹងត្រៀមទុកសម្រាប់តែនាំចេញប៉ុណ្ណោះ ។ ប៉ុល ពត បាននិយាយថា «យើងអាចហូបត្រីផ្សេងទៀត» ។ ត្រីក៏ត្រូវបានយកមកផលិតជាជីសម្រាប់នាំចេញដែរ ហើយប្រហែលជាអាចរកចំណូលបានដល់ទៅរាប់លានដុល្លារឯណោះ ។ ប្រភពផ្សេងៗទៀតដែលផ្តល់ចំណូលក្នុងវិស័យនាំចេញមានដូចជា ពោត សណ្តែកសៀង ត្រី និងផលិតផលព្រៃឈើ ។ ដូងទុកសម្រាប់នាំចេញទៅក្រៅប្រទេស ដូច្នេះប្រជាជនត្រូវផលិតសាប៊ូចេញពីជ័រដែលបានមកពីដើមកៅស៊ូ ។ ផ្លែឈើដែលមិននាំចេញ ត្រូវផ្តល់ឲ្យប្រជាជននិងភ្ញៀវទេសចរណ៍ ។ ផែនការប្រចាំឆ្នាំអំពីប្រភេទទំនិញត្រូវបានរៀបចំសម្រាប់ពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស ។

### ខ) នយោបាយមហាលោតផ្លោះមហាអស្ចារ្យ

ដើម្បីសម្រេចការនាំចេញស្រូវចេញឲ្យបានតាមផែនការ ផលិតកម្មត្រូវបានបង្កើនពី២,៥លានតោននៅមុនសង្គ្រាមទៅ៥,៥៥៥លានតោននៅក្នុងឆ្នាំ១៩៧៧ និង៧,៧៤២លានតោននៅឆ្នាំ១៩៨០ ។ ទិន្នផលត្រូវតែបង្កើនឲ្យបានលើសមុនចំនួនបីដងគឺពី១,០៧ទៅ៣តោនក្នុងមួយហិកតា ។ «បីតោន» គឺជានយោបាយមហាលោតផ្លោះមហាអស្ចារ្យ ។ ការធ្វើស្រែពីរដងក្នុងមួយឆ្នាំត្រូវបានបង្កើនដល់៣៧ភាគរយនៃផ្ទៃដីទាំងអស់នៅឆ្នាំ១៩៨០ ។ បក្សបានដាក់ផែនការដល់ភូមិភាគបូព៌ា និរតី ឧត្តរ និងបស្ចិម ក្នុងភូមិភាគនីមួយៗត្រូវផ្តល់ស្រូវ២០ភាគរយនៃបរិមាណស្រូវដែលគិតថាសល់ពីការប្រើប្រាស់ប្រគល់ឲ្យរដ្ឋ ។ ដោយឡែក មិនមានតួលេខអំពីផលិតផលដែលភូមិភាគពាយ័ព្យត្រូវប្រគល់ជូនរដ្ឋទេ ប៉ុន្តែបើតាម ប៉ុល ពត រដ្ឋនឹងយកពាក់កណ្តាលនៃផលិតផលនៅក្នុងភូមិភាគនេះ ។

បញ្ហាដែលសំខាន់នោះគឺបញ្ហាទឹក ។ បញ្ហានេះត្រូវបាន

ដោះស្រាយដោយការកសាងទំនប់ទឹក ប្រឡាយ អាងស្តុកទឹកនិងដំឡើងម៉ាស៊ីនបូមទឹក ។ បញ្ហាផ្សេងទៀតនោះគឺជី ថ្នាំសម្លាប់សត្វល្អិត និងគ្រាប់ពូជ ។ កម្ពុជាប្រជាធិបតេយ្យមិនប្រើប្រាស់ជីគីមីទេ ។ ការស្រាវជ្រាវនឹងត្រូវរៀបចំដើម្បីរកមើលគ្រាប់ពូជដែលអាចផ្តល់ទិន្នផលខ្ពស់ ។

ផែនការហាក់ដូចជាកំណត់ចំនួនសត្វពាហនៈទាប ពោលគឺ ២សែន៣ម៉ឺនក្បាលនៅឆ្នាំ១៩៧៧ និង៥សែន២ពាន់ក្បាលនៅឆ្នាំ១៩៨០ ។ នៅឆ្នាំ១៩៧០សត្វពាហនៈមានចំនួន៣លានក្បាល ហើយនៅឆ្នាំ១៩៧៩នៅសល់តែ៧សែន៥ម៉ឺនក្បាល ។ ចំពោះត្រីទឹកសាប ប្រហុក ទឹកត្រី និងអាហារដែលធ្វើអំពីសាច់ត្រី ត្រូវបានកំណត់ជាបរិមាណជាក់លាក់ រីឯត្រីទឹកប្រៃត្រូវបានកំណត់ជាចំនួនទឹកប្រាក់តែម្តង ។

**ក) ឧស្សាហូបនីយកម្ម**

បក្សបានកំណត់នូវទិសដៅសម្រាប់ឧស្សាហូបនីយកម្មដូចតទៅ ÷

- សម្រេចឲ្យបាននូវឯករាជ្យភាព
- បម្រើជីវភាពរបស់ប្រជាជន
- អភិវឌ្ឍន៍ឧបករណ៍កសិកម្ម

ឧស្សាហកម្មអគ្គិសនីត្រូវធ្វើមុនបង្អស់ ។ ប្រទេសសង្គមនិយមផ្សេងៗដែលបានចាប់ផ្តើមដោយឧស្សាហកម្មធុនធ្ងន់តែម្តង ក្រោយមកត្រូវបង្ខំចិត្តត្រឡប់ទៅរកឧស្សាហកម្មអគ្គិសនីនិងកសិកម្មវិញ ។ បក្សកុម្មុយនិស្តកម្ពុជាត្រូវតែ “ដើរលើជើងទាំងពីរ” ព្រោះថា បើមិនអភិវឌ្ឍឧស្សាហកម្មធុនធ្ងន់ទេ កម្ពុជាប្រជាធិបតេយ្យត្រូវតែ“ពឹងផ្អែកលើបរទេស” ប៉ុន្តែបើមិនអភិវឌ្ឍឧស្សាហកម្មអគ្គិសនីទេ ជីវភាពរបស់ប្រជាជនត្រូវតែពឹងផ្អែកលើវិស័យផ្សេងទៀត ។

ក៏ប៉ុន្តែ ផែនការនេះបានបែងចែកពេលវេលាជាច្រើនទៅឲ្យឧស្សាហកម្មធុនធ្ងន់ ដោយបញ្ជាក់ថា ឧស្សាហកម្មនេះត្រូវបម្រើឲ្យវិស័យកសិកម្មដូចជា ម៉ាស៊ីនបូមទឹក ម៉ាស៊ីនបោកនិងកិនស្រូវ ត្រាក់ទ័រ និងម៉ាស៊ីនអារឈើ ហើយផែនការនេះបានកំណត់ទិសដៅសម្រាប់រយៈពេល៤ឆ្នាំ ។ ឧស្សាហកម្មដែកត្រូវតែពន្យារពេលដោយសារបក្សខ្វះទុននិងមិនទាន់មានអ្នកជំនាញបច្ចេកទេសផ្នែកនេះនៅឡើយ ។ នៅឆ្នាំ១៩៧៧ បក្សមានគម្រោងទិញចង្ក្រានរំលាយដែកមួយពីបរទេសដែលអាចមានសមត្ថភាពផលិតដែកបានពី៥ពាន់ទៅ១ម៉ឺនតោនមិនឲ្យហួសពីឆ្នាំ១៩៧៩-៨០ ។ ប៉ុល ពត បានពន្យល់ថា បក្សត្រូវការផលិតដែកដែលមិនឆ្អុតដើម្បីផលិតជាសម្ភារផ្សេងៗ ។ ប៉ុល ពត បាននិយាយទៀតថា កម្ពុជាប្រជាធិបតេយ្យនឹងផលិតត្រាក់ទ័រដោយខ្លួនឯងឲ្យបានក្នុងរយៈពេល៤ឬ៥ឆ្នាំ (កាលពីឆ្នាំ១៩៧៧ បក្សកុម្មុយនិស្តកម្ពុជាបានដាក់ផែនការនេះម្តងរួចហើយ) ។ បន្ទាប់មកទៀត កម្ពុជាពិតជាអាចផលិតអាវុធបានដោយខ្លួនឯងជាមិនខាន ។ ផែនការបានដាក់ថា បក្សត្រូវតែនាំដែកចូល ប៉ុន្តែ ប៉ុល ពត បាននិយាយថា មិនចាំបាច់ទេ ព្រោះបើធ្វើដូច្នេះវាមិនមែនជាការគ្រប់គ្រងខ្លួនឯងនោះទេ ។ កម្ពុជាប្រជាធិបតេយ្យអាចប្រើដែកចាស់ៗដែលនៅសល់ ។ មានរ៉ែដែកដល់ទៅ៦លានតោននៅក្នុងប្រទេស ហើយបក្សបម្រុងនឹងស្រាវជ្រាវរកត្បូងថ្មនិងរ៉ែដែកបន្ថែមទៀត ។ ផែនការសរសេរថា “បើមានរ៉ែ យើងនឹងរកវា” ។ ចំនួននេះប្រហែលជាសំដៅទៅរ៉ែដែក៥លានតោននៅខេត្តកំពង់ធំ ។ ផែនការមិនបាននិយាយសោះអំពីរ៉ែផូស្វាតនិងត្បូងដែលត្រូវបានប្រើប្រាស់តាំងពីមុនពេលមានសង្គ្រាម ។

ឧស្សាហកម្មគីមីនឹងផលិតសារធាតុគីមីសម្រាប់ប្រើប្រាស់ក្នុងការរំលាយដែកនិងកសិកម្ម ។ នៅឆ្នាំ១៩៧៩ បក្សមានគម្រោងនាំចូលម៉ាស៊ីនផលិតម្សៅដេដេតេ ។ ផលិតកម្មអំបិលត្រូវតែបង្កើនដោយសារតែអំបិលមានសារសំខាន់សម្រាប់អាហារ សម្រាប់ធ្វើប្រហុក និងសម្រាប់ផលិតសារធាតុពាវម៉្យាងដែលប្រើប្រាស់សម្រាប់ផលិតសាប៊ូនិងក្រដាស ។ ឱសថអាចត្រូវបានផលិតតាមវិធីសាស្ត្រទំនើបនិងបុរាណ ។ ផលិតថ្នាំពេទ្យទំនើបដោយប្រើប្រាស់សម្ភារក្នុងស្រុកមិនចោទជាបញ្ហាទេ ប៉ុន្តែម៉ាស៊ីននិងវត្ថុធាតុដើមត្រូវតែនាំចូល ។ ថវិកាអតិបរមា៤,៥លានដុល្លារអាមេរិកអាចត្រូវប្រើប្រាស់ក្នុងការផលិតថ្នាំការពារជំងឺគ្រុនចាញ់ ។

អំពីបញ្ហាថាមពលអគ្គិសនី ផែនការបានដាក់ថា កម្ពុជាប្រជាធិបតេយ្យត្រូវតែមានថាមពលអគ្គិសនីដែលដើរដោយប្រេងឆៅនិងត្បូងចំនួនពី៥ម៉ឺនទៅ៦ម៉ឺនគីឡូវ៉ាត់ម៉ោង ។ បក្ស

នឹងស្រាវជ្រាវរកកន្លែងដែលអាចសាងសង់វារីអគ្គិសនីមួយដែលអាចផលិតបានអគ្គិសនីពី១ម៉ឺនទៅ៣ម៉ឺនគីឡូវ៉ាត់ម៉ោង ។ ការជួសជុលនឹងត្រូវធ្វើជាបន្តនៅឯរោងចក្រស្លប្រេងកាតនៅកំពង់សោម ហើយបក្សនឹងស្រាវជ្រាវរកប្រេង ជាពិសេសនៅក្នុងសមុទ្រ ។ ប្រេងគ្រប់ប្រភេទនឹងត្រូវបូមយកដើម្បីផលិតឲ្យបាន៦សែនតោនប្រេងដែលជាតម្រូវការសម្រាប់ដំណើការរបស់រោងចក្រ ។

គមនាគមន៍នឹងបម្រើឲ្យការកសាងសង្គមនិយមលើវិស័យកសិកម្មនិងឧស្សាហកម្ម ពាណិជ្ជកម្មក្នុងនិងក្រៅប្រទេស និងជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជន ។ កំពង់ផែកំពង់សោមត្រូវតែពង្រីកបន្ថែមទៀតដើម្បីឲ្យកប៉ាល់របស់បរទេសអាចចូលចតបាន ។ ផែនការសរសេរថា មុនដំបូងកំពង់ផែនេះទទួលតែកប៉ាល់ដែលមកតែពីប្រទេសជាមិត្តប៉ុណ្ណោះ មួយរយៈក្រោយមកទៀតទើបទទួលកប៉ាល់ដែលមកពីប្រទេសមូលធនផ្សេងៗ ។ ត្រូវពង្រីកកំពង់ផែសមុទ្រនិងបំពាក់ដោយម៉ាស៊ីនបូមទឹក ម៉ាស៊ីនស្ទូច ម៉ាស៊ីនលើកដាក់ឥវ៉ាន់ ម៉ាស៊ីនសម្រាប់សាងសង់ ឃ្លាំងស្តុកឥវ៉ាន់ បទបញ្ជាគយ ពោង ឧបករណ៍ស្ទង់អាកាសធាតុ វិទ្យុ ទឹកភ្លើង ។ល ។ ផែនការបានសរសេរបន្ថែមទៀតថា «ត្រូវតែថែរក្សានិងកែលម្អផ្លូវទឹក» ។ កម្ពុជាប្រជាធិបតេយ្យត្រូវការទូកម៉ាស៊ីនធំៗសម្រាប់ដឹកស្រូវនិងកៅស៊ូចេញទៅក្រៅប្រទេស ។ ប៉ុល ពត បាននិយាយថា «យើងត្រូវការឲ្យកងទ័ពជាអ្នកធ្វើទូកទាំងនេះ» ។ កម្ពុជាប្រជាធិបតេយ្យគ្មានកប៉ាល់ដែលអាចធ្វើដំណើរទៅសមុទ្របានទេ ប៉ុន្តែអាចផលិតទូកនេសាទតូចៗបានយ៉ាងងាយស្រួល ។ ទូកដែលចរាចរនៅលើទន្លេនិងបឹងមានសារសំខាន់ខ្លាំងណាស់សម្រាប់បម្រើឲ្យការដឹកជញ្ជូនទំនិញ ប៉ុន្តែត្រូវតែប្រើប្រាស់ឲ្យមានប្រសិទ្ធភាពជាងមុន ។ ជួនកាលទូកទាំងនេះវិលត្រលប់មកវិញដោយមិនមានដឹកទំនិញសោះ ។ ប៉ុល ពត បាននិយាយថា «បើនៅតែបែបនេះយើងនឹងខាតបង់រាប់លានដុល្លារជារៀងរាល់ឆ្នាំ» ។

សមត្ថភាពរបស់ផ្លូវដែកក៏ត្រូវតែបង្កើន ហើយផ្លូវដែកមួយថ្មីពីភ្នំពេញទៅកំពង់សោមនឹងត្រូវសាងសង់បន្ថែម ។ ផ្លូវដែកនេះនឹងត្រូវទិញពីបរទេសនៅក្នុងតម្លៃ៤០លានដុល្លារ ។ តម្លៃសរុបជិតដល់១០០លានដុល្លារឯណោះ ប៉ុន្តែផ្លូវនេះគឺសម្រាប់បម្រើឲ្យមូលហេតុនយោបាយ សេដ្ឋកិច្ច និងយោធាក្រៅពីផ្លូវទឹកតាមទន្លេមេគង្គ ។ ផ្លូវទាំងអស់ត្រូវតែជួសជុលឲ្យហើយមិនឲ្យហួសពីឆ្នាំ១៩៨០ ហើយជាបឋមត្រូវតែរៀបចំផ្លូវយុទ្ធសាស្ត្រ ។ វិស័យទូរគមនាគមន៍និងសេវាកម្មផ្ញើសំបុត្រត្រូវតែជួសជុលឡើងវិញ ជាពិសេសនៅទីក្រុងភ្នំពេញ ។ យន្តហោះនិងអ្នកបើកបរយន្តហោះត្រូវតែរៀបចំយ៉ាងណាឲ្យរួចរាល់ដើម្បីអាចបម្រើការហោះហើរក្នុងស្រុកបានចាប់ពីឆ្នាំ១៩៧៨តទៅ ជាពិសេសផ្លូវភ្នំពេញ-សៀមរាប ។ ជើងហោះហើរក្រៅប្រទេសក៏ត្រូវបានត្រៀមដែរ ព្រោះថាវិស័យទេសចរណ៍មានសារសំខាន់ណាស់សម្រាប់ការផ្សព្វផ្សាយឥទ្ធិពលនយោបាយរបស់បក្ស ។

## ឃ) ការអភិវឌ្ឍវិស័យបច្ចេកវិជ្ជា វប្បធម៌ និងសង្គម

បក្សកុម្មុយនិស្តកម្ពុជាបានជ្រើសរើសយកការរៀនបច្ចេកវិជ្ជាដោយការអនុវត្តផ្ទាល់តែម្តង ដើម្បីកុំឲ្យបក្សដទៃអាចលូកដៃចូលដែលនាំឲ្យបាត់បង់ឯករាជ្យភាពរបស់បក្ស ។ ប៉ុល ពត បាននិយាយថា បើយើងឲ្យមនុស្សទៅរៀនពីប្រទេសផ្សេងនោះនឹងនាំឲ្យមានគ្រោះថ្នាក់ដល់បក្ស ។ សតិអារម្មណ៍នយោបាយគឺជាកត្តាកំណត់ ។ ប៉ុល ពត និយាយថា «អ្នកបើកបរយន្តហោះរបស់យើងមិនចេះអក្សរប៉ុន្មានទេ ប៉ុន្តែដោយការបណ្តុះសតិអារម្មណ៍នយោបាយ យើងទាំងអស់គ្នាអាចរៀនបានយ៉ាងឆាប់រហ័ស» ។ ការបញ្ជាវ៉ាដាអាចរៀនចេះតែក្នុងរយៈពេលពីរឬបីខែប៉ុណ្ណោះ ។

ប្រព័ន្ធអប់រំមួយនឹងត្រូវបានរៀបចំឡើងពីឆ្នាំ១៩៧៧ ដោយចំណាយរយៈពេល៣ឆ្នាំសម្រាប់បឋមសិក្សា ៦ឆ្នាំសម្រាប់មធ្យមសិក្សា និង៣ឆ្នាំសម្រាប់ការអប់រំកម្រិតទីបី ពោលគឺសិក្សាអំពីបច្ចេកទេសដែលក្នុងនោះសិស្សរៀនពាក់កណ្តាលធ្វើការងារពាក់កណ្តាល ។ សិស្សត្រូវតែសិក្សាអំពីស្រូវនិងធញ្ញជាតិផ្សេងៗ កៅស៊ូនិងដំណាំឧស្សាហកម្ម ព្រៃឈើនិងដើមឈើហូបផ្លែ ការបន្តពូជសត្វ ត្រីទឹកសាបនិងទឹកប្រៃ ទឹកទន្លេនិងទឹកសមុទ្រ ថាមពល ថ្នាំ ។ល ។ ត្រូវតែមានសាលាពហុបច្ចេកវិជ្ជាដោយបែងចែកឲ្យមានការអនុវត្តកម្រិតបឋមនិងមធ្យម ។

វប្បធម៌ អក្សរសាស្ត្រ និងសិល្បៈ របស់ចក្រពត្តិនិយម

អាណានិគមនិយមនិងរបស់វណ្ណៈជិះជាន់ ត្រូវតែលុបបំបាត់ចោលទាំងអស់ ។ វប្បធម៌ អក្សរសាស្ត្រ និងសិល្បៈ របស់បដិវត្តន៍ ត្រូវតែលើកតម្កើង ជាពិសេសបទចម្រៀងនិងកំណាព្យដែលឆ្លុះបញ្ចាំងអំពីគំរូល្អ ។

ផែនការបក្សបានបង្ហាញពីភាពចាំបាច់ក្នុងការបង្កើនសេវាសុខភាព និងបង្កើនជីវភាពរស់នៅ ដើម្បីពង្រឹងកម្លាំងប្រជាពលរដ្ឋដែលអាចនាំទៅដល់ការបង្កើនកម្លាំងនិងសតិអារម្មណ៍នយោបាយ ។ ការបង្កើនសេវានេះត្រូវតែធ្វើឡើងនៅក្នុងរង្វង់នៃប្រព័ន្ធសមូហភាពមួយ ដើម្បីចៀសវាងកុំឲ្យមានកម្មសិទ្ធិឯកជននិងមូលធននិយមម្តងទៀត ។

មធ្យមភាគនៃការប្រើប្រាស់ស្រូវប្រចាំឆ្នាំត្រូវបានកំណត់១៣ថាំងឬ៣១២គីឡូក្រាម (កន្លះគីឡូក្រាមអង្ករក្នុងមួយថ្ងៃ) ។ របបអាហារប្រចាំថ្ងៃគឺ៣កំប៉ុងសម្រាប់កម្លាំងទីមួយ ២កំប៉ុងកន្លះសម្រាប់កម្លាំងទីពីរ ២កំប៉ុងសម្រាប់កម្លាំងទីបី និង១កំប៉ុងកន្លះសម្រាប់កម្លាំងទីបួន (១កំប៉ុងស្មើ២០០ឬ២៥០ក្រាម) ។ មុនពេលមានសង្គ្រាម ប្រជាជនកម្ពុជាម្នាក់ត្រូវការអង្ករជាមធ្យមពី៥០០ក្រាមទៅ៦០០ក្រាមក្នុងមួយថ្ងៃ ។ ប្រជាជនត្រូវការបរិភោគសាច់ច្រើនជាងនេះពីរដង ត្រីពីរដង និងត្រីងៀតបីដងក្នុងមួយសប្តាហ៍ ។ ផែនការសរសេរទៀតថា ចាប់ពីឆ្នាំ១៩៧៨ នឹងត្រូវមានបង្អែមបន្ថែមទៀត ។ អាហារត្រូវតែមានរសជាតិឆ្ងាញ់ ព្រោះថា បើប្រជាជនបរិភោគមិនឆ្អែតនិងមិនពេញចិត្តចំពោះរបបសមូហភាព ប្រជាជននឹងងាកទៅរកផ្លូវមូលធនជាមិនខាន ។

ចាប់ពីឆ្នាំ១៩៧៧ រៀងរាល់ដប់ថ្ងៃនឹងមានថ្ងៃឈប់សម្រាកមួយថ្ងៃ ។ ពេលវេលាខ្លះនឹងត្រូវបានលៃលកសម្រាប់បើកអង្គប្រជុំជីវភាព រៀនសូត្រនយោបាយ និងកសាងសតិអារម្មណ៍ ។

ភូមិរបស់កសិករនិងកម្មករនឹងមានផ្ទះស្អាតសមរម្យសម្រាប់ក្រុមគ្រួសារនីមួយៗ ។ មិនគួររុះរើផ្ទះចាស់ចោលមុនពេលដែលផ្ទះថ្មីសាងសង់រួចនោះទេ ។

មានផែនការពង្រីកមន្ទីរពេទ្យនិងបង្កើនចំនួនបុគ្គលិកពេទ្យ ។ ជំងឺគ្រុនចាញ់នឹងត្រូវកាត់បន្ថយឲ្យបានពី៧០ភាគរយ ទៅ១០០ភាគរយនៅឆ្នាំ១៩៨០ ។ ប៉ុល ពត បាននិយាយថា មានការពិភាក្សាគ្នាអំពីចំនួនវេជ្ជបណ្ឌិតដែលមានចំនួនតិចហើយមិនសូវមានគុណភាព ។ ចំនួនវេជ្ជបណ្ឌិតនឹងត្រូវបង្កើន ។ «វេជ្ជបណ្ឌិតត្រូវតែរៀនអំពីគោលការណ៍វេជ្ជសាស្ត្រដូចជារបៀបវិភាគសាកសពជាដើម» ។

មជ្ឈមណ្ឌលថែរក្សាកុមារនឹងត្រូវបង្កើតនៅក្នុងសហករណ៍ រោងចក្រ ការិយាល័យ ក្រសួង និងអង្គភាពទ័ព ដើម្បីថែរក្សា អប់រំ និងណែនាំ កុមារក្នុងការបង្កើនផលិតកម្ម ។ នឹងមានមជ្ឈមណ្ឌលថែរក្សាមនុស្សចាស់និងជនពិការដើម្បីឲ្យគាត់អាចចូលរួមនៅក្នុងផលិតកម្មស្រាលៗ ។

## ៥) តើផែនការនេះបានជោគជ័យឬទេ?

ផែនការបានសរសេរថា ប្រទេសកម្ពុជាមានធនធានធម្មជាតិដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងដី សត្វ និងទឹក ។ ដង់ស៊ីតេប្រជាជនមានលក្ខណៈអំណោយផលជាងប្រទេសចិន វៀតណាម និងកូរ៉េខាងជើង ។ ធនធានទឹកក៏អំណោយផលជាងប្រទេសទាំងនោះដែរ ។

ផ្ទុយទៅវិញ ប្រទេសនេះមានផលវិបាកខ្លះៗដោយសារ



មិនសូវមានឧស្សាហកម្ម និងគ្មានឧស្សាហកម្មធុនធ្ងន់ ។ ប្រទេសកម្ពុជាក៏គ្មានធនធានរ៉ែនិងអគ្គិសនីដែរ ។ ឧស្សាហកម្មធុនស្រាលពឹងផ្អែកទៅលើវត្ថុធាតុដើមពីបរទេស ។ បច្ចេកវិជ្ជាក៏ទន់ខ្សោយ ។ បើប្រៀបធៀបទៅនឹងប្រទេសផ្សេងៗ កម្ពុជាទន់ខ្សោយណាស់ខាងផ្នែកឧស្សាហកម្ម ។ ក៏ប៉ុន្តែ នេះមិនមែនជាកត្តាដាច់ខាតនោះទេ ។ ផែនការបានសង្កត់ធ្ងន់ថាៈ «កត្តាកំណត់របស់បដិវត្តន៍គឺនយោបាយ ប្រជាជនបដិវត្ត និងវិធីសាស្ត្របដិវត្ត» ។ កត្តាសំខាន់បំផុតគឺបក្សដ៏ខ្លាំងក្លាមួយ ។ បក្សទាំងមូលត្រូវតែប្រឹងប្រែងដើម្បីបំពេញផែនការនេះ ។ ដោយសារអង្គការបក្សតាមភូមិភាគនិងតំបន់រឹងមាំ កម្លាំងរបស់ប្រជាជននឹងកើនឡើងជាមិនខាន ។

នឹងមានបញ្ជាដាក់ចេញទៅទូទាំងប្រទេស ក្នុងនោះចេញពីថ្នាក់ភូមិភាគ តំបន់ ស្រុក កងផលិតកម្ម និងសហករណ៍ ។ តាមរយៈនេះ បក្សនឹងមានក្បាលម៉ាស៊ីនដឹកនាំដើម្បីសម្រេចផែនការ ។ ប៉ុល ពត បាននិយាយថា «យើងត្រូវតែគោរពបញ្ជាឲ្យបានត្រឹមត្រូវ ។ បើមិនដូច្នោះទេ ធនធានទាំងប៉ុន្មាននឹងវិនាសអស់ជាមិនខាន» ។

ប្រជាជនត្រូវតែជឿជាក់លើផែនការរបស់បក្ស និងត្រូវសាមគ្គីគ្នា ព្រោះបើមិនមានសាមគ្គី ផែនការប្រទេសមិនអាចជឿនលឿនទៅមុខទេ ហើយអ្វីៗទាំងអស់នឹងបរាជ័យ ។ ប៉ុល ពត និយាយទៀតថា «កុំបណ្តោយឲ្យការលំបាកដែលអ្នកជួបប្រទះធ្វើឲ្យអ្នកនិយាយថា ទាំងនេះគឺដោយសារតែផែនការដាក់ឲ្យអនុវត្តប្រញាប់ប្រញាល់ពេក» ។ បញ្ហាតែមួយគត់នោះគឺគំនិតផ្ទុយគ្នានៅក្នុងបក្ស ។ ប៉ុន្តែ កម្មាភិបាលភាគច្រើនជាមនុស្សល្អ ហើយបក្សនឹងជ្រើសរើសអ្នកដែលអាចបម្រើចលនាបដិវត្តន៍បាន ។ ជាកត្តាបន្ទាប់បន្សំ កម្ពុជាប្រជាធិបតេយ្យត្រូវការមិត្តភក្តិបរទេស ជាពិសេសនៅក្នុងផ្នែកនយោបាយនិងសតិអារម្មណ៍ ។ សត្រូវនឹងមិនហ៊ានវាយប្រហារកម្ពុជាទេ ដោយសារតែខ្លាចការរិះគន់របស់ពិភពលោក ។

## ២) ការសង្កេតខ្លះៗ

ផែនការរបស់បក្សហាក់បីដូចជាត្រូវបានរៀបចំដោយប្រញាប់ប្រញាល់ពេក ដោយមិនមានព័ត៌មានគ្រប់គ្រាន់អំពីស្ថានភាព ។ ប៉ុល ពត បាននិយាយថាបក្សត្រូវការតារាង បញ្ជីនិងតួលេខ ដើម្បីមើលថាតើអ្វីដែលបានសរសេរនៅក្នុងផែនការត្រូវឬខុស និងត្រូវការផែនទីមួយដើម្បីមើលប្រភេទដីរបស់តំបន់និងស្រុកនានា ។ ប៉ុល ពត ក៏បានស្នើសុំតួលេខដើម្បីដឹងឲ្យច្បាស់ថាតើសត្វសម្រាប់យកសាច់ជាអាហារនិងសត្វសម្រាប់ប្រើប្រាស់ក្នុងការងារធ្ងន់មានចំនួនប៉ុន្មាន ។ ប៉ុល ពត បាននិយាយទៀតថា «នៅពេលដែលយើងដឹងពីតួលេខ យើងអាចរៀបចំផែនការបាន» ។ ក៏ប៉ុន្តែ ផែនការបានសរសេររួចទៅហើយអំពីចំនួនសត្វសម្រាប់យកសាច់ជាអាហារនិងសត្វសម្រាប់ប្រើប្រាស់ក្នុងការងារធ្ងន់ដែលត្រូវមានសម្រាប់ឆ្នាំនីមួយៗ ។

អត្រាកំណើនមិនអាចគណនាបានទេ ពីព្រោះតួលេខទាំងអស់គឺជាទិសដៅទៅអនាគតប៉ុណ្ណោះ ហើយមិនធ្លាប់មានតួលេខពីឆ្នាំមុនៗមកទេ ។ គ្មានការយោងទៅរកទិន្នន័យនៅមុនពេលមានសង្គ្រាមទេ ។ **(នៅមានត)**

**ម៉ុង សាន់ឃ្មីស**



# ការិយាល័យពត៌មានសាធារណៈ

«ការិយាល័យពត៌មានសាធារណៈ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យពត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ពត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យពត៌មានសាធារណៈ» មានផ្តល់ជូននូវសេវា៤យ៉ាងៈ

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជានិងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

**៤) ហាងកាហ្វេ** ៖ មជ្ឈមណ្ឌលយើងខ្ញុំមានហាងកាហ្វេសម្រាប់បម្រើសេវាភេសជ្ជៈនិងចំណីអាហារជូនលោកអ្នក ។

ភាពយន្តឯកសារអំពីខ្មែរក្រហម មានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។


វគ្គបណ្តុះបណ្តាលច្បាប់អន្តរជាតិ នៅការិយាល័យពត៌មានសាធារណៈ

ការិយាល័យពត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជ័យ សុភារម្យ ឬ រ័ត្ន ដារា ពិដោរ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# រសាយចិត្តទៅតាមពេលវេលា

នៅក្នុងឃុំបន្ទាយដែក ខេត្តកណ្តាល ក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទៅរកគ្រួសារមួយដែលមានជីវភាពមធ្យម ។ បងស្រីម្ចាស់ផ្ទះបាននាំយើងទៅជួបអ៊ីប្រុសម្នាក់ឈ្មោះ អ៊ុក សែម ដែលកំពុងសម្រាន្តនៅលើគ្រែក្រោមម្លប់ស្វាយក្រោយផ្ទះ ។ អ៊ីសែម បានងើបមកទទួលយើងយ៉ាងរាក់ទាក់ ។ បន្ទាប់ពីយើងជម្រាបគាត់អំពីគោលបំណងក្នុងការមករកគាត់ អ៊ីសែម បានប្រាប់ថាគាត់ពេញចិត្តនឹងកិច្ចការរបស់យើងណាស់ ពីព្រោះគាត់ស្គាល់មជ្ឈមណ្ឌលកម្ពុជាតាមរយៈការតាមដានស្តាប់វិទ្យុរាល់ថ្ងៃ ។


អ៊ុក សែម

បច្ចុប្បន្ន អ៊ីសែម មានអាយុ ៧៤ឆ្នាំនិងរស់នៅជាមួយកូនៗ ។ គាត់មើលថែរក្សាផ្ទះសម្បែងនិងចៅៗខណៈដែលកូនៗរបស់គាត់ចេញទៅរកស៊ី ។ អ៊ីសែម ជាគ្រូបង្រៀនម្នាក់តាំងពីសម័យសង្គមរាស្ត្រនិយម ។ បច្ចុប្បន្ន អ៊ីចូលនិវត្តន៍ហើយ ។ អ៊ីសែម ប្រាប់ថា គាត់មិនមែនជាអ្នកស្រុកនេះទេ ស្រុកកំណើតរបស់អ៊ីនៅខេត្តស្វាយរៀងឯណោះ ។ អ៊ីបានចាកចេញពីស្រុកកំណើតតាំងពីអាយុ៦ឆ្នាំមករស់នៅនិងបួសរៀននៅក្នុងខេត្តកណ្តាល ។ អ៊ីបានយកវត្តអារាមធ្វើជាទីពឹងក្នុងការស្នាក់អាស្រ័យនិងសិក្សារៀនសូត្រ ។ បន្ទាប់ពីប្រឡងជាប់វិញ្ញាបនប័ត្របឋមសិក្សានៅឆ្នាំ១៩៥០ អ៊ីបានបន្តសិក្សានៅភ្នំពេញនិងបានធ្វើជាគ្រូបង្រៀននៅឆ្នាំ១៩៥៣ ។ កាលណោះអ៊ីត្រូវបានចាត់តាំងឲ្យទៅបង្រៀននៅខេត្តស្វាយរៀង ។ នៅឆ្នាំ១៩៥៤ អ៊ីបានផ្លាស់មកបង្រៀននៅវត្តអរិយក្សត្រនៅខេត្តកណ្តាលរហូតដល់ឆ្នាំ១៩៥៧ ទើបផ្លាស់ទៅបង្រៀននៅឃុំបន្ទាយដែក ។ ឆ្នាំ១៩៦២ អ៊ីបានចេញពីសាលាបន្ទាយដែកមកនៅសាលាខ្សុំបិតនៅក្នុងភូមិដែលអ៊ីរស់នៅសព្វថ្ងៃ ។

នៅចុងឆ្នាំ១៩៧២ ខ្មែរក្រហមវាយផ្តាច់ផ្លូវជាតិលេខមួយមិនឲ្យមានទំនាក់ទំនងមកភ្នំពេញ ។ ពេលនោះខ្មែរក្រហមបានកៀរប្រជាជនជាងមួយម៉ឺននាក់ឲ្យទៅរស់នៅស្រុកកោះធំ ។

នៅស្រុកកោះធំ ខ្មែរក្រហមបានស្រង់ប្រវត្តិរូបប្រជាជនម្តងម្នាក់ៗដោយប្រាប់ប្រជាជនថា "សូមបងប្អូនឆ្លើយឲ្យត្រង់ពីព្រោះយើងរកមើលតើអ្នកណាមួយជាសក្តិភូមិ ។ យើងស្អប់ណាស់សក្តិភូមិ យើងស្អប់ណាស់ពួកមូលធន ។ ដូច្នេះយើងត្រូវវាយកម្ទេចឲ្យរាបស្មើ បក្សយើងធ្វើឲ្យមានភាពស្មើគ្នា កុំឲ្យមានការជិះជាន់" ។ អ៊ីសែម បានឆ្លើយប្រាប់ដោយត្រង់ថា គាត់ជាគ្រូបង្រៀន ។ តាំងពីនោះមក ខ្មែរក្រហមចេះតែមកបញ្ចុះបញ្ចូលជាញឹកញាប់ឲ្យអ៊ីចូលបម្រើបដិវត្តន៍ ប៉ុន្តែអ៊ីចេះតែលើកយកបញ្ហាជីវភាពជាលេសថា "មិត្តអើយខ្ញុំមានកូនច្រើនណាស់ ជីវភាពក្រណាស់ មិត្តមើលខ្ញុំវេទនាខ្លាំងណាស់ ។ ចាំមើលទៅមុខជីវភាពខ្ញុំធូរខ្ញុំចូលបម្រើហើយ ខ្ញុំបាទមិនស្អប់អង្គការទេ ព្រោះតែខ្ញុំស្រឡាញ់អង្គការហើយបានជាខ្ញុំប្រឹងគេចពីពួក លន់ ណុល" ។ ក្រោយមកទៀត ខ្មែរក្រហមបានមកសុំកូនប្រុសរបស់អ៊ីទៅធ្វើជាយោធាម្តង ប៉ុន្តែអ៊ីរកល្បិចដោះសារបន្តទៀត ពីព្រោះអ៊ីមិនចង់ឲ្យកូនៗធ្វើបដិវត្តន៍ទេ ។ អ៊ីសែម បានប្រាប់ឲ្យដឹងថា "បើគេបង្ខំថីមិនបាន ប៉ុន្តែគេមិនបង្ខំយើង ។ ទីមួយយើងកូនគ្រូបង្រៀន ទីពីរ គេថាអាហ្នឹងគំនិតវានៅសក្តិភូមិ ដូច្នេះកុំបង្ខំវា ជួនកាលទៅវាអត់ស្មោះត្រង់នឹងយើង ទៅក៏ទៅមិនទៅក៏ហី ។ បើកូនកម្មករសុទ្ធគេយកទៅហើយ គេហៅថាប្រវត្តិរូបស្អាតស្អំ ។ កូនរាស្ត្រយកខ្មេច ពួសខ្លះកំបុតក ខ្លះបែកក្បាល ខ្លះដាច់ដៃដាច់ជើង ងាប់ខ្មេច" ។

នៅតំបន់រំដោះក្នុងស្រុកកោះធំ ខ្មែរក្រហមបានបែងចែកប្រជាជនជម្លៀសខ្លះឲ្យរស់នៅតាមផ្ទះជាមួយប្រជាជនមូលដ្ឋានខ្លះទៀតឲ្យសង់ខ្ទមថ្មីដើម្បីស្នាក់នៅបណ្តោះអាសន្ន ។ ពីមួយថ្ងៃទៅមួយថ្ងៃ វិន័យរបស់ខ្មែរក្រហមកាន់តែតឹងតែងឡើងៗក្រោមការគ្រប់គ្រងរបស់គណៈស្រុកកោះធំឈ្មោះ សុខ ប៉ិតចំរើន និង ហួត សេ ។ មុនដំបូងស្រុកកោះធំនៅចាយលុយនៅឡើយទេ ។

អ៊ឹសែម ប្រកបមុខរបរដួញដូរស្រូវពីស្រុកនៅសៅរ៉ា អន្លង់ត្រសេក និងខេត្តតាកែវ ដើម្បីបានអង្ករយកមកលក់ឲ្យកងទ័ពយៀកកុង ដែលរស់នៅក្បែរផ្ទះរបស់គាត់ ។ ចំណែកប្រពន្ធនិងកូនរបស់គាត់ ទូលបបរលក់តាមផ្ទះ ។ លុះមួយរយៈពេលក្រោយមក ខ្មែរក្រហម បានហាមប្រាមមិនឲ្យលក់អង្ករឲ្យយៀកកុងទៀត ប៉ុន្តែអ៊ឹសែម នៅតែលួចលាក់លក់បានបន្តិចបន្តួចដើម្បីដោះស្រាយជីវភាពគ្រួសារ ។

៦ខែបន្ទាប់ពីថ្ងៃជ័យជម្នះ១៧មេសា ១៩៧៥ អង្គការ បានដឹកអ៊ឹសែមនិងក្រុមគ្រួសារវិលត្រឡប់មកផ្ទះនៅភូមិខ្សុំវិញ ។ កូនៗរបស់អ៊ឹត្រូវបញ្ជូនទៅក្នុងកងយុវជននិងអង្គភាពកុមារដេញ ទា ។ ចំណែកអ៊ឹនិងប្រពន្ធនៅរែកដីនិងដឹកព្រែក ហូបបាយរួមនៅ សហករណ៍ភូមិ ។

អ៊ឹសែម បានឲ្យដឹងទៀតថា នៅភូមិរបស់គាត់មានប្រជាជនរស់នៅចម្រុះគ្នា ខ្លះមកពីភ្នំពេញ(ប្រជាជន១៧មេសា) មាន សាស្ត្រាចារ្យ គ្រូបង្រៀន ទាហានស័ក្តិ៣-ស័ក្តិបួន និងវេជ្ជបណ្ឌិត ។ ខ្មែរក្រហមនិយាយថា «យើងនឹងកម្ចាត់អាពួកសក្តិភូមិជិះជាន់ ពួករាជការធំៗឲ្យតែថា យើញពួកអាគិញអីហ្នឹងយកឲ្យអស់» ។ ប្រជាជនដែលជម្លៀសពីភ្នំពេញជាច្រើននាក់បានស្លាប់ដោយ ចាញ់បោកការឃោសនារបស់អង្គការដែលថានរណាធ្វើការនៅ ក្រសួងណាអនុញ្ញាតឲ្យទៅធ្វើការនៅកន្លែងដដែលវិញ ។ អ្នកខ្លះ ពាក់ស័ក្តិមួយឬគ្មានបុណ្យស័ក្តិសោះ ប៉ុន្តែប្រាប់ខ្មែរក្រហមថា ស័ក្តិបី ស័ក្តិបួន ព្រោះចង់បានតំណែងធំ ។ ទីបំផុតអ្នកទាំងនោះ ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោលអស់ ។ អ្នកខ្លះទៀតស្លាប់ ដោយសារខ្វះអាហារ អ៊ឹសែម បាននិយាយថា ខ្មែរក្រហមមក យកមនុស្សម្តងពីរបីនាក់ទៅបាត់ៗ ដោយគ្រាន់តែនិយាយថា ទៅកាប់ឫស្សីយកមកធ្វើក្បូនដឹកក្រួស ឬទៅលើកទំនប់ប្រឡាយ នៅកន្លែងនេះកន្លែងនោះ ប៉ុន្តែអ្នកទាំងនោះមិនដែលឃើញ ត្រឡប់មកវិញឡើយ ។ ប្អូនថ្លៃរបស់គាត់ម្នាក់ដែលធ្វើទាហាន ត្រូវអង្គការប្រាប់ថាឲ្យទៅដឹកក្រួសនៅកោះទីយូ ហើយក៏បាត់ខ្លួន តាំងពីពេលនោះរហូតមក ។ ចំណែកប្រពន្ធកូនត្រូវអង្គការយក ទៅតាមក្រោយ ។

នៅថ្ងៃមួយក្នុងឆ្នាំ១៩៧៧ ក្រោយពេលដែល អ៊ឹសែម ត្រឡប់មកពីដឹកពោតវិញ ឈ្លបម្នាក់បានដើរមកប្រាប់គាត់ឲ្យទៅ យកចេកហូបនៅឯមន្ទីរ ។ អ៊ឹសែមសប្បាយចិត្តណាស់ព្រោះថាមាន ចេកហូប ។ គ្រាន់តែទៅដល់មន្ទីរភ្លាម គាត់ត្រូវឈ្លបនៅទីនោះ ចាប់ចងស្លាបសេក ។ ខណៈនោះអ៊ឹក៏ឃើញមនុស្សម្នាក់ទៀតត្រូវ ចងស្លាបសេកមុនគាត់ទៅទៀត ។ អ៊ឹសែម រៀបរាប់ថា «កាលណោះ ប្រសិនបើខ្ញុំដឹងមុន មិនដឹងជាខ្ញុំតក់ស្លុតប៉ុនណាទេ ។ ខ្ញុំឮតែគេឲ្យ ចេក ខ្ញុំអរក៏ចូលទៅគេបង្ហាញថាចេកនៅខាងណោះ ខ្ញុំដើរទិនៗ ទៅយកចេក គេក៏ស្ទុះភ្លែតពីក្រោយចាប់ជាប់ ដល់អ៊ឹចឹងគេថា ហុចដៃៗចងស្លាបសេក ។ ដល់ចងហើយគេថាកុំមាត់នៅឲ្យស្ងៀម ។ មួយយប់គេបញ្ឈរកង ខ្ញុំគេឲ្យអង្គុយនៅពីក្រោយគេយកទៅដាក់ គុកនៅគគីរ» ។ ធ្វើដំណើរបានពាក់កណ្តាលផ្លូវ ឈ្លបទាំងពីរនោះ ឈប់កង់ហើយចុះទៅជិតគ្នាឆ្ងាយពីកង់ ។ ឆ្លៀតឱកាសនោះ អ៊ឹសែម បានព្យាយាមទាញយកកាតគ្រូចេញពីហោប៉ៅទាំងដៃជាប់ចំណង មកទំពារខ្ទេចរហូតដល់មើលមិនស្គាល់ថាជារបស់អ្វី ។

ប្រហែលម៉ោង៧ ឈ្លបបាននាំអ៊ឹមកដាក់នៅផ្ទះមួយដោយ ដាក់ខ្នោះជើងជាប់ជាមួយនឹងបុរសពិការជើងម្នាក់ទៀតដែល ត្រូវចោទថាជាទាហានស័ក្តិពីរ ប៉ុន្តែបុរសម្នាក់នោះប្រាប់អ៊ឹសែម ថាគាត់ជាព្រូឡានទេ ។ ពីរថ្ងៃក្រោយមក ខ្មែរក្រហមដឹកអ៊ឹទៅ ដាក់នៅមន្ទីរលត់ដំវត្តចំពុះក្អែក ។

តាមផ្លូវប្រកបូលខាងស្តាំដៃទៅកាន់វត្តចំពុះក្អែក អ៊ឹបាន ឃើញអ្នកទោសប្រហែល៣០-៤០នាក់ដែលមានរូបរាងកាយ ស្គមកំព្រឹង សក់វែងត្រឹមក ធ្វើឲ្យអ៊ឹនឹកភ្នកដល់ជោគវាសនាខ្លួន ទៅថ្ងៃមុខនឹងដូចអ្នកទាំងនោះពុំខាន ។ បន្ទាប់មកកងឈ្លបក៏បាន នាំអ៊ឹទៅជួបឆ្មាំគុកម្នាក់ដើម្បីបង្ហាញលិខិតស្នាម ។ ឆ្មាំគុកសម្លឹង មុខអ៊ឹសែមយ៉ាងមាំ រួចរុញអ៊ឹបញ្ចូលទៅក្នុងគុក ដាក់ខ្នោះដៃខ្នោះ ជើងជាប់ ។ នៅក្នុងគុក អ៊ឹបានឃើញអ្នកទោសខ្លះមានរូបកាយ ស្គមៗ ខ្លះទៀតហូរលាមកសុទ្ធតែឈាម និងខ្លះដេកស្លាប់ហើម ពីរបីថ្ងៃហើយនៅតែមិនទាន់មាននរណាអើពើយកចេញ ។ ឆ្មាំគុក បានឲ្យអ៊ឹបោចស្មៅ ធ្វើបង្គី និងដឹកព្រែក ហើយត្រូវចូលរួមស្តាប់ ការប្រជុំរបស់មេគុកពីរដងក្នុងមួយសប្តាហ៍ ។ នៅក្នុងអំឡុងពេល អ៊ឹសែម ជាប់គុក គាត់បានឃើញឆ្មាំគុកធ្វើសកម្មភាពគ្រប់ បែបយ៉ាងមកលើអ្នកទោស ។ អ្នកទោសត្រូវឆ្មាំគុកនាំចូលមកក្នុង គុកនេះជាបន្តបន្ទាប់ ។ នៅពេលគុកចង្អៀត ឆ្មាំគុកយកបញ្ជីមក

ហៅឈ្មោះអ្នកទោសចេញទៅម្តង ហើយដាក់អ្នកទោសថ្មីៗចូលមកវិញ ។ ឆ្មាំទាំងនោះបានប្រាប់អ្នកទោសដែលត្រូវហៅឈ្មោះចេញក្រៅថា យកទៅកសាងអប់រំដើម្បីដោះលែងឲ្យទៅជួបប្រពន្ធកូនវិញ ប៉ុន្តែអ្នកទោសទាំងនោះពុំមានសំណាងដូចការគិតទេ ។ អ្នកទោសទាំងអស់ត្រូវដឹកទៅតាមទូកយកទៅសម្លាប់នៅកោះគរ ខ្លះត្រូវធាក់ទម្លាក់ទឹកកណ្តាលទន្លេក៏មាន ។ អ្នកទោសខ្លះទៀតត្រូវដឹកតាមរថយន្តទាហានយកទៅសម្លាប់ ។ អ្នកទោសម្នាក់ដែលមានរូបកាយស្គមស្គាំង ត្រូវឈ្លបចងផ្តោបនឹងគល់ដូងពីលើសំបុកស្រមោចទុកឲ្យស្រមោចខាំ ។

អ៊ឹសែម រៀបរាប់ទៀតថា ថ្ងៃមួយពេលដែល អ៊ឹសែម កំពុងធ្វើការនៅការដ្ឋានបឹងស្នោ ស្ត្រីម្នាក់ទឹកកូនពេកបានលួចរត់ ស្រាប់តែឈ្លបឆ្មាំគុករត់ដេញតាមពីក្រោយទាន់ ហើយវាយស្ត្រីនោះនឹងចបជីកចំពីក្រោយ ។ ស្ត្រីនោះមុខឡើងលឿងមួយរំពេច ហើយក៏ដួលផ្កាប់មុខក្បាលធ្លាក់ចូលក្នុងប្រឡាយ ។ ចំណែកស្ត្រីម្នាក់ទៀតឈ្មោះ ខុម បានលួចទៅរើសគ្រាប់ពោតដែលជ្រុះនៅលើថ្នល់ក្នុងពេលកំពុងចែករបបបបរ ស្រាប់តែមេគុកឈ្មោះ ថ្វាង ញោញធ្មេញដាក់ ហើយបញ្ជាឲ្យកងឈ្លបយកចង្វាទូកមកវាយស្ត្រីនោះរហូតដល់ស្លាប់ ។

ថ្ងៃមួយទៀត ពេលកំពុងធ្វើការនៅស្រែ អ៊ឹសែម បានឃើញនិស្សិតដែលទើបមកពីបរទេសចំនួនពីរឡានត្រូវអង្គការបញ្ជូនមកឲ្យគាស់គល់រាំងនិងដាំស្ពៃ ។ អ៊ឹសស្ញើតខ្លាំងណាស់ព្រោះឃើញនិស្សិតទាំងនោះមានរូបរាងស្អាតបាត ក្រចកដៃវែងៗបែរជាមកធ្វើការបែបនេះ ។ អ៊ឹសែម បានឃើញមេដឹកនាំខ្មែរក្រហមមួយចំនួនដូចជា ខៀវ សំផន, តាជ័យ, តាម៉ុក និងយាយបូគណៈស្រុកតំបន់២៥ ចុះមកសួរសុខទុក្ខប្រជាជនដែរ ។ ខៀវ សំផន បានសួរប្រជាជនថា «តើហូបចុកគ្រប់គ្រាន់ដែរឬទេ?» ប្រជាជនឆ្លើយថា «បានហូបឆ្អែតគ្រប់គ្រាន់ និងមានបង្អែមមួយអាទិត្យពីរដង» ។ អ៊ឹសែម បន្ថែមថា ជាក់ស្តែងប្រជាជនមិនដែលបានហូបឆ្អែតទេ ប៉ុន្តែបើមិននិយាយដូច្នេះទេ «មេកងនៅក្បែរហ្នឹង មេដែលត្រួតយើងហ្នឹង គិតថាហូបមិនឆ្អែតហ្នឹងបាត់ទៀតហើយ ។ ម្យ៉ាងទៀតយើងខ្លាចខ្លួនយើង យើងថាតាមវិទ្យុប្រកាសក្តែងៗថា បាយហូបឆ្អែត មួយអាទិត្យមានបង្អែមពីរដង។ ចំណែក តាម៉ុក និងយាយបូ ចុះមកគ្រាន់តែមកសួរថា ម៉េចមិត្តយើងធ្វើការបានលឿនទេ ហូបឆ្អែតទេ ៗ គ្រប់គ្នាចេះតែឆ្លើយបាទៗ ទៅ» ។

មកដល់ចុងឆ្នាំ១៩៧៨ នៅក្នុងគុកសល់តែអ៊ឹសែម និងអ្នកទោសប្អូននាក់ទៀតប៉ុណ្ណោះ ។ អ៊ឹសែម និយាយថា គាត់ទាំងប្រាំនាក់លែងមានសង្ឃឹមថាបានវិលត្រឡប់មកជួបប្រពន្ធកូនទៀតហើយ ក៏នាំគ្នាហួចច្រៀងលេងយ៉ាងសប្បាយ ព្រោះគិតថាសប្បាយផ្តាំស្លាប់ ។ ស្រាប់តែពេលនោះមេគុកឈ្មោះ ថ្វាង ស្រែកពីក្រៅគុកថា «ម៉េចមិនគិតរកពាក្យនិយាយជាមួយអង្គការទេ គិតតែនាំគ្នាសប្បាយ ។ ម៉េចដឹងខ្លួនទេ គេឲ្យមកនៅហ្នឹងដើម្បីរកវិធីដោះស្រាយជាមួយអង្គការ ។ អង្គការមិនមែនចិត្តអាក្រក់ទេ អង្គការនឹងដោះលែងមិត្តឲ្យទៅសហករណ៍វិញហើយ» ។

ប្រាំពីរថ្ងៃក្រោយមក គឺនៅខែវិច្ឆិកា ឆ្នាំ១៩៧៨ អ៊ឹសែម និងអ្នកទោសម្នាក់ទៀតដែលត្រូវជាកូនសិស្សរបស់អ៊ឹដែរ ត្រូវបានដោះលែងពីគុក ។ ឆ្មាំគុកបានប្រាប់គាត់ថា «ដោយសារមិត្តឯងធ្វើការបានល្អ កសាងខ្លួនបានល្អចំពោះបក្សបានគួរឲ្យចាប់អារម្មណ៍ ដូច្នេះបក្សយល់ឃើញថាមិត្តឯងស្មោះត្រង់ហ្នឹងបក្ស ។ ដូច្នេះបក្សនឹងលើកលែងទោសឲ្យ តែរួចម្នាក់គឺរួចទាំងអស់រហូតដល់កូនទៀត ៗ» អ៊ឹសែម ចេញពីគុកបានតែម្ភៃថ្ងៃប៉ុណ្ណោះ របបកម្ពុជាប្រជាធិបតេយ្យក៏ដួលរលំ ។

អ៊ឹសែម ពិតជាខឹងខ្មែរក្រហមណាស់ដែលបានធ្វើបាបនិងសម្លាប់បងប្អូនរបស់គាត់ ប៉ុន្តែមកដល់បច្ចុប្បន្ននេះ កំហឹងទាំងអស់នេះស្ទើរតែរសាយអស់ពីអារម្មណ៍របស់គាត់ទៅហើយ ។ ទោះជាយ៉ាងណាអ៊ឹចង់ឲ្យប្រជាជនកម្ពុជាទាំងអ្នកស្លាប់និងអ្នកដែលនៅរស់រានមានជីវិតទទួលបានយុត្តិធម៌ពីអ្វីដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ អ៊ឹសែម និយាយថា «កាលចេញដំបូងខឹងណាស់ ដែលគេធ្វើបាបខ្ញុំហ្នឹង បងប្អូនខ្ញុំហ្នឹងងាប់ច្រើនណាស់ មួយពូជអស់ជាងម្ភៃនាក់ នៅសល់តែខ្ញុំពីរបីនាក់ ។ ដល់ឥឡូវហួសលែងចង់ខឹងហើយ ប៉ុន្តែរដ្ឋគេធ្វើម៉េចស្រេចតែគេទៅ យើងវាបានជាហួសទៅហើយ ។ បើគេបង្កើតតុលាការអត់មានជំទាស់ទេ ។ ដើម្បីឲ្យឃើញការពិតផង ។ វាអស់ចិត្តអ្នកដែលមានបងប្អូនស្លាប់ ហ្នឹងកុំឲ្យថាស្លាប់ចេះតែស្លាប់ទៅអ៊ីចឹង ។ ដើម្បីឲ្យមានសុចរិតយុត្តិធម៌ ។»

**លី សុផល**

# សម្លឹងទៅអតីតកាល


ឡុង ម៉ារី

រឿងរ៉ាវបានកន្លងទៅជាង ៣០ឆ្នាំហើយសម្រាប់ ឡុង ម៉ារី ។ ជាង៣០ឆ្នាំមុន ម៉ារី គឺជាយុទ្ធនារីខ្មែរក្រហមម្នាក់នៅក្នុងកងពល៧០៣ដែលរត់គេចពីការទម្លាក់គ្រាប់បែកនិងគ្រាប់កាំភ្លើងគ្រប់ប្រភេទ ។ ក្នុងពេលដែលខ្លួនគាត់កំពុងស្ថិតនៅក្នុងព្រឹត្តិការណ៍ទាំងនោះ ម៉ារី មិនដឹងថាហេតុការណ៍នៅពេលនោះអាក្រក់យ៉ាងណា ហើយប្រឈមមុខនិងគ្រោះថ្នាក់ខ្លាំងយ៉ាងណាទេ ។ ជាង៣០ឆ្នាំក្រោយមក ពេលដែលសម្លឹងទៅព្រឹត្តិការណ៍កាលពីអំឡុងពេលនោះវិញ ម៉ារី និយាយថា «ខ្ញុំខ្លាចណាស់ ឥឡូវខ្ញុំលែងកាំភ្លើងហើយ» ។

ម៉ារីចូលបម្រើបដិវត្តន៍នៅក្នុងឆ្នាំ១៩៧៣ តាមការបញ្ចុះបញ្ចូលរបស់កម្មាភិបាលខ្មែរក្រហម ។ ម៉ារី និយាយថា ក្រោយពីរដ្ឋប្រហារឆ្នាំ១៩៧០ មានកម្មាភិបាលខ្មែរក្រហមជាច្រើននាក់បានមកដល់ភូមិរបស់គាត់ ។ ម្នាក់ក្នុងចំណោមអ្នកទាំងនោះ ម៉ារី ស្គាល់ថាឈ្មោះ អ៊ុង រដ្ឋា ជានិរសាររបស់ ខៀវ សំផន ។ អ្នកទាំងនោះមកបង្រៀនចម្រៀងបដិវត្តន៍ដល់អ្នកភូមិ ជាពិសេសយុវជន ។ បន្ទាប់មកបានបញ្ចុះបញ្ចូលយុវជននៅក្នុងភូមិឲ្យចូលបម្រើបដិវត្តន៍ខ្មែរក្រហមដើម្បីរំដោះប្រជាជនឲ្យផុតពីភាពក្រីក្រនិងនាំប្រទេសទៅរកសង្គមមួយដែលស្អាតស្អំ ។ ដោយកាលនោះគ្មានគ្រូបង្រៀននៅតាមសាលាផង យុវជនស្ទើរតែទាំងអស់បានចូលបម្រើបដិវត្តន៍ ។ ម៉ារី និយាយថា «ពេលនោះយើងវាក្រ យើងមានសន្ទុះចិត្តមួយចង់រំដោះខ្លួនយើង ដល់ហើយក៏ស្ម័គ្រចិត្តចូលទាំងអស់តែម្តង ។ ស្រករៗខ្ញុំហ្នឹងទៅទាំងអស់មួយភូមិ» ។

ចូលបដិវត្តន៍ភ្លាម ម៉ារី នៅក្នុងកងពលលេខ១២ មាននាទីជាអ្នកវែកបាយស្មុកឲ្យយុទ្ធជនទៅសមរភូមិមុខ ។ ជារៀងរាល់ថ្ងៃ ម៉ារី វែកបាយពីស្មុករត់កាត់គ្រាប់កាំភ្លើងនិងគ្រាប់បែកដែលទម្លាក់ពីលើយន្តហោះ ។ ម៉ារី និយាយថា ពេលទម្លាក់គ្រាប់បែកម្តងៗ អ្នកដែលរត់ចូលលេណដ្ឋានមិនទាន់ត្រូវស្លាប់យ៉ាងអាណោចអាធ័ម ខ្លះដាច់ពាក់កណ្តាលខ្លួន ខ្លះលៀនភ្នែក ខ្លះត្រូវលេណដ្ឋានសង្កត់លើស្លាប់ ។ នៅឆ្នាំ១៩៧៤ ម៉ារី បានទៅហាត់រៀនបាញ់កាំភ្លើងនៅព្រែកដូង ។ ក្រោយមកគាត់ត្រូវអង្គការចាត់តាំងឲ្យកាន់កាំភ្លើងបេ-៤០ពេលប្រយុទ្ធក្នុងសមរភូមិ ។ ម៉ារី បានវាយចូលក្រុងភ្នំពេញតាមផ្លូវជាតិលេខមួយឆ្លងចូលសិត្បូ ព្រែកជ៉ាវ និងតាខ្មៅ រហូតទទួលបានជ័យជម្នះលើរបបលន់ណុល ។ នៅព្រែកជ៉ាវនេះហើយដែល ម៉ារី ឃើញយុទ្ធជនខ្មែរក្រហមស្លាប់អស់យ៉ាងច្រើន ហើយគ្មាននរណាអើពើយកសាកសពទាំងនោះទៅកប់ទេ ។

ពេលដែលអង្គការជម្លៀសប្រជាជនចេញពីទីក្រុង ម៉ារី ឈរយាមលើស្ពានមុនីវង្ស ។ ក្រោយជម្លៀសប្រជាជនចេញពីទីក្រុងអស់ហើយ កងរបស់ ម៉ារី និងយុទ្ធជនដទៃទៀតមាននាទីដើរប្រមូលទ្រព្យសម្បត្តិប្រជាជនដាក់ក្នុងឃ្លាំងរួមមួយដែលឋិតនៅពីក្រោយវាំង ។

ក្នុងមហាសន្និបាតមួយនៅពហុកីឡាដ្ឋានជាតិអូឡាំពិកនៅថ្ងៃទី២២ កក្កដា ឆ្នាំ១៩៧៥ កងពល១២ត្រូវប្តូរទៅជាកងពល៧០៣ ឋិតនៅក្រោមការគ្រប់គ្រងរបស់សេនាធិការកងទ័ពបដិវត្តន៍ ។ តួនាទីរបស់កងពល៧០៣ពេលនោះគឺការពារអង្គការថ្នាក់លើ ការពារសម្តេច សីហនុ ការពារក្រវាត់ក្រុង ជួនកាលការពារមន្ទីរស-២១ តាមចាប់ខ្លួនខ្មាំងរបស់បដិវត្តន៍ រក្សាសុវត្ថិភាពពេលមានពិធីបុណ្យផ្សេងៗ និងទទួលភ្ញៀវអន្តរជាតិនៅព្រលានយន្តហោះពោធិចិនតុង ។ ម៉ារី បាននិយាយថា កាលនោះមិនមានវត្តមានប្រជាជននៅក្នុងទីក្រុងទេ ។ ដូច្នេះដើម្បីបន្លំភ្នែកភ្ញៀវបរទេស អង្គការបានចែកអាវស ខោប្រុសំពត់ ខៀវឲ្យកងទ័ពស្លៀកពាក់ដើម្បីបន្លំធ្វើជាប្រជាជនមកទទួលគណៈប្រតិភូបរទេសដែលមកទស្សនាកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីខ្មែរក្រហមទទួលបានជ័យជម្នះ ម៉ារី ឃើញមានគណៈប្រតិភូ

បរទេសមកទស្សនាប្រទេសកម្ពុជាជាញឹកញាប់ ក្នុងនោះ ម៉ារី ក៏បានទៅទទួលសម្តេច សីហនុ យាងចូលស្រុកវិញនៅខែកញ្ញា ឆ្នាំ១៩៧៥ដែរ ។

នៅខែកញ្ញា ឆ្នាំ១៩៧៦ ម៉ារី ត្រូវបានអង្គការបញ្ជូនទៅរៀនខាងបច្ចេកទេសទូរស័ព្ទនៅប្រទេសចិន ។ ទើបតែរៀនបានរយៈពេលមួយខែ កងទ័ពចំនួនដប់នាក់ក្នុងនោះមាន ម៉ារី ផង ត្រូវបានបញ្ជូនមកស្រុកខ្មែរវិញដោយសារមានប្រវត្តិរូបមិនល្អ ។ ម៉ារី ត្រូវបានបញ្ជូនមកស្រុកខ្មែរវិញដោយសារមានជាប់ពាក់ព័ន្ធនឹងបងរបស់គាត់ដែលធ្វើការនៅភ្នំពេញកាលពីរបបលន់ណុល ។ មកដល់ភ្នំពេញភ្លាម ម៉ារី ត្រូវបញ្ជូនឲ្យមន្ទីរស-២១យ ឬមន្ទីរលត់ដំព្រៃស ។ នៅមន្ទីរព្រៃសបានចំនួនដប់ថ្ងៃ គាពីន ដែលជាគណៈកងពល៧០៣បានទៅដោះលែងម៉ារីមកវិញ ហើយឲ្យទៅធ្វើស្រែនៅព្រៃសក្នុងរូបភាពលត់ដំកម្រិតស្រាល ។

ម៉ារី និយាយថា ទាហានកងពល៧០៣ចំនួនបីរយនាក់ត្រូវបានចាត់តាំងឲ្យធ្វើស្រែនៅជើងឯក តែក្នុងរយៈពេលមិនបានមួយឆ្នាំផង ទាហានទាំងនោះនៅសល់តែប្រហែលមួយរយនាក់ប៉ុណ្ណោះ ។ អ្នកទាំងនោះត្រូវស្លាប់ដោយការសម្លាប់ផង និងដោយការបង្អត់បាយផង ។ គណៈវរៈរបស់ ម៉ារី ឈ្មោះ ម៉េត និង នី ត្រូវបានអ្នកយាមគុកព្រៃសបញ្ជាឲ្យបោចសក់គ្នាដោយនិយាយថា នរណាបោចឈ្នះនិងត្រូវដោះលែងឲ្យមានសេរីភាព ។ អ្នកទាំងពីរខំបោចសក់គ្នាទាល់តែរលើងស្បែកក្បាល តែទីបំផុតអ្នកទាំងពីរត្រូវអ្នកយាមសម្លាប់ចោលទាំងអស់ ។

នៅចុងឆ្នាំ១៩៧៧ មានដំណឹងថា កងទ័ពវៀតណាមចូលដល់ខេត្តស្វាយរៀងហើយ ។ កងពល៧០៣ត្រូវបានចាត់តាំងឲ្យទៅទប់ទល់ជាមួយកងទ័ពវៀតណាម ។ តែក្នុងរយៈពេលប្រហែលជាកន្លះខែទ័ពខ្មែរក្រហមបានដេញទ័ពវៀតណាមទៅដល់ព្រំដែនវិញ ហើយវាយលុកហួសចូលទៅក្នុងទឹកដីខេត្តតាយនិញរបស់វៀតណាមថែមទៀត ។ ពេលនោះទាហាន៧០៣ត្រូវបានកងទ័ពវៀតណាមព័ទ្ធជាប់ ។ ម៉ារី និយាយថា ពេលនោះមេបញ្ជាការបានចែកគ្រាប់បែកឲ្យយុទ្ធនារីទាំងអស់ម្នាក់មួយ ដើម្បីទុកបោកបំផ្ទុះពេលដែលកងទ័ពវៀតណាមរត់សំដៅមក ។ មានយុទ្ធនារីម្នាក់ឈ្មោះ ផុន បានបោកគ្រាប់បែកឲ្យផ្ទុះស្លាប់ខ្លួនឯងនិងទាហានវៀតណាមជាច្រើននាក់ទៀតពេលដែលខ្លួនឈឺជើងរត់មិនរួច ។ ម៉ារី សម្លឹងមើលការស្លាប់របស់ ផុន ដោយក្តីអាណោចអាធ័មនិងតក់ស្លុត ។ កងពល៧០៣បានតស៊ូប្រយុទ្ធចំនួនកន្លះខែទើបរត់មកដល់ព្រំដែនខ្មែរវិញ ។ តាំងពីពេលនោះមក កងទ័ពវៀតណាមយ៉ាងច្រើនសន្ធឹកសន្ធាប់បានចូលមកក្នុងទឹកដីខ្មែរ ហើយវាយបណ្តេញកម្ពុជាប្រជាធិបតេយ្យ ។

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យ ដួលរលំទៅ ម៉ារី បានត្រលប់មករស់នៅស្រុកកំណើតឯខេត្តកណ្តាលវិញ ។

**ញាណ សុជាតិ**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ÷

◆ វិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧:៣០-៧:៤៥ល្ងាច ។

◆ វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

◆ វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧:០០-៧:៣០ព្រឹក និងម៉ោង៦:៣០-៧:០០ល្ងាច ។

◆ វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩:០០-៩:៣០ព្រឹក និងម៉ោង៣:០០-៣:៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើងនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **លី សុផល និង សូ ហ្វារីណា**

# ការបង្កើតការទទួលខុសត្រូវសម្រាប់មេដឹកនាំខ្មែរក្រហម ចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិ

***(តពីលេខមុន)***

### ***ឃ) យុត្តាធិការតាមសំណុំរឿងដែលជាប់វិវាទ និងយុត្តាធិការលើបុគ្គល***

#### ***ឃ-១) យុត្តាធិការតាមសំណុំរឿងដែលជាប់វិវាទ***

*យុត្តាធិការតាមសំណុំរឿងដែលជាប់វិវាទនៃអង្គជំនុំជម្រះវិសាមញ្ញ បានទទួលយកការផ្លាស់ប្តូរដ៏សមហេតុផល និងគួរឲ្យទុកចិត្តបានស្តីពីការហាមប្រាមរបស់អនុសញ្ញានិងទំនៀមទម្លាប់នូវអំពើឧក្រិដ្ឋកម្មអន្តរជាតិមួយចំនួនធំដែលបំពេញបន្ថែមដោយយុត្តាធិការនៃឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតនៅក្រោមច្បាប់កម្ពុជា ។*

*ក្រៅពីតួនាទីបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ច្បាប់តុលាការក៏នឹងដាក់បញ្ចូលមួយចំណែកនូវ“ច្បាប់និងទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិនិងអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់” ទៅក្នុងច្បាប់ឧក្រិដ្ឋកម្មរបស់កម្ពុជាដែរ ។ ពីមាត្រាទី៤ ដល់ទី៦ នៃច្បាប់នេះចោទប្រកាន់ទៅលើអំពើឧក្រិដ្ឋកម្មអន្តរជាតិចំនួនបីសំខាន់ៗៈ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ទោះជាយ៉ាងណាក៏ដោយ មាត្រាទី៧ និងទី៨ បំពេញបន្ថែមលើបទល្មើសប្រឆាំងទៅនឹងអនុសញ្ញាដែលមិនសូវបានស្គាល់ គឺ“ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្នុងអំឡុងមានជម្លោះប្រដាប់អាវុធ” និង “ឧក្រិដ្ឋកម្មប្រឆាំងបុគ្គលទទួលការការពារពីអន្តរជាតិ” ។*

*អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ និងឧក្រិដ្ឋកម្មប្រឆាំងបុគ្គលទទួលការការពារពីអន្តរជាតិ ត្រូវបានកំណត់នៅក្នុងអនុសញ្ញាអន្តរជាតិរួចហើយ បើទោះជាមិនទាំងអស់ក៏ដោយ ក៏ឥឡូវនេះបានក្លាយទៅជាក្បួនច្បាប់ទំនៀមទម្លាប់របស់ច្បាប់អន្តរជាតិទៅហើយ ។ ទោះជាប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាទាំងអស់នេះបានទាន់ពេលវេលាមុនឆ្នាំ១៩៧៥ក៏ដោយ ក៏រហូតមកដល់ពេលនេះគ្មានអនុសញ្ញាណាមួយត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់ជាតិទេ ។ ទោះជាការបញ្ចូលបែបនេះមានសារសំខាន់ក្តី ក៏នៅតែមានការភ័យខ្លាចថាកម្ពុជាអាចឆក់យកឱកាសនេះ “រៀបចំ” និយមន័យពាក្យប្រល័យពូជសាសន៍ ដើម្បីនាំយកគ្រប់អំពើឧក្រិដ្ឋកម្មទាំងអស់ដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមដាក់ឲ្យស្ថិតនៅក្នុងអំពើឧក្រិដ្ឋកម្មដ៏គួរស្អប់ខ្ពើមបំផុត ។ ក្នុងន័យនេះគួរកត់សម្គាល់ដែរថា អ្នកនិពន្ធជាច្រើនយល់ស្របគ្នាថា ការប្រព្រឹត្តមកលើជនជាតិភាគតិចជាអំពើប្រល័យពូជសាសន៍ ប៉ុន្តែមានការសង្ស័យថាតើអំពើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងចំពោះប្រជាជនកម្ពុជាជាទូទៅមានន័យធំធេងជាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬទេ ប្រសិនបើអំពើនេះមានកម្រិតធ្ងន់ធ្ងររហូតដល់មានការលុបបំបាត់ក្រុមនានានៅក្នុងសង្គម ឬក្រុមនយោបាយ ដែលមិនបានទទួលការការពារដោយអនុសញ្ញាប្រល័យពូជសាសន៍ ។ រ៉ាតន័រ បានផ្តល់ទស្សនីករណ៍ថាៈ*

*“ជាក់ស្តែង បើទាញការចាប់អារម្មណ៍ខាងសីលធម៌ ការបកស្រាយផ្សេងៗគ្នាខាងផ្លូវច្បាប់នឹងពង្រីកវិសាលភាពនៃក្រុមដែលទទួលបានការការពារពីអនុសញ្ញា រួមមានក្រុមនយោបាយសង្គម ឬសេដ្ឋកិច្ច ដែលជាផ្នែកមួយនៃក្រុមជនជាតិភាគច្រើន” ។*

*រាល់ការប៉ុនប៉ងទាំងអស់ទៅលើយុត្តិធម៌“ចម្រុះ”សុទ្ធតែជាប់ពាក់ព័ន្ធទៅនឹងគ្រោះថ្នាក់នៃការជ្រៀតជ្រែកខាងនយោបាយទៅលើការកំណត់និយមន័យអំពើឧក្រិដ្ឋកម្ម ។ អាស្រ័យហេតុដូចនេះហើយសេចក្តីព្រាងអនុស្សរណៈយោគយល់បានទទូចសុំឲ្យមានការចោទប្រកាន់លើអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចដែលបានកំណត់នៅក្នុងច្បាប់អន្តរជាតិ (មាត្រាទី៨) ។ នៅទីបញ្ចប់ ច្បាប់តុលាការបានផ្សារភ្ជាប់ការចោទប្រកាន់ទៅនឹងការកំណត់និយមន័យអនុសញ្ញា ។ បន្ថែមពីនេះទៀត ដូចបានស្នើឡើងដោយក្រុមអ្នកជំនាញការការជ្រើសរើសយកឧក្រិដ្ឋកម្មណាមួយដើម្បីរាប់បញ្ចូលទៅក្នុងយុត្តាធិការតាមសំណុំរឿងដែលជាប់វិវាទត្រូវតែទុកឲ្យអង្គ*

ជំនុំជម្រះមានសេរីភាពក្នុងការចង្អុលបង្ហាញនូវរាល់អំពើឧក្រិដ្ឋទាំងអស់របស់ខ្មែរក្រហមនៅក្រោមច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។ វិធីដោះស្រាយ"តាមអនុសញ្ញា"នាំឲ្យសាលាជំនុំជម្រះក្តីកម្ពុជាមានយុត្តាធិការទូលំទូលាយជាងយុត្តាធិការដែលមានស្រាប់នៅក្នុងសាលាជំនុំជម្រះក្តីឧក្រិដ្ឋកម្មអន្តរជាតិ ដែលយុត្តាធិការតាមសំណុំរឿងដែលជាប់វិវាទត្រូវបានដាក់កម្រិតយ៉ាងមានប្រសិទ្ធភាពទៅលើ"វិធាននៃច្បាប់មនុស្សធម៌អន្តរជាតិដែលជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់" ។

ប្រភពច្បាប់ទំនៀមទម្លាប់ស្តីពីការហាមប្រាមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានធានាឲ្យមានការយកចិត្តទុកដាក់យ៉ាងពិសេសខណៈដែលនិយមន័យនៃអំពើឧក្រិដ្ឋកម្មមិនអាចយកធ្វើជាមូលដ្ឋានក្នុងអត្ថបទអន្តរជាតិជួវការណាមួយបាន ។ ជាងនេះទៅទៀត ឧក្រិដ្ឋកម្មនេះមិនត្រូវបានហាមប្រាមដោយអនុសញ្ញាអន្តរជាតិណាមួយដែលបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជាក្នុងពេលមានអំពើឧក្រិដ្ឋនេះកើតឡើងឡើយ ។ មាត្រាទី៥នៃច្បាប់នេះបានចោទប្រកាន់អំពើអមនុស្សធម៌មួយចំនួន "ដែលប្រព្រឹត្តឡើងជាផ្នែកមួយនៃការវាយប្រហាររាលដាលឬបែបប្រព័ន្ធទៅលើប្រជាជនស៊ីវិលណាម្នាក់ ដោយឈរលើមូលដ្ឋានជនជាតិ នយោបាយ ជាតិពន្ធ ជាតិសាសន៍ ឬសាសនាជាដើម" ។ ធ្វើដូច្នេះ ច្បាប់នេះបានបង្កើតបន្ថែមនូវមាត្រាទី៣នៃលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា ។ បើប្រៀបធៀបជាមួយនឹងនិយមន័យដើមដំបូងរបស់តុលាការនូរឹមប៊ឺកអត្ថបទកាលពីឆ្នាំ១៩៩៤មានការផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ចំនួនបួនៈ ១) ការមិនជាប់ពាក់ព័ន្ធទៅនឹងជម្លោះប្រដាប់អាវុធ ២) ការដាក់ជំនួសនូវតម្រូវការជួវការសម្រាប់"ការវាយប្រហាររាលដាលឬបែបប្រព័ន្ធ" ៣) ការរាប់បញ្ចូលអំពើអមនុស្សធម៌បន្ថែមទៀត (គឺមិនគ្រាន់តែការលួចធ្វើឃាត ការសម្លាប់បំផុតពូជ ការធ្វើទាសករ ការជម្លៀសចេញ និងការធ្វើទុក្ខបុកម្នេញដោយសារការរើសអើងប៉ុណ្ណោះទេ បូករួមទាំងការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម និងការរំលោភសេពសន្ថវៈ) ៤) ចេតនារើសអើងដោយឈរលើហេតុផលជនជាតិ នយោបាយ ជាតិពន្ធ ឬសាសនា ឬដោយសារមូលហេតុណាក៏ដោយ (ផ្ទុយពីលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងប្រទេសរ៉ាន់ដា) ។ ចំណុចចុងក្រោយគឺមានសារសំខាន់ ពីព្រោះថាចំណុចនេះប្រហែលជាពិបាកក្នុងការដាក់បញ្ចូលទង្វើរបស់ខ្មែរក្រហមទៅលើក្រុម"ជនជាតិខ្មែរ" ទៅក្នុងប្រភេទនៃការរើសអើងក្រុមជនជាតិ នយោបាយ ជាតិពន្ធ ឬសាសនា ។ ការលំបាកនេះត្រូវបានដោះស្រាយនៅក្នុងកិច្ចព្រមព្រៀងឆ្នាំ២០០៣ដែលចង់បាននិយមន័យពាក្យឧក្រិដ្ឋកម្មសង្គ្រាមដែលបានអនុម័តនៅក្នុងលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ។

នៅទីបញ្ចប់ មាត្រាទី២៩នៃច្បាប់នេះគោរពទាំងស្រុងទៅតាមវិធានបច្ចុប្បន្ននៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិទាក់ទងនឹងការរៀបចំគម្រោង ការញុះញង់ ការបញ្ជា ការប៉ុនប៉ង និងទម្រង់នៃការទទួលខុសត្រូវមិនផ្ទាល់ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មទាំងអស់នេះ ។ ករណីលើកលែងដ៏សំខាន់នោះគឺការលុបចោលពីមាត្រាទី៨នូវ "ការញុះញង់ដោយផ្ទាល់និងជាសាធារណៈឲ្យប្រព្រឹត្តអំពើប្រល័យពូជសាសន៍" ដែលចូលក្នុងទម្រង់នៃការសមគំនិត ឬ "ញុះញង់" ។ ការទទួលខុសត្រូវលើការបញ្ជាចំពោះអំពើរបស់អ្នកក្រោមបង្គាប់ក៏ត្រូវបានចែងដូចនៅក្នុងលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិដែរ ។ ផ្ទុយទៅវិញ ការដោះសាការពារខ្លួនថាមានបញ្ជាពីថ្នាក់លើត្រូវបានបដិសេធចោល ។

ទោះជាយ៉ាងណាក៏ដោយ យើងចាំមើលថាតើវិធានទូទៅទាំងនេះស្របទៅនឹងវិធានដែលយកមកអនុវត្តចំពោះបទឧក្រិដ្ឋកម្មដែលដកស្រង់ចេញពីក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ដែរឬទេ ជាពិសេសការគោរពតាមបញ្ជាថ្នាក់លើដែលមាន "សិទ្ធិអំណាចស្របច្បាប់" គឺជាការការពារខ្លួនមួយនៅក្រោមមាត្រាទី៩៩និងមាត្រា១០០នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ។ អាស្រ័យហេតុនេះ ការអនុវត្តវិធានទូទៅនៅក្នុងច្បាប់តុលាការទៅតាមបទឧក្រិដ្ឋកម្មរួមដែលចែងនៅក្នុងមាត្រាទី៣នឹងផ្ទុយពីគោលការណ៍ច្បាប់បញ្ញត្តិ ។ ដូច្នេះប្រហែលជាថា បទដ្ឋានផ្សេងៗគ្នានឹងត្រូវយកមកអនុវត្តចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិនិងឧក្រិដ្ឋកម្មរួមដែលបញ្ហានឹងលេចឡើងនៅពេលណាដែលសាលាជំនុំជម្រះក្តីចម្រុះផ្តល់យុត្តាធិការលើបទល្មើសក្នុងស្រុក ។ ជាងនេះទៅទៀតដូចដែលអ្នកនិពន្ធម្នាក់បានគូសបញ្ជាក់នៅក្នុងករណីទាំងឡាយ

ដែលគ្មានបញ្ញត្តិជាក់លាក់ណាមួយត្រូវបានធ្វើឡើងទាក់ទងទៅនឹងការការពារក្តី សេចក្តីសន្និដ្ឋានដ៏សមហេតុផលនោះគឺថា បទបញ្ញត្តិក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ក៏នឹងត្រូវយកអនុវត្តចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិ ទោះជានៅពេលនោះអំណោយផលដល់ចុងចោទក្នុងការការពារខ្លួននៅក្រោមច្បាប់អន្តរជាតិក៏ដោយ ។ ផ្សេងពីនេះវិញ អង្គជំនុំជម្រះវិសាមញ្ញអាចដោះស្រាយចំណុចខ្សោយនេះនៅក្នុងច្បាប់តុលាការនិងកិច្ចព្រមព្រៀងឆ្នាំ២០០៣ ដោយអនុវត្តតាមការវិនិច្ឆ័យនៃច្បាប់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលនឹងដោះស្រាយជាមួយនឹងកន្លះការរៀបរាប់ភ្លាមៗស្តីពីការការពារនៅក្នុងលក្ខន្តិកៈនីមួយៗដែលមានចែងនៅក្នុងវិធានក្បួនច្បាប់ទំនៀមទម្លាប់ និង«គោលការណ៍ទូទៅនៃច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ» ។

តាមពិត ស្ទើរតែរាល់អំពើអមនុស្សធម៌ដែលប្រព្រឹត្តដោយខ្មែរក្រហមត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ដែលនៅជាធរមាននៅឡើយនៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច ។ មាត្រាទី៣នៃច្បាប់តុលាការអនុញ្ញាតឲ្យមានការចោទប្រកាន់តែចំពោះបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតដូចជាៈ ការសម្លាប់ ការលួចធ្វើឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងសាសនា ។ ក្រៅពីនេះក្រមព្រហ្មទណ្ឌបានចោទប្រកាន់អំពើពាក់ព័ន្ធធំធេងមួយចំនួនដូចជាៈ ការវាយប្រហារទៅលើព្រះមហាក្សត្រនិងរាជវង្សានុវង្ស ការបំបិទសិទ្ធិស៊ីវិល ការធ្វើឲ្យខូចខាតទីតាំងសាសនា និងការបញ្ចេះការស្អប់ខ្ពើមរវាងក្រុមនិងក្រុម ។ មាត្រានេះក៏បានហាមឃាត់ការចេញបញ្ជាតាមទំនើងចិត្តរបស់មន្ត្រីរដ្ឋាភិបាលដែរ ។

ជាគោលការណ៍ហាក់ដូចជាសាមញ្ញណាស់សម្រាប់សាលាជំនុំជម្រះក្តីក្នុងស្រុកដូចករណីអង្គជំនុំជម្រះវិសាមញ្ញនេះក្នុងការកាត់ទោសខ្មែរក្រហមពីបទឧក្រិដ្ឋកម្មរួម ទោះជាអំពើដូចគ្នានេះត្រូវបានកំណត់ថាជាបទឧក្រិដ្ឋកម្មអន្តរជាតិក៏ដោយ ។ ជាពិសេសវាហាក់ដូចជាសមរម្យណាស់ក្នុងការកាត់ទោសជនដៃដល់នៃអំពើឧក្រិដ្ឋកម្ម ទោះជាគ្មានភស្តុតាងបញ្ជាក់ថាជនដៃដល់ទាំងនោះមានបំណងច្បាស់លាស់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក៏ដោយ ។ ប្រសិនបើយកដំណោះស្រាយបែបនេះទៅអនុវត្តចំពោះអ្នកដែលបានរៀបចំគម្រោងនិងអ្នកប្រតិបត្តិគោលនយោបាយឧក្រិដ្ឋនោះនឹងកាត់បន្ថយផលប៉ះពាល់នៃឧក្រិដ្ឋកម្មទាំងអស់នោះ ។ ចំណុចនេះជាប់ទាក់ទងទៅនឹងករណីប្រទេសកម្ពុជាដែលសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមមានយុត្តាធិការតូចចង្អៀត ដូច្នេះប្រហែលជាមានជនដៃដល់«ធម្មតា»តែប៉ុន្មាននាក់ប៉ុណ្ណោះដែលត្រូវចោទប្រកាន់ ។

អាស្រ័យហេតុនេះ ការដាក់បញ្ចូលនូវឧក្រិដ្ឋកម្មរួមអាចត្រូវចាត់ទុកថាជាការដកថយមួយដើម្បីឲ្យប្រាកដថាតើការចោទប្រកាន់លើបទឧក្រិដ្ឋកម្មអន្តរជាតិគួរត្រូវទាត់ចោលដែរឬទេ ។ បើត្រូវទាត់ចោលមែន ការដាក់បញ្ចូលនេះក៏នឹងស្ទះស្វែងបំពេញតាមសេចក្តីប្រាថ្នារកឲ្យឃើញនូវការជំនុំជម្រះដែលឈរលើមូលដ្ឋានរឹងមាំចំពោះការចោទប្រកាន់ដែលបានដាក់បញ្ចូលរួចមកហើយទៅក្នុងច្បាប់កម្ពុជានៅពេលដែលបទឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង ។ ទោះជាយ៉ាងណាក៏ដោយ ក្រៅពីការសង្ស័យពាក់ព័ន្ធទៅនឹងការអនុវត្តន៍តាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ការស្វែងរកភាពស្របច្បាប់បានថមថយឥទ្ធិពលដោយសារតែបទបញ្ញត្តិដែលពង្រីកបន្ថែមនូវដែនអាជ្ញាយុកាលសម្រាប់បទឧក្រិដ្ឋកម្មរួមទាំងអស់នេះ ។

## ឃ-២) យុត្តាធិការផ្ទាល់ដែលមានលក្ខណៈតូចចង្អៀត

ទោះជាមានកិច្ចព្រមព្រៀងគ្នាទាំងស្រុងអំពីតម្រូវការឲ្យកម្រិតការចោទប្រកាន់ក៏ដោយ ក៏ព្រំដែនពិតប្រាកដនៃយុត្តាធិការរបស់អង្គជំនុំជម្រះគឺជាប្រភពនៃការមិនចុះសម្រុងគ្នារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ។

ចាប់តាំងពីដើមដំបូងមក ច្បាស់ណាស់ថា យុត្តាធិការរបស់សាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនឹងត្រូវដាក់កម្រិតមុនពេលដែលការចូលរួមពីអន្តរជាតិត្រូវបានកំណត់ ។ ទោះជាមិនពេញចិត្តក៏ដោយ ក៏នៅក្នុងខ្លឹមសារនៃលិខិតដែលដាក់ឲ្យដំណើរការទាំងស្រុង សហនាយករដ្ឋមន្ត្រីបានស្នើសុំឲ្យមាន«ជំនួយឧបត្ថម្ភពីអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិដើម្បីនាំយកមេដឹកនាំខ្មែរក្រហមឡើងតុលាការពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេលគ្រប់គ្រងអំណាចរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩» ។

ដើម្បីឈានទៅដល់កិច្ចព្រមព្រៀងចុងក្រោយលើសេចក្តីព្រាងអនុស្សរណៈយោគយល់នៅក្នុងខែកក្កដាឆ្នាំ២០០០ អង្គការសហប្រជាជាតិបានទទួលស្គាល់ថា យុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញគួរតែគ្របដណ្តប់តែទៅលើ«មេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត» ចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការ ។ បែបផែននៃពាក្យពេចន៍ទាំងនេះមានប្រភពចេញពីរបាយការណ៍របស់ក្រុមអ្នកជំនាញការអង្គការសហប្រជាជាតិដែលស្នើសុំឲ្យមានការចោទប្រកាន់បុគ្គលណាដែលជាអ្នក«ទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតក្នុងអំឡុងពេលគ្រប់គ្រងអំណាចរបស់កម្ពុជាប្រជាធិបតេយ្យ» ។ ក្រុមអ្នកជំនាញការបានសារភាពថា ពាក្យពេចន៍នេះនឹងមិនគ្របដណ្តប់លើ«គ្រប់បុគ្គលថ្នាក់ខ្ពស់ទាំងអស់របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឬសូម្បីតែរបស់បក្សកុម្មុយនិស្តកម្ពុជាទេ» ក៏ប៉ុន្តែគ្រាន់តែគ្របដណ្តប់មកលើ«មេដឹកនាំជាន់ខ្ពស់ដែលមានការទទួលខុសត្រូវចំពោះការរំលោភ ព្រមទាំងអ្នកដែលនៅថ្នាក់ក្រោមដែលបានជាប់ពាក់ព័ន្ធផ្ទាល់នៅក្នុងអំពើឃោរឃៅដ៏ធ្ងន់ធ្ងរបំផុត»ប៉ុណ្ណោះ ។ ឯកឧត្តម សុខ អាន បានបញ្ជាក់នៅក្នុងអំឡុងពេលពិភាក្សានៅរដ្ឋសភាថា គោលបំណងនៃការកម្រិតបន្ថែមគឺកំណត់យុត្តាធិការនៃការចោទប្រកាន់ឲ្យនៅត្រឹមបុគ្គលមួយចំនួនតូច ដើម្បីចៀសវាងកុំឲ្យជ្រួលច្របល់ដល់អតីតកម្មាភិបាលខ្មែរក្រហមរាប់ម៉ឺននាក់ដែលបានធ្វើសមាហរណកម្មជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជារួចហើយ ។ ទោះជាការអះអាងផ្ទុយពីគោលការណ៍ទូទៅនៃច្បាប់ឧក្រិដ្ឋកម្មក៏ដោយ ក៏ការកម្រិតបែបនេះគឺជាការស្វែងរកការទទួលខុសត្រូវនៅក្នុងប្រទេសដែលអំពើឃោរឃៅបានកើតឡើងដោយមិនគិតថាតើតុលាការនោះជាតុលាការក្នុងស្រុកឬតុលាការអន្តរជាតិឡើយ ។

ដូច្នេះ មាត្រាទី២នៃច្បាប់តុលាការបានផ្តល់សិទ្ធិអំណាចឲ្យ «នាំយកមកកាត់ទោសនូវមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិប-តេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាទាក់ទងនឹងឧក្រិដ្ឋកម្ម ច្បាប់និងទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ និងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ដោយប្រទេសកម្ពុជាដែលប្រព្រឹត្តឡើងនៅក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩» ។

បើពិនិត្យមើលប្រវត្តិសាស្ត្រវិបល្លាសរបស់កម្ពុជាចាប់តាំងពីទទួលបានឯករាជ្យមក យុត្តាធិការដ៏ទូលាយជាងមុននឹងត្រួសត្រាយផ្លូវឲ្យមានការចោទប្រកាន់ដែលហួសពីក្របខ័ណ្ឌនៃអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។ ទោះជាយ៉ាងណាក៏ដោយ មិនមែនប្រទេសមហាអំណាចឬប្រទេសក្នុងតំបន់ដែលបានជាប់ពាក់ព័ន្ធនៅក្នុងជម្លោះរបស់កម្ពុជាទាំងបីលើក ហើយក៏មិនមែនរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ននេះដែរ ដែលទទួលបានផលប្រយោជន៍ពីការប្រព្រឹត្តនៅមុនរបបខ្មែរក្រហម ក្នុងអំឡុងរបបខ្មែរក្រហម និងក្រោយរបបខ្មែរក្រហម ។

ការដាក់កំហិតបន្ថែមទៀតនោះគឺថា មានតែមេដឹកនាំកម្ពុជាទេដែលទទួលរងការចោទប្រកាន់ បើទោះជាកងកម្លាំងវៀតណាមក៏ប្រហែលទទួលខុសត្រូវពីបទឧក្រិដ្ឋកម្មសង្គ្រាមក្នុងអំឡុងពេលនោះក៏ដោយ ។ សក្តានុពលនៃការប្រព្រឹត្តប្រកបដោយការរើសអើងនេះបានញ៉ាំងឲ្យក្រុមអ្នកជំនាញការអង្គការសហប្រជាជាតិឲ្យយោបល់ថា គួរតែលុបបទឧក្រិដ្ឋកម្មសង្គ្រាមចេញពីយុត្តាធិការរបស់តុលាការ ។ យោបល់នេះត្រូវបានបដិសេធ ។

បញ្ហាចោទឡើងគឺថា តើការដាក់កម្រិតបន្ថែមបែបនេះនៅក្នុងច្បាប់ជាការសមរម្យដែរឬទេ ។ ដោយលើកយកឧទាហរណ៍អំពីតុលាការពិសេសសម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉ូវ៉ាន់ដា ក្រុមអ្នកជំនាញការបានស្នើថា អង្គជំនុំជម្រះវិសាមញ្ញមានលក្ខណៈអំណោយផលដល់យុត្តាធិការដ៏ទូលំទូលាយដែលគ្របដណ្តប់ទៅលើ«បុគ្គលណាម្នាក់ ដែលអំពើរបស់បុគ្គលនោះស្ថិតនៅក្នុងយុត្តាធិការតាមសំណុំរឿងដែលជាប់វិវាទរបស់អង្គជំនុំជម្រះ» ។ ដូច្នេះ នេះជាតួនាទីរបស់ព្រះរាជអាជ្ញាក្នុងការសម្រេចថាតើត្រូវកាត់ទោសបុគ្គលណាម្នាក់ «ដោយពិចារណាអំពីគោលដៅទាំងពីរ គឺការទទួលខុសត្រូវរបស់បុគ្គលនិងការផ្សះផ្សាជាតិ» ។ នៅទីបញ្ចប់ អង្គការសហប្រជាជាតិត្រូវបានបង្ខំឲ្យទទួលយកចំណុចនេះនៅក្នុងខែកក្កដាឆ្នាំ២០០០ ដោយសារតែសម្តេច ហ៊ុន សែន បានដាក់ចំណុចនេះធ្វើជាលក្ខខណ្ឌសម្រាប់ការធានារបស់គាត់ចំពោះឯករាជ្យភាពរបស់ព្រះរាជអាជ្ញានិងចៅក្រម

សើុបអង្កេតអន្តរជាតិ ។ ប្រតិបត្តិការថ្មីៗនេះរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិទាក់ទងទៅនឹងបញ្ហានេះ គឺមិនខុសប្លែកគ្នាពីការប្រតិបត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញទេ ព្រោះថារាល់ករណីដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិមិនបានជំនុំជម្រះប្រហែលជាត្រូវបានផ្ទេរទៅឲ្យតុលាការក្នុងស្រុករបស់ប្រទេសដែលជាប់ពាក់ព័ន្ធ ។ ផ្ទុយទៅវិញ នៅក្នុងបរិបទប្រទេសកម្ពុជា ជនណាម្នាក់ដែលមិនត្រូវការកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញទេ ជននោះនឹងរួចទោសដោយស្វ័យប្រវត្តិតែម្តង ទោះជាចំពោះបទឧក្រិដ្ឋកម្មទូទៅឬបទឧក្រិដ្ឋកម្មអន្តជាតិក៏ដោយ ។

បច្ចុប្បន្ននេះ អ្នកដែលត្រូវចាប់ខ្លួនមានតែ អ៊ុង ជឿន ដែលគ្រប់គ្នាស្គាល់ថាជា តាម៉ុក (ជាមេបញ្ជាការយោធាជាន់ខ្ពស់តែម្នាក់គត់ដែលមិនព្រមចុះចូល) និង កាំង ហ្កិចអៀវ ដែលគ្រប់គ្នាស្គាល់ថាជា ឌុច (អតីតប្រធានមន្ទីរសន្តិសុខទួលស្លែងនៅភ្នំពេញ) ។ ដើម្បីចៀសវាងកាតព្វកិច្ចក្នុងការដោះលែង តាម៉ុក មុនពេលបើកការជំនុំជម្រះតាមផ្លូវច្បាប់បន្ទាប់ពីផុតរយៈពេលឃុំខ្លួន រាជរដ្ឋាភិបាលកម្ពុជាបានចោទប្រកាន់ តាម៉ុក ពីបទ «ឧក្រិដ្ឋកម្មប្រឆាំងសន្តិសុខក្នុងស្រុកក្នុងគោលបំណងបម្រើឲ្យគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ» «អំពើប្រល័យពូជសាសន៍»អនុលោមតាមក្រឹត្យច្បាប់លេខ១ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩ និង «ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ» នៅក្នុងខែកុម្ភៈ ឆ្នាំ២០០២ ។ ជនសង្ស័យសំខាន់ៗដទៃទៀតដែលនៅរស់រានមានជីវិតនៅឡើយនោះរួមមាន នួន ជា, អៀង សារី និង ខៀវ សំផន ។

**ឃ-៣) ឥទ្ធិពលនៃសេចក្តីសម្រេចដំបូងរបស់តុលាការ និងអភ័យឯកសិទ្ធិរួចផុតពីយុត្តាធិការ**

ក្រៅពីបញ្ហាដែលបានកម្រិតទាំងអស់នេះ វាជាការចាំបាច់ក្នុងការពិនិត្យពិចារណាអំពីឥទ្ធិពលជាយថាហេតុនៃវិធានការផ្លូវច្បាប់ដំបូងៗរបស់អាជ្ញាធរកម្ពុជាក្នុងការចោទប្រកាន់មនុស្សមួយចំនួនដែលនឹងស្ថិតនៅក្នុងយុត្តាធិការផ្ទាល់របស់អង្គជំនុំជម្រះវិសាមញ្ញ ។ ប្រសិនបើការជំនុំជម្រះត្រូវធ្វើឡើងនៅក្រោមច្បាប់កម្ពុជា ជាការពិតណាស់ ចុងចោទនឹងលើកឡើងអំពីបញ្ហាអភ័យឯកសិទ្ធិ ។ ក្រៅពីនេះ វាមានសារសំខាន់ខ្លាំងណាស់ក្នុងការ



វិភាគទៅលើឥទ្ធិពលនៃការកាត់ទោសរបស់សាលាជំនុំជម្រះក្តីកម្ពុជាទាំងពីរលើកកាលពីពេលមុនដោយឈរលើគោលការណ៍គ្រោះថ្នាក់ទ្វេដង (non bis in idem) និងការលើកលែងទោសដែលព្រះមហាក្សត្របានផ្តល់ឲ្យបុគ្គលទាំងអស់នោះ ។

បញ្ហាសំខាន់នៃ non bis in idem កើតចេញពីសំណើរបស់សម្តេច ហ៊ុន សែន ដែលថា អៀង សារី (អតីតបងធំលំដាប់ទី២ របស់ខ្មែរក្រហម និងនៅតែជាអ្នកដើរតួម្នាក់ដ៏មានឥទ្ធិពល) មិនគួរត្រូវនាំយកទៅកាត់ទោសពីបទប្រល័យពូជសាសន៍ទៀតទេ ព្រោះរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបានកាត់ទោស«បនក្សត់ ប៉ុល ពត អៀង សារី» ពីបទឧក្រិដ្ឋកម្មនេះរួចហើយនៅក្នុងឆ្នាំ១៩៧៩ ។ តាមពិតទៅ នេះជាការអះអាងបែបងាយៗទៅ




លើបញ្ហាផ្លូវច្បាប់ដែលមានលក្ខណៈស្មុគស្មាញតែប៉ុណ្ណោះ ។ ទី១ ច្បាប់តុលាការមិនបាននិយាយសំដៅឲ្យបានជាក់ច្បាស់លាស់ ដើម្បីគោរពគោលការណ៍នេះខ្លួនឯង ហើយតុលាការក្នុងស្រុកក៏មិនច្បាស់អំពីបញ្ហានេះដែរ ។ ទោះជាគោលការណ៍នេះត្រូវបានប្រកាសនៅក្នុងមាត្រាទី១៤(៧) នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយក៏ដោយ ក៏ប្រទេសកម្ពុជាមិនទទួលយកមកអនុវត្តដោយផ្ទាល់នូវសន្ធិសញ្ញាសិទ្ធិមនុស្សដោយមិនចាំបាច់អនុវត្តន៍តាមច្បាប់របស់ខ្លួននោះដែរ ។ ទី២ ទោះជាការជំនុំជម្រះកាលពីឆ្នាំ១៩៧៩ត្រូវបានចាត់ទុកថាមិនស្របទៅតាមគោលការណ៍អន្តរជាតិក្តី ក៏ការកាត់ទោសនេះអាចចាត់ទុកថាជាការរៀបរយសណ្តាប់ធ្នាប់ផ្ទៃក្នុងនៃច្បាប់របស់កម្ពុជា ។ ក៏ប៉ុន្តែចំណុចនេះមិនទាន់ប្រាកដនៅឡើយទេ ដោយសារតែសវនាការនៅពេលនោះធ្វើឡើងដោយកំបាំងមុខ ហើយប្រហែលជាថា ច្បាប់ឧក្រិដ្ឋកម្មកម្ពុជាដែលផ្អែកលើប្រព័ន្ធច្បាប់របស់បារាំងអនុញ្ញាតឲ្យមានសវនាការថ្មីមួយបន្ទាប់ពីការចាប់ខ្លួនជនសង្ស័យ ដើម្បីគោរពដល់សិទ្ធិជាមូលដ្ឋានរបស់ជនសង្ស័យ ។ ទី៣ ការកំណត់និយមន័យនៃពាក្យ«ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» នៅក្នុងក្រឹត្យច្បាប់ឆ្នាំ១៩៧៩ ដែលបង្កើតឡើងក្រោយហេតុការណ៍ (ex post factor) ដើម្បីគ្របដណ្តប់លើរាល់បទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ខុសគ្នាពីនិយមន័យរបស់អនុសញ្ញាឆ្នាំ១៩៤៨ ហើយត្រូវបានមើលឃើញថាជាការចោទប្រកាន់បែបធម្មតានៅក្រោមច្បាប់កម្ពុជាប៉ុណ្ណោះ ។ តាមការពិត ច្បាប់អន្តរជាតិអនុញ្ញាត

ឲ្យចោទប្រកាន់បុគ្គលណាម្នាក់ពីបទឧក្រិដ្ឋកម្មអន្តរជាតិ បើទោះបីជាបុគ្គលនោះត្រូវបានកាត់ទោសរួចហើយពីបទឧក្រិដ្ឋកម្មធម្មតាដោយផ្អែកលើអំពើដូចគ្នានោះក៏ដោយ ។ យ៉ាងណាក៏ដោយ វេទិកាដ៏ស័ក្តិសមដើម្បីសម្រេចបញ្ហាផ្លូវច្បាប់ដ៏ស្មុគស្មាញនេះគឺមានតែតុលាការមានសមត្ថភាពមួយប៉ុណ្ណោះ មិនមែននាយករដ្ឋមន្ត្រីកម្ពុជាទេ ។

ដោយសារតែដឹងច្បាស់អំពីទំនាក់ទំនងគ្នាជាប្រវត្តិសាស្ត្ររវាងរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ននិងខ្មែរក្រហម អង្គការសហប្រជាជាតិបានទទូចម្តងហើយម្តងទៀតសុំឲ្យបដិសេធចោលនូវការលើកលែងទោស (មុនពេលមានការជំនុំជម្រះ) ឬការអត់ឱនទោស (បន្ទាប់ពីជំនុំជម្រះរួចហើយ) ។ ទោះជាមានការទទូចសុំយ៉ាងនេះក៏ដោយ ច្បាប់តុលាការគ្រាន់តែបានហាមប្រាមមិនឲ្យរាជរដ្ឋាភិបាលកម្ពុជាស្នើសុំឲ្យមានការលើកលែងទោសឬការអត់ឱនទោសដល់បុគ្គលណាម្នាក់ដែលត្រូវបានស៊ើបអង្កេតឬកាត់ទោសពីបទឧក្រិដ្ឋកម្មស្ថិតនៅក្នុងដែនយុត្តាធិការរបស់អង្គជំនុំជម្រះ (មាត្រាទី៤០) ។ បទបញ្ញត្តិមិនពេញលេញនេះត្រូវបានសម្តេច ហ៊ុន សែន អះអាងថាជាបទបញ្ញត្តិមួយខ្ពស់បំផុតហើយមិនចាំបាច់កែប្រែរដ្ឋធម្មនុញ្ញនោះទេ ។ ជាលទ្ធផល គ្មានបទបញ្ញត្តិណាមួយនៅក្នុងច្បាប់តុលាការចែងសម្រាប់បុគ្គលដែលបានទទួលនូវការអនុគ្រោះបែបនោះរួចហើយ ដូចជា អៀង សារី ដែលបានទទួលការលើកលែងទោសពីអតីតព្រះមហាក្សត្រ នរោត្តម សីហនុ នៅពេលដែលគាត់ធ្វើសមាហរណកម្មនៅក្នុងខែសីហាឆ្នាំ១៩៩៦ មានការអនុម័តយល់ស្របជាផ្លូវការពីរាជរដ្ឋាភិបាលនិងរដ្ឋសភាកម្ពុជា ។ នៅពេលនោះ សម្តេច សីហនុ បានប្រកាសថា ការលើកលែងទោសនេះជាសំណើផ្ទុកក្នុងសុទ្ធសាធ ។

លើសពីនេះទៀត អនុលោមតាមច្បាប់ឆ្នាំ១៩៩៤ដែលដាក់កម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ កងទ័ពខ្មែរក្រហមរូបណាដែលស្ម័គ្រចិត្តចុះចូលនៅក្នុងអំឡុងពេល៦ខែក្រោយនោះនឹងមិនត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទេ ។ ក៏ប៉ុន្តែ ច្បាប់នេះគួរតែគ្មានឥទ្ធិពលទៅលើការចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញទេ ដោយសារថា មាត្រាទី៦ ដាក់មេដឹកនាំខ្មែរក្រហមឲ្យផុតពីបញ្ញត្តិលើកលែងទោស ។

នៅទីបញ្ចប់ គួរកត់សម្គាល់ដែរថា ទោះជាគ្មានការធានាជាពិសេសណាមួយឲ្យបានច្បាស់លាស់ក៏ពិតមែន ក៏ប៉ុន្តែក្រុមប្រឹក្សាធម្មនុញ្ញផ្តល់សុពលភាពដល់ច្បាប់នេះដែលនឹងត្រូវបកស្រាយក្នុងលក្ខណៈមួយដើម្បីធានាការគោរពនូវបទដ្ឋានសិទ្ធិមនុស្សដែលការពារដោយរដ្ឋធម្មនុញ្ញ ។ ដូចបានរៀបរាប់ខាងលើ វាមិនទាន់ច្បាស់នៅឡើយថាតើអង្គជំនុំជម្រះអាចពិនិត្យឡើងវិញដើម្បីអនុញ្ញាតឲ្យមានការចោទប្រកាន់ជនណាម្នាក់ដែលបានទទួលការលើកលែងទោសរួចហើយឬទេ ។

នៅខែមករា ឆ្នាំ២០០១ អង្គការសហប្រជាជាតិបានបញ្ចេញអនុស្សរណៈទាក់ទងទៅនឹងមាត្រាទី៤០នៃច្បាប់តុលាការ ដោយគូសបញ្ជាក់ថា អនុលោមតាមមាត្រាទី៩នៃសេចក្តីព្រាងអនុស្សរណៈយោគយល់ "ការលើកលែងទោសជនណាម្នាក់ដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់អង្គជំនុំជម្រះមិនមែនជាឧបសគ្គចំពោះការចោទប្រកាន់នោះទេ" ។ អង្គការសហប្រជាជាតិធ្លាប់បានគោរពគោលការណ៍នេះថាជាលក្ខខណ្ឌជាមុនសម្រាប់ការចូលរួមរបស់ខ្លួន និងការបន្តការចរចាដែលនាំឆ្ពោះទៅរកការដាក់បញ្ចូលនូវបទបញ្ញត្តិដែលធ្វើវិសោធនកម្មរួចហើយទៅក្នុងកិច្ចព្រមព្រៀងឆ្នាំ២០០៣ ។

### ឃ-៤) កាលបរិច្ឆេទនិងដែនដី

នៅរាល់ដំណាក់កាលនៃការចរចា ជាពិសេសនៅក្នុងខែមករា ឆ្នាំ១៩៩៩ សម្តេច ហ៊ុន សែន បានអំពាវនាវឲ្យពង្រីកការកាត់សេចក្តីឲ្យកាន់តែទូលំទូលាយថែមទៀតដើម្បីគ្របដណ្តប់លើចន្លោះពេលពីឆ្នាំ១៩៧០រហូតដល់បច្ចុប្បន្ន ។ ការអំពាវនេះបើកផ្លូវយ៉ាងច្បាស់ក្រឡែតឲ្យមានការស៊ើបអង្កេតទៅលើសហរដ្ឋអាមេរិកពីបទឧក្រិដ្ឋកម្មសង្គ្រាមទាក់ទងទៅនឹងការទម្លាក់គ្រាប់បែកបេ-៥២ ដ៏ច្រើនសន្ធឹកសន្ធាប់មកលើប្រទេសកម្ពុជារហូតដល់ឆ្នាំ១៩៧៣ ព្រមទាំងស៊ើបអង្កេតទៅលើប្រទេសវៀតណាមពីបទឧក្រិដ្ឋកម្មផ្សេងៗដែលប្រព្រឹត្តឡើងក្នុងអំឡុងពេលនៃការកាន់កាប់ប្រទេសកម្ពុជាពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨៩ ។ ការអំពាវនាវនេះក៏បានលើកឡើងនូវលទ្ធភាពនៃការស៊ើបអង្កេតតួនាទីរបស់ប្រទេសលោកខាងលិចនិងអង្គការសហប្រជាជាតិខ្លួនឯងដែលគាំទ្រ

ខ្មែរក្រហមប្រឆាំងនឹងវៀតណាមដែរ ។ ជាមូលដ្ឋាន ដោយសារតែមានលក្ខណៈជាកល្បិចចរចា ការអំពាវនាវនេះមិនអាចយកមកអនុវត្តបានទេ ហើយកាលបរិច្ឆេទត្រូវបានកម្រិតឲ្យនៅត្រឹមរយៈកាលមួយជាក់លាក់របស់របបកម្ពុជាប្រជាធិបតេយ្យ គឺនៅចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ការកំណត់បង្ហាញច្បាស់ថា រយៈពេលនេះជារយៈពេលរបស់របបកម្ពុជាប្រជាធិបតេយ្យ ហើយបដិសេធអំពើឧក្រិដ្ឋកម្មស្រដៀងគ្នានេះដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមមុនពេលកាន់អំណាចនិងបន្ទាប់ពីការកាន់អំណាច ។

ក្រៅពីបញ្ហាជាក់ស្តែងនៃច្បាប់ប្រតិសកម្មដែលលើកឡើងដោយច្បាប់តុលាការ បញ្ហាមួយក៏កើតមានដែរ នោះគឺការដាក់កម្រិតទៅលើការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មរួមមួយចំនួន ។ បើពិនិត្យមើលថាចលនាខ្មែរក្រហមបានប្រព្រឹត្តបទឧក្រិដ្ឋកម្មនៅក្នុងប្រទេសជិតខាងកម្ពុជាដែរនោះ យុត្តាធិការដែនដីដែលមានកម្រិតរបស់អង្គជំនុំជម្រះក៏នៅតែចោទជាបញ្ហា ។

ដូចដែលបានទទួលស្គាល់នៅក្នុងច្បាប់កម្ពុជា គោលការណ៍ "គ្មានបទឧក្រិដ្ឋកម្មណាដែលមិនមានចែងនៅក្នុងច្បាប់" បានហាមប្រាមមិនឲ្យមានច្បាប់ព្រហ្មទណ្ឌប្រតិសកម្មទេ ។ ខណៈដែលថាឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមត្រូវបានប្រព្រឹត្តឡើងបន្ទាប់ពីការផ្តល់សច្ចាប័នរបស់កម្ពុជាទៅលើអនុសញ្ញាអន្តរជាតិទាំងឡាយដែលបានបញ្ជាក់នៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះគឺជាការពិត វិធានការទាំងអស់ដែលបានច្របាច់បញ្ចូលកាតព្វកិច្ចអន្តរជាតិទៅក្នុងច្បាប់ក្នុងស្រុកត្រូវបានធ្វើឡើងនៅពេលបន្ទាប់មករាប់បញ្ចូលទាំងច្បាប់តុលាការដែលអនុម័តនៅក្នុងឆ្នាំ២០០១ដែរ ។ មានការមិនយល់ស្របគ្នាខ្លះៗក្នុងចំណោមអ្នកជំនាញការច្បាប់អំពីជម្រើសដែលបានបើកចំហចំពោះប្រទេសកម្ពុជាឲ្យបំពេញកាតព្វកិច្ចរបស់ខ្លួនទៅតាមអនុសញ្ញាដើម្បីទប់ស្កាត់និងដាក់ទោសអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ដោយមិនរំលោភលើគោលការណ៍ "គ្មានបទឧក្រិដ្ឋកម្មណាដែលមិនមានចែងនៅក្នុងច្បាប់" ។ ក៏ប៉ុន្តែរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានពិនិត្យពិចារណាយ៉ាងល្អិតល្អន់ថា ច្បាប់អនុញ្ញាតឲ្យចោទប្រកាន់ខ្មែរក្រហមតែអំពីបទឧក្រិដ្ឋកម្មណាដែលហាមឃាត់ដោយច្បាប់អន្តរជាតិនៅក្នុងអំឡុងពេលដែលខ្មែរក្រហមកាន់អំណាចតែប៉ុណ្ណោះ ដោយសារតែច្បាប់នីតិវិធីបានកំណត់ថាតើសាលាជំនុំជម្រះក្តីណាមួយមានយុត្តាធិការដើម្បីកាត់សេចក្តីខ្មែរក្រហម ។ អាស្រ័យហេតុនេះ ច្បាប់តុលាការមិនបានដាក់បញ្ចូលឧក្រិដ្ឋកម្មដែលគ្រាន់តែត្រូវបានហាមឃាត់នៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិចាប់តាំងពីឆ្នាំ១៩៧៩ ដូចជាការធ្វើទារុណកម្មនិងការរំលោភទៅលើពិធីសារបន្ថែមរបស់អនុសញ្ញាទីក្រុងហ្សឺណែវទេ ។

នៅក្នុងន័យនេះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនឹងក្លាយទៅជាបញ្ហាដ៏គួរឲ្យកត់សម្គាល់ ។ ទោះជាការដាក់បញ្ចូលឧក្រិដ្ឋកម្មនេះស្របទៅនឹងការហាមប្រាមជាអន្តរជាតិតាមទំនៀមទម្លាប់តាំងពីមុនឆ្នាំ១៩៧៥ក៏ដោយ ក៏បែបផែនពិតប្រាកដនៃការប្រព្រឹត្តបទល្មើសនាពេលនោះធ្វើឲ្យមានការលំបាកក្នុងការកំណត់ណាស់ ។ ក្នុងចំណោមបញ្ហាទាំងបួនដែលបានរៀបរាប់ខាងលើដែលច្បាប់តុលាការខុសប្លែកពីធម្មនុញ្ញទីក្រុងរ៉ូម (sic) — 

ដែលច្បាប់តុលាការខុសប្លែកពីធម្មនុញ្ញនូរិមប៊ឺក ការមិនទាក់ទងជាមួយនឹងជម្លោះ និងការមិនដាក់បញ្ចូលទៅក្នុងច្បាប់នូវការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម និងរំលោភសេពសន្ថវៈ នឹងមិនបង្កើតឲ្យមានបញ្ហាជាដុំកំភួនឡើយ ដោយសារតែភាពខុសប្លែកគ្នាត្រូវបានដាក់បញ្ចូលទៅក្នុងនិយមន័យតាមទំនៀមទម្លាប់ចាប់តាំងពីសង្គ្រាមលោកលើកទី២មកម្ល៉េះ ។ ទោះជាយ៉ាងណាក៏ដោយ សេចក្តីត្រូវការជាផ្លូវការចំពោះការវាយប្រហារបែបរាលដាលឬបែបប្រព័ន្ធគឺជាផ្នែកនៃការវិវត្តន៍ថ្មីៗនេះនៅក្នុងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ដូចដែលបានឆ្លុះបញ្ចាំងតាមរយៈតុលាការអន្តរជាតិពិសេស និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ។ បន្ថែមពីនេះទៀត តម្រូវការរកឲ្យឃើញចេតនារើសអើងនៅក្នុងគ្រប់ករណីទាំងអស់ត្រូវបានកំណត់ច្បាស់នៅក្នុងលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា និងជាទូទៅត្រូវបានចាត់ទុកថាមានភាពរឹតត្បិតជាងទស្សនៈវិស័យច្បាប់ទំនៀមទម្លាប់ ។ ទោះជាច្បាប់ប្រតិសកម្មដែលមិនផ្ទុយពីគោលការណ៍ផ្លូវច្បាប់ក៏ដោយ ក៏ភាពខុសប្លែកគ្នាទាំងនេះបានបង្ហាញថា ការវិនិច្ឆ័យតាមច្បាប់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិត្រូវតែដោះស្រាយដោយប្រុងប្រយ័ត្ននៅពេលយកមកអនុវត្តនៅក្នុងស្ថានការណ៍

របស់កម្ពុជា ។ ការវិនិច្ឆ័យដូចគ្នានេះនឹងអនុវត្តចំពោះនិយមន័យដែលកែប្រែដែលត្រូវបានអនុម័តនៅក្នុងកិច្ចព្រមព្រៀងឆ្នាំ២០០៣ ដោយដកស្រង់ចេញផ្ទាល់ពីលក្ខន្តិកៈរបស់តុលាការខ្មែរក្រហមអន្តរជាតិ ។

ក្រៅពីបញ្ហាចោទមួយចំនួនតូច ច្បាប់តុលាការហាក់ដូចជាបំពេញបានទៅតាមលក្ខណៈវិនិច្ឆ័យនៃច្បាប់ព្រហ្មទណ្ឌដែលកំពុងមានសុពលភាព ដោយសារតែច្បាប់នេះក៏មានចែងអំពីការដាក់ទោសដ៏ជាក់លាក់ដែរ ។ រយៈពេលនៃការដាក់ពន្ធនាគារមានចន្លោះពីប្រាំឆ្នាំរហូតដល់អស់មួយជីវិត និងរឹបអូសយកទ្រព្យសម្បត្តិដែលបានមកដោយខុសច្បាប់(ជំពូកទី១១) ។

ដូចដែលអគ្គការសហប្រជាជាតិបានស្នើច្បាប់តុលាការបានបដិសេធដាច់ខាតនូវដែនអាជ្ញាយុកាលចំពោះបទប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ទោះបីជាមានការខ្វះខាតដ៏គួរឲ្យសោកស្តាយនូវបទបញ្ញត្តិស្រដៀងគ្នានេះសម្រាប់បទឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗទៀតក៏ដោយ វាប្រហែលជាថាការខ្វះខាតដែនអាជ្ញាយុកាលណាមួយនឹងត្រូវចាត់ទុកថាគ្មានឯកសារសំអាងគ្រប់គ្រាន់ ដោយសារតែច្បាប់តុលាការបានបដិសេធចោលនូវដែនអាជ្ញាយុកាលដែលមានស្រាប់សម្រាប់បទឧក្រិដ្ឋកម្មរួមនៅក្រោមច្បាប់កម្ពុជា ។ ជាការពិតណាស់ថា មាត្រាទី៣នៃច្បាប់នេះបានបន្ថយពេលវេលាឲ្យនៅត្រឹមរយៈពេល២០ឆ្នាំដែលជាដែនអាជ្ញាយុកាលនៃការចោទប្រកាន់បទឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងមាត្រានេះ ។ បន្ទាប់ពីត្រូវបានបន្ថែមរយៈពេល២០ឆ្នាំដែលមានចែងរួចហើយនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អំពើឧក្រិដ្ឋកម្មទាំងអស់នេះនឹងមានពេលវេលាកំណត់នៅចន្លោះឆ្នាំ២០០៥និងឆ្នាំ២០០៩ ។

**(នៅមានត)**

**ជាទីដ ប៉័យ**

# វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី "វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

- រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។
- ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍ សេចក្តីទុក្ខការខឹងគុំកួនមកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងការរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងពត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# ទម្រង់ទូទៅនៃអង្គជំនុំជម្រះវិសាមញ្ញ

នៅវិស្សមកាលរដូវក្តៅក្នុងឆ្នាំ២០០៤ដែលមានរយៈពេលបួនខែ ខ្ញុំបានចូលរួមជួយសម្រួលដល់វគ្គហ្វឹកហ្វឺនផ្នែកច្បាប់រយៈពេល៦សប្តាហ៍ក្នុងនៅទីក្រុងភ្នំពេញជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាអង្គការមួយផ្តោតទៅលើការថែរក្សាឯកសារប្រវត្តិសាស្ត្រទាក់ទងនឹងរបបខ្មែរក្រហម ។ គោលបំណងនៃវគ្គសិក្សានេះគឺដើម្បីពង្រីកការអប់រំដល់សហគមន៍មូលដ្ឋានអំពីច្បាប់ដែលនឹងត្រូវប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនៃប្រទេសកម្ពុជា ។ កិច្ចខិតខំប្រឹងប្រែងនេះគឺដើម្បីជួយឲ្យសហគមន៍នៅតាមមូលដ្ឋានបានយល់ដឹងអំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

អង្គជំនុំជម្រះវិសាមញ្ញកំពុងតែត្រូវបានបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលបានប្រព្រឹត្តបទឧក្រិដ្ឋមួយចំនួនប្រឆាំងនឹងប្រជាជនកម្ពុជាខ្លួនឯង ដោយរួមទាំងការបាត់បង់ជីវិត របស់ប្រជាជនចំនួនពី៨សែននាក់ទៅដល់២លាននាក់ (ចំនួនពិតប្រាកដមិនត្រូវបានដឹងដោយសារខ្វះទិន្នន័យអំពីការស្រង់ចំនួនប្រជាជននៅមុនរបបខ្មែរក្រហម) ។ អត្ថបទនេះគឺជំនួយដល់ការយល់ដឹងជាមូលដ្ឋានអំពីច្បាប់ដែលនឹងត្រូវប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។

## ការបង្កើត

អង្គជំនុំជម្រះវិសាមញ្ញមានទីតាំងនៅក្នុងទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា ។ តាមន័យច្បាប់ អង្គជំនុំជម្រះនេះជាលទ្ធផលនៃឧបករណ៍ច្បាប់ចំនួនពីរគឺ «ច្បាប់ស្តីអំពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» និង «កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សច្ចាប័នដល់ច្បាប់នេះនៅខែតុលា ឆ្នាំ២០០៤ ។ ឧបករណ៍ច្បាប់ទាំងពីរនេះនឹងដើរតួនាទីជាសន្ធិសញ្ញាអន្តរជាតិដែលត្រូវគ្រប់គ្រងដោយច្បាប់សន្ធិសញ្ញា (នេះជាចំណុចគួរឲ្យកត់សម្គាល់ដោយសារថា នៅក្នុងកិច្ចព្រមព្រៀងទាំងពីរមិនមានកិច្ចព្រមព្រៀងណាមួយដែលធ្វើឡើងរវាងកម្ពុជានិងរដ្ឋណាមួយផ្សេងទៀតនោះទេ ហើយនេះជាលក្ខខណ្ឌធម្មតាដែលសន្ធិសញ្ញាអន្តរជាតិមួយចាំបាច់ត្រូវតែបំពេញ) ។

## ការគ្រប់គ្រង

អង្គជំនុំជម្រះវិសាមញ្ញគឺជាអង្គជំនុំជម្រះពិសេសនៅក្នុងនៃប្រព័ន្ធយុត្តិធម៌កម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញនេះមិនមែនជាផ្នែកមួយនៃអង្គការសហប្រជាជាតិទេ ។ អង្គជំនុំជម្រះវិសាមញ្ញជាតុលាការចម្រុះដែលមានចៅក្រមជាតិនិងអន្តរជាតិ និងសហព្រះរាជអាជ្ញាពីររូប ដែលមួយរូបជាសហព្រះរាជអាជ្ញាជាតិនិងមួយរូបទៀតជាសហព្រះរាជអាជ្ញាអន្តរជាតិ ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាជាអ្នកត្រួតពិនិត្យមើលដំណើរការរបស់អង្គជំនុំជម្រះពិសេសនេះ ។ ចៅក្រមនិងព្រះរាជអាជ្ញានឹងបំពេញភារកិច្ចរបស់ខ្លួនដោយឯករាជ្យ ។ រាជរដ្ឋាភិបាលកម្ពុជានឹងទទួលខុសត្រូវចំពោះការផ្គត់ផ្គង់បុគ្គលិកជនជាតិកម្ពុជា ហើយអង្គការសហប្រជាជាតិនឹងទទួលខុសត្រូវក្នុងការផ្តល់បញ្ជីបុគ្គលិកអន្តរជាតិសំខាន់ៗ ដែលតាមរយៈបញ្ជីនេះ រាជរដ្ឋាភិបាលកម្ពុជាគឺជាអ្នកជ្រើសរើសបុគ្គលិកអន្តរជាតិនិងចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិ ។

## សមាសភាព

មានអង្គជំនុំជម្រះពីរថ្នាក់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ រាល់ការចេញសេចក្តីសម្រេចចិត្តនិងសាលក្រមទាំងឡាយចាំបាច់តម្រូវឲ្យមានសំឡេងភាគច្រើនដាច់ខាតគាំទ្រ ។ សំឡេងភាគច្រើនដាច់ខាតជាបរិបទថ្មីនៅក្នុងនីតិព្រហ្មទណ្ឌអន្តរជាតិដែលចេញមកពីបទដ្ឋាននៃការសម្រេចដោយបោះឆ្នោតយកសំឡេងភាគច្រើនដាច់ខាត ។ នៅក្នុងអង្គជំនុំជម្រះនៃសាលាដំបូងយ៉ាងហោចណាស់ត្រូវមានបួនសំឡេងគាំទ្រដើម្បីចេញសេចក្តីសម្រេចឬសាលក្រមណាមួយ ។ នៅក្នុងអង្គជំនុំជម្រះនៃសាលាកំពូល

យ៉ាងហោចណាស់ត្រូវមានប្រាំសំឡេងគាំទ្រ ។ អង្គជំនុំជម្រះវិសាមញ្ញនៅសាលាដំបូងមានចៅក្រមចំនួនប្រាំរូប (ដែលក្នុងនោះបីរូបជាចៅក្រមកម្ពុជានិងពីររូបជាចៅក្រមអន្តរជាតិ) ។ អង្គជំនុំជម្រះវិសាមញ្ញនៅសាលាកំពូលមានចៅក្រមចំនួនប្រាំពីររូប (ដែលក្នុងនោះមានបួនរូបជាចៅក្រមកម្ពុជា និងបីរូបជាចៅក្រមអន្តរជាតិ) ។ ការិយាល័យព្រះរាជអាជ្ញានឹងមានសហព្រះរាជអាជ្ញាពីររូបដែលមួយរូបជាសហព្រះរាជអាជ្ញាកម្ពុជានិងមួយរូបជាសហព្រះរាជអាជ្ញាអន្តរជាតិ ។ ហាសិបភាគរយនៃបុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញជាជនជាតិកម្ពុជា ។

## យុត្តាធិការ

អង្គជំនុំជម្រះវិសាមញ្ញមានដែនយុត្តាធិការដែលមានកំណត់ ។ យុត្តាធិការមានកំណត់នេះគឺគ្របដណ្តប់លើបទល្មើសដែលប្រព្រឹត្តនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ (ថ្ងៃដែលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ) និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ (ថ្ងៃដែលខ្មែរក្រហមត្រូវបណ្តេញចេញពីអំណាច) ។ ជាងនេះទៅទៀតយុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញក៏មានកំណត់លើជនល្មើសដែរ ។ បុគ្គលដែលសាលាជំនុំជម្រះក្តីអាចកាត់ទោសបានលុះត្រាតែបុគ្គលនោះជាៈ ១) ជាមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ ឬ ២) ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃបទឧក្រិដ្ឋដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ ។ យុត្តាធិការនៃបទល្មើសរបស់អង្គជំនុំជម្រះវិសាមញ្ញរួមមានបទល្មើសអន្តរជាតិចំនួនប្រាំនិងបទល្មើសច្បាប់ក្នុងស្រុកចំនួនបី ។ បទល្មើសអន្តរជាតិទាំងប្រាំនោះមាន÷ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌និងឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលទទួលបានការការពារជាអន្តរជាតិ ។ បទល្មើសក្នុងស្រុកទាំងបីគឺ មនុស្សឃាត ទារុណកម្ម និងការវាយប្រហារលើសាសនា ។

## ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

នៅក្នុងបរិបទនៃនីតិព្រហ្មទណ្ឌអន្តរជាតិ បទល្មើសអន្តរជាតិបីប្រភេទដែលកំពុងតែរីកចម្រើនគឺឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាអំពើណាមួយក្នុងចំណោមអំពើខាងក្រោម «ហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណា» មួយដូចជា÷

- ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម
- ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយឬសតិបញ្ញាសមាជិកនៃក្រុម(រួមទាំងការធ្វើទារុណកម្មនិងរំលោភ)
- ការធ្វើដោយចេតនាឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុងឬមួយផ្នែក (ដូចជាការដកហូតដោយចេតនានូវអាហារនិងថ្នាំពេទ្យ)
- ការដាក់នូវវិធានការនានាដែលមានបំណងរារាំងមិនឲ្យមានការផ្តល់កំណើតទារក
- ការបញ្ជូនកុមារដោយបង្ខំចេញពីក្រុមមួយឲ្យទៅក្រុមមួយផ្សេងទៀត ។

ផ្នែកដែលលំបាកបំផុតក្នុងការបង្ហាញថាទង្វើមួយជាអំពើប្រល័យពូជសាសន៍គឺជាធាតុ «គោលបំណងឬធាតុចេតនា» នៃបទល្មើស ហើយនេះជាបញ្ហាដែលអង្គជំនុំជម្រះវិសាមញ្ញនឹងជួបប្រទះ ។ ដោយសារតែឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហមត្រូវបានចោទថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍កើតឡើងនៅក្នុងប្រទេសកម្ពុជា សហព្រះរាជអាជ្ញានឹងជួបប្រទះនូវការជំទាស់នៅពេលអះអាងថាទង្វើដែលកំពុងតែចិតនៅក្នុងការសង្ស័យនេះត្រូវបានប្រព្រឹត្តឡើងនៅក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងស្រុងឬមួយផ្នែកនូវក្រុមមួយដែលទទួលបានការការពារនៅក្នុងបទល្មើសប្រល័យពូជសាសន៍ ។ នៅពេលដែលហាក់ដូចជាមានភស្តុតាងក្នុងការបង្ហាញថាមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹងសហគមន៍ជនជាតិចាម ប្រឆាំងនឹងជនភាគតិចវៀតណាមឬចិន ឬព្រះសង្ឃ ការសម្លាប់ទ្រង់ទ្រាយធំឬសកម្មភាពផ្សេងទៀតប្រឆាំងនឹងប្រជាជនកម្ពុជាភាគច្រើននឹងពិបាកក្នុងការពន្យល់តាមផ្លូវច្បាប់ថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ទោះជាយ៉ាងណាក៏ដោយសកម្មភាពផ្សេងៗទៀតក៏អាចធ្លាក់ទៅក្នុងឧក្រិដ្ឋកម្មមួយផ្សេងទៀតនៃឧក្រិដ្ឋកម្មអន្តរជាតិដែរ ។

## ខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាអំពើមួយដូចខាងក្រោមនេះ «ដែលវាយប្រហារជាទូទៅ ឬដោយមានរៀបចំប្រឆាំងនឹងប្រជាជនស៊ីវិលដែលយល់ដឹងអំពីទង្វើនោះ»

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការដាក់ជាទាសករ
- ការនិរទេស
- ការឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភលើផ្លូវភេទ
- ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ឬសាសនា ។
- អំពើអមនុស្សធម៌ផ្សេងៗទៀត ។

ខក្រិដ្ឋកម្មអន្តរជាតិមួយនេះមានតួនាទីសំខាន់ជាងគេនៅក្នុងដំណើរការសវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ទីមួយ ខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាខក្រិដ្ឋកម្មអន្តរជាតិដែលងាយស្រួលបំផុតសម្រាប់ព្រះរាជអាជ្ញាក្នុងការការពារការចោទប្រកាន់របស់ខ្លួន ។ ទីពីរ បរិបទដ៏ទូលាយនៃខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺដើម្បីកាត់ទោសបទល្មើសដែលមានលក្ខណៈ«រីករាលដាលឬមានការរៀបចំជាខ្សែសង្វាក់» ។ ដោយផ្អែកលើស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ដល់១៩៧៩ ខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប្រហែលជាមានការពន្យល់តាមន័យច្បាប់ដ៏ត្រឹមត្រូវបំផុតចំពោះអ្វីដែលបានកើតឡើង ។ ធាតុ «គោលបំណងឬចេតនា» និយមន័យរបស់ខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺមិនមែនចង្អៀតដូចនិយមន័យរបស់ខក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេ ។ ដូចគ្នាដែរ ខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមិនចាំបាច់តម្រូវឲ្យបង្ហាញថា ទង្វើដែលមានចែងខាងលើកើតឡើងនៅពេលមានជម្លោះប្រដាប់អាវុធដូចបទល្មើសខក្រិដ្ឋកម្មសង្គ្រាមនោះទេ ។

## ខក្រិដ្ឋកម្មសង្គ្រាម

ចុងក្រោយនេះគឺខក្រិដ្ឋកម្មសង្គ្រាម ។ ខក្រិដ្ឋកម្មសង្គ្រាមកើតឡើងដូចមានរៀបរាប់ខាងក្រោមនេះ «ត្រូវបានប្រព្រឹត្តជាផ្នែកមួយនៃផែនការ ឬជាផ្នែកនៃការប្រព្រឹត្តសកម្មភាពទាំងនោះនៅក្នុងទម្រង់យ៉ាងធំធេង» ÷

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬបង្កឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការបំផ្លាញ ឬធ្វើឲ្យខូចខាតធ្ងន់ធ្ងរទៅលើទ្រព្យសម្បត្តិដោយមិនមានហេតុផលចាំបាច់ខាងយោធាដែលធ្វើឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី
- ការបង្ខំឲ្យឈ្លើយសឹក ឬជនស៊ីវិលបម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ
- ការដកហូតដោយចេតនាពីឈ្លើយសឹកឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌និងទៀងទាត់
- ការនិរទេស ការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់
- ការយកជនស៊ីវិលជាចំណាប់ខ្មាំង ។

ធាតុសំខាន់បំផុតនៅក្នុងការបង្ហាញថាបទល្មើសមួយជាខក្រិដ្ឋកម្មសង្គ្រាមគឺធាតុ «ជម្លោះប្រដាប់អាវុធ» ។ ប្រសិនបើព្រះរាជអាជ្ញាមិនអាចបង្ហាញថាមានជម្លោះប្រដាប់អាវុធកើតឡើងនៅពេលមានទង្វើណាមួយទេនោះ ព្រះរាជអាជ្ញានឹងមិនអាចធានាថាអ្វីដែលគាត់បានចោទប្រកាន់នោះជាខក្រិដ្ឋកម្មសង្គ្រាមបានទេ ។ ដើម្បីបង្ហាញថា ការធ្វើមនុស្សឃាតដ៏ច្រើនសន្ធឹកសន្ធាប់និងទង្វើមិនស្របច្បាប់ផ្សេងៗទៀតនៅក្នុងសម័យខ្មែរក្រហមជាខក្រិដ្ឋកម្មសង្គ្រាម ព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញត្រូវតែបង្ហាញថា ជម្លោះប្រដាប់អាវុធក្នុងស្រុកកើតមាននៅកម្ពុជាពីឆ្នាំ១៩៧៥ដល់១៩៧៩ ។ វាមិនទាន់ច្បាស់លាស់នៅឡើយទេដែលថាជម្លោះប្រដាប់អាវុធពិតជាកើតមាននៅក្នុងរបបនោះ ហើយការណ៍នេះបានធ្វើឲ្យមានការលំបាកក្នុងការពន្យល់ថា ការសម្លាប់រង្គាលនិងអំពើព្រៃផ្សៃផ្សេងទៀតនៅក្នុងរបបខ្មែរក្រហមជាលទ្ធផលនៃខក្រិដ្ឋកម្មសង្គ្រាម ។ ខក្រិដ្ឋកម្មសង្គ្រាមប្រហែលជាជម្រើសមួយដែលអាចលើកយកមកចោទប្រកាន់ទៅលើសកម្មភាពទាំងឡាយដែលបានប្រព្រឹត្តចំពោះ

ជនជាតិវៀតណាម នៅក្នុងអំឡុងពេលដែលវៀតណាមវាយលុកចូលទឹកដីកម្ពុជានៅដើមឆ្នាំ១៩៧៩ ។

***ចំណុចច្បាប់ដែលត្រូវត្រួតពិនិត្យមើល និងការព្រួយបារម្ភផ្សេងៗទៀត***

តាមពិតបញ្ហាចំពោះមុខដែលគួរឲ្យព្រួយបារម្ភសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនៅពេលបច្ចុប្បន្ននេះគឺជាបញ្ហាថវិកា ។ តម្លៃប៉ាន់ស្មានសរុបនៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញសម្រាប់រយៈពេលបីឆ្នាំគឺប្រមាណជា៦០លានដុល្លារសហរដ្ឋអាមេរិក ហើយប្រទេសជប៉ុនបានសន្យាថានឹងចំណាយប្រមាណពាក់កណ្តាលនៃថវិកាសរុប ។

បើតាមទស្សនវិស័យច្បាប់ ដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនឹងអាចរួមចំណែកដល់ការវិវត្តនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនិងទ្រឹស្តីនៃការទទួលខុសត្រូវ ។ ទ្រឹស្តីពីរនៃការទទួលខុសត្រូវដែលនឹងវិវត្តតាមរយៈដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញគឺ «ការទទួលខុសត្រូវចំពោះការចេញបញ្ជា (command responsibility)» និង «ការទទួលខុសត្រូវរួម (joint criminal enterprise)» ។ «ការទទួលខុសត្រូវចំពោះការចេញបញ្ជា» ជារបៀបដែលបានអនុវត្តជាយូរមកហើយ ដែលក្នុងនោះមេដឹកនាំត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់អ្នកក្រោមបង្គាប់បញ្ជារបស់ខ្លួន ។ ទ្រឹស្តីនេះជាទូទៅត្រូវបានអនុវត្តនៅក្នុងបរិបទយោធា ប៉ុន្តែទ្រឹស្តីនេះអាចអនុវត្តនៅក្នុងបរិបទទូលាយផ្សេងៗទៀត ដោយយោងទៅតាមស្ថានភាពជាក់ស្តែងនិងពេលវេលា ។ «ការទទួលខុសត្រូវរួម» ជាទ្រឹស្តីអរូបី ។ នៅមានការវិវត្តន៍ច្រើនទៀតសម្រាប់ទ្រឹស្តីនិងការអនុវត្តទ្រឹស្តីនេះ ។ ខ្លឹមសារជាមូលដ្ឋានគឺថាអង្គការឧក្រិដ្ឋកម្មមួយដែលមានសមាជិកមួយក្រុម ហើយសមាជិកទាំងនេះត្រូវទទួលខុសត្រូវរួមគ្នា ហើយមានមួយចំនួនដែលត្រូវទទួលខុសត្រូវចំពោះសមាជិកដទៃទៀត ។ ខ្លឹមសារមួយនេះកំពុងតែត្រូវបានអនុវត្តនិងវិវត្តយ៉ាងទៀងទាត់នៅចំពោះមុខសាលាជំនុំជម្រះក្តីអន្តរជាតិ និងសាលាជំនុំជម្រះក្តីចម្រុះដែលបានបង្កើតកន្លងមក ។

**អូប្រ៊ី អារដេម៉ា**

# ការអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា៖ សម្រាប់ការផ្សះផ្សាជាតិនិងការកសាងសន្តិភាព

***គោលបំណង***

គំនិតចម្បងនៃនិក្ខេបបទនេះគឺផ្តោតទៅលើការស្វែងរកវិធីបង្កើតសន្តិភាពនៅប្រទេសកម្ពុជាតាមរយៈការអប់រំ ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ខ្មែរក្រហមបានចាប់ផ្តើមសាបព្រោះគំនិតនៃការរើសអើងនៅក្នុងចំណោមប្រជាជនកម្ពុជាតាមរយៈញុះញង់ឲ្យជនក្រីក្រប្រឆាំងនឹងក្រុមដែលខ្លួនគិតថាជាក្រុមជិះជាន់កេងប្រវ័ញ្ច (ដែលអ្នកទាំងនោះរួមមានដូចជា អ្នកមានចំណេះដឹងខ្ពស់ ជនស៊ីវិល័យ អ្នកមានទ្រព្យសម្បត្តិច្រើន និងអ្នករដ្ឋការនានាដែលបម្រើឲ្យរបបមុន) ។ នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានឈ្នះសង្គ្រាម ហើយបានគ្រប់គ្រងប្រទេសកម្ពុជារហូតដល់ឆ្នាំ១៩៧៩ ។ ក្នុងអំឡុងពេលជាងបីឆ្នាំនៃការគ្រប់គ្រងរបស់របបនេះ មនុស្សជិតពីរលាននាក់បានបាត់បង់ជីវិត ។ ខ្មែរក្រហមបានគាំទ្រជាផ្លូវការឲ្យកម្មាភិបាលរបស់ខ្លួនប្រព្រឹត្តអំពើហិង្សាទៅលើជនដែលមានឋានៈជាអ្នកជិះជាន់កេងប្រវ័ញ្ច ។ ចំពោះរបបខ្មែរក្រហមការឲ្យនិយមន័យទៅលើពាក្យថា «អំពើហិង្សា» គឺសំដៅទៅលើការបំផ្លិចបំផ្លាញការធ្វើបដិវត្តន៍របស់សត្រូវរបស់របបនេះទាំងស្រុងតែម្តង ។

***បទពិសោធន៍ផ្ទាល់របស់ខ្ញុំ***

នៅពេលដែលខ្ញុំអាយុ៨ឆ្នាំ ដោយថៃដន្យខ្ញុំបានឃើញមនុស្សជាច្រើនដើរនៅលើផ្លូវដោយមានកាន់ដំបងនិងផ្ទាំងក្រដាសដែលមានសរសេរអក្សរថា «កម្ទេចឲ្យអស់ពួក ប៉ុល ពត, អៀង សារី, ខៀវ សំផន និងដៃជើងរបស់វា» ។ នៅពេលដែលខ្ញុំសួរទៅ

ម្តាយរបស់ខ្ញុំគាត់បាននិយាយប្រាប់ខ្ញុំថា "ប្រជាជនកំពុងតែប្រារព្ធពិធីចងកំហឹងនៅគុកទួលស្លែង" ។ ខ្ញុំសួរគាត់បន្តទៀតថា "ចុះហេតុអ្វីបានជាប្រជាជនចាំបាច់កាន់ដំបងព្រនង់អ្វីចឹង?" គាត់ក៏ឆ្លើយថា "ទុកសម្រាប់វាយពួកប៉ុលពត" ។

ចាប់ពីឆ្នាំ១៩៨៤ដល់ឆ្នាំ១៩៨៩ ក្នុងពេលដែលខ្ញុំកំពុងសិក្សានៅថ្នាក់បឋមសិក្សា ភាគច្រើននៃអ្វីដែលខ្ញុំបានអាននិងសិក្សាគឺការធ្វើទារុណកម្មនិងការសម្លាប់រង្គាលនៅក្នុងរបបខ្មែរក្រហមដែលមានបោះពុម្ពផ្សាយនៅក្នុងសៀវភៅសិក្សា ។ ភាគច្រើននៅក្នុងកំណាព្យ ចម្រៀង និងសៀវភៅសិក្សាផ្សេងៗ គឺតែងតែបញ្ចប់ទៅជាមួយនឹងឃ្លាថា "យើងសន្យាថា យើងនឹងវាយបណ្តេញបន ប៉ុល ពត, អៀង សារី, អៀង សារី និងបរិវារចេញពីប្រទេស" ។ ការស្អប់ខ្ពើម កំហឹង និងការសងសឹក បានកប់យ៉ាងជ្រៅនៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជា ។

ពីរបបមួយទៅរបបមួយ ដើម្បីបម្រើឲ្យគោលបំណងនយោបាយរបស់ខ្លួន អ្នកដឹកនាំកម្ពុជាតែងតែជំរុញឲ្យប្រជាជនប្រើអំពើហិង្សាបង្កឲ្យមានការស្អប់ខ្ពើម កំហឹងឈឺចាប់ និងការសងសឹក ។ ការពិតនេះបានធ្វើខ្ញុំចាប់អារម្មណ៍ក្នុងការសិក្សាអំពីការអប់រំអំពីសន្តិភាព ។ បើតាមគំនិតរបស់ខ្ញុំទាំងការអប់រំក្រៅប្រព័ន្ធនិងក្នុងប្រព័ន្ធគឺសុទ្ធសឹងតែជាកត្តាសំខាន់សម្រាប់បន្តទម្រង់ប្រវត្តិសាស្ត្រសង្គម និងអាចដើរតួនាទីទាំងក្នុងផ្លូវល្អនិងផ្លូវអាក្រក់ ។ តាមគំនិតអវិជ្ជមាន របបខ្មែរក្រហមនិងរបបកុម្មុយនិស្តបានបង្កឲ្យមានវប្បធម៌នៃអំពើហិង្សា ។ ការស្អប់ខ្ពើមកំហឹងឈឺចាប់និងការសងសឹកចំពោះហេតុការណ៍ទាំងអម្បាលម៉ានបានជ្រួតជ្រាបពេញក្នុងចិត្តនិងបេះដូងរបស់ប្រជាជនកម្ពុជា ។ ផ្ទុយទៅវិញ ការសិក្សាស្រាវជ្រាវបានរកឃើញថាការអប់រំតាមផ្លូវវិជ្ជមានអាចជួយបង្កើតឲ្យមានវប្បធម៌សន្តិភាពនៅក្នុងសង្គមមួយ ។ ខ្ញុំជឿជាក់ថា ការផ្តល់កម្មវិធីអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជាអាចជាជំហានដ៏មានប្រសិទ្ធភាពមួយក្នុងការបំផ្លាញចោលនូវវប្បធម៌នៃអំពើហិង្សានិងគំនិតរើសអើងនៅក្នុងសង្គមកម្ពុជាបាន ។

## កម្មវត្ថុ

កម្មវត្ថុទាំងបីរបស់និក្ខេបបទនេះរួមមានៈ

១) ឆ្លើយតបទៅនឹងសំណួរថា "ហេតុអ្វីបានជាការអប់រំអំពីសន្តិភាពជាកត្តាសំខាន់ចាំបាច់ក្នុងការកសាងសន្តិភាព?"

២) បកស្រាយអំពីការអប់រំអំពីសន្តិភាពបែបណាដែលអាចឲ្យការកសាងសន្តិភាពសម្រេចទៅបាន ។

៣) សិក្សាអំពីគុណសម្បត្តិនៃកម្មវិធីអប់រំអំពីសន្តិភាពនៅប្រទេសកម្ពុជា ។

## យុទ្ធសាស្ត្រក្នុងការសរសេរនិក្ខេបបទ

ពត៌មានដែលប្រើប្រាស់ក្នុងការសរសេរនិក្ខេបបទនេះត្រូវបានប្រមូលមកពីប្រភពជាច្រើន ដែលក្នុងនោះរួមមានបទសម្ភាសន៍ការស្ទាបស្ទង់មតិ ឯកសារខ្មែរក្រហមជាច្រើននិងផែនការនិងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងអប់រំយុវជននិងកីឡានៃប្រទេសកម្ពុជា ។ លើសពីនេះប្រភពពត៌មានដែលដកស្រង់ចេញពីវិបសាយជាច្រើនក៏ជាជំនួយសំខាន់ក្នុងការសរសេរនិក្ខេបបទនេះដែរ ។ ពត៌មានស្នូលដែលបានដកស្រង់ចេញមកនេះគឺមានសារសំខាន់នៅក្នុងចំណុចចម្បងធំៗបីក្នុងសំណេររបស់ខ្ញុំនេះ ។

ទីមួយ ផ្នែកជាច្រើននៃសំណេរនេះដែលសង្កត់ធ្ងន់លើប្រវត្តិសាស្ត្រខ្មែរក្រហមនិងព្រឹត្តិការណ៍ទាក់ទងជាច្រើនទៀតក៏បានប្រើប្រាស់ឯកសារខ្មែរក្រហមការស្ទាបស្ទង់មតិ កាសែតនិងអត្ថបទជាច្រើនទៀត ដែលមានចុះផ្សាយនៅតាមវិបសាយជាច្រើនស្តីអំពីរបបខ្មែរក្រហម និងស្ថានភាពបច្ចុប្បន្ននៅប្រទេសកម្ពុជា ។ លើសពីនេះ ខ្ញុំក៏បានប្រើកិច្ចសម្ភាសន៍ផ្ទាល់ជាមួយនឹងប្រជាជនកម្ពុជាដែលជាសាក្សីនៃរបបខ្មែរក្រហមនេះដែរ ។ ភាគច្រើននៃឯកសារនិងពត៌មានដែលប្រើប្រាស់ក្នុងការនិពន្ធនេះគឺមានការជួយជ្រោមជ្រែងពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ទីពីរ ជំពូកដែលផ្តោតទៅលើការអប់រំស្តីពីសន្តិភាព ខ្ញុំបានប្រើប្រាស់ពត៌មានដែលដកស្រង់ចេញពីសៀវភៅមួយចំនួននិយាយឲ្យចំគឺសៀវភៅដែលមានចំណងជើងថា "ការអប់រំអំពីសន្តិភាព" និពន្ធដោយ អៀន ហារី និង ម៉ារី លី ម៉ូរីសសុន ។ មានពត៌មានជាច្រើន ក៏ត្រូវបានដកស្រង់ចេញពីកាសែតនិងវិបសាយជាច្រើនទៀត ដែលក្នុងនោះក៏មានវិបសាយរបស់អង្គការសហប្រជាជាតិ អង្គការយូនីសេហ្វ និងអង្គការយូណេស្កូជាដើម ។

ចុងក្រោយគឺជំពូកមួយចំនួនដែលសង្កត់ធ្ងន់ទៅលើ "ការ

អប់រំនិងសាសនា នៅកម្ពុជា» ខ្ញុំបានប្រើប្រាស់ព័ត៌មានពីសៀវភៅពីរក្បាលដែលបោះពុម្ពផ្សាយដោយក្រសួងអប់រំយុវជននិងកីឡា ដោយសារសៀវភៅទាំងពីរក្បាលនេះផ្តល់ព័ត៌មានមូលដ្ឋានស្តីអំពីគោលការណ៍និងរបាយការណ៍ប្រចាំឆ្នាំនៃការអប់រំនៅកម្ពុជា ។ ចំពោះព័ត៌មានដែលទាក់ទងនឹងសាសនានៅកម្ពុជាត្រូវបានដកស្រង់ចេញពីសៀវភៅនិងវិបសាយជាច្រើន ។

**មាតិកា**

និក្ខេបបទនេះចែកចេញជា៧ជំពូក÷

១) សេចក្តីផ្តើមៈ ផ្នែកនេះនិយាយអំពីគោលបំណង កម្មវត្ថុ យុទ្ធសាស្ត្រ និង មាតិកា ។

២) ជំពូកទីមួយៈ បង្ហាញអំពីប្រវត្តិនៃជម្លោះនៅប្រទេសកម្ពុជានិងឥទ្ធិពលដែលប៉ះពាល់ដល់សង្គមកម្ពុជាបច្ចុប្បន្ន ។ ផ្នែកនេះក៏មានព័ត៌មានទាក់ទងនឹងផ្នែកទីបីដែលផ្តោតលើការសិក្សាអំពីសន្តិភាព ។

៣) ជំពូកទីពីរៈ សង្កត់ធ្ងន់លើការអប់រំស្តីពីសន្តិភាពដែលចែកចេញជាពីរផ្នែកតូចៗទៀតៈ ផ្នែកទីមួយបកស្រាយថាអ្វីជា «ការអប់រំស្តីពីសន្តិភាព» និងអ្វីជាអត្ថប្រយោជន៍នៃការអប់រំផ្នែកសន្តិភាព ។ ផ្នែកទីពីរគឺជាការលើកឧទាហរណ៍មួយចំនួនស្តីពីការអប់រំសន្តិភាពដែលធ្លាប់បានដាក់ឲ្យអនុវត្តនៅប្រទេសជាច្រើនរួចមកហើយ ។

៤) ជំពូកទីបីៈ គឺជាការបកស្រាយពន្យល់អំពីតួនាទីរបស់ការអប់រំសន្តិភាពនៅក្នុងដំណើរការផ្សះផ្សាបញ្ហានៅក្នុងសង្គមបន្ទាប់ពីឆ្លងកាត់ភ្លើងសង្គ្រាម ។ ក្នុងន័យនេះករណីនៅប្រទេសរ៉ាន់ដានិងប្រទេសហុល្លង់ត្រូវបានលើកយកមកពិភាក្សា ។

៥) ជំពូកទីបួនៈ ការអប់រំសន្តិភាពទាំងប៉ុន្មានដែលបានបកស្រាយនៅក្នុងជំពូកទី៤នឹងយកមកជំនួសនៅក្នុងករណីប្រទេសកម្ពុជាវិញ ព្រមទាំងបង្ហាញអំពីបទពិសោធន៍មួយចំនួននៅប្រទេសដទៃមកអនុវត្តនៅក្នុងកម្មវិធីអប់រំអំពីសន្តិភាពនៅក្នុងកម្ពុជា ។

៦) ជំពូកទីប្រាំៈ នឹងមានការបកស្រាយយ៉ាងល្អិតល្អន់អំពីកម្មវិធីអប់រំអំពីសន្តិភាពនៅកម្ពុជានិងយុទ្ធសាស្ត្របែបណាដែលត្រូវយកមកអនុវត្ត ។

៧) សេចក្តីសន្និដ្ឋានៈ សន្និដ្ឋានទៅលើនិក្ខេបបទនេះ ដោយលើកយកចំណុចសំខាន់ៗ និងផ្តល់យោបល់មួយចំនួនទាក់ទងនឹងការអប់រំនេះ ។

**ជំពូកទី១ៈ ជម្លោះនៅកម្ពុជា**

១) ប្រវត្តិនៃជម្លោះ

ខ្មែរក្រហមបានចូលមកកាន់អំណាចនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៥ ហើយបានបង្កើតជារបបមួយហៅថារបបកម្ពុជាប្រជាធិបតេយ្យ គឺជាការធ្វើបដិវត្តន៍នៃក្រុមកម្មករ ប្រជាជនស្រុកស្រែនិងជនក្រីក្រប្រឆាំងនឹងក្រុមដែលខ្លួនយល់ថាជាក្រុមអ្នកជិះជាន់កេងប្រវ័ញ្ចសង្គម ។ នៅក្នុងសម័យកាលបដិវត្តន៍ជនដែលបានចាត់ទុកថាជាអ្នកជិះជាន់កេងប្រវ័ញ្ចរួមមាន មន្ត្រីរដ្ឋការរបស់របបមុន បញ្ញាជន អ្នកមានទ្រព្យសម្បត្តិច្រើន និងប្រជាជនទីក្រុងដែលអ្នកទាំងអស់នេះត្រូវបានគេចាត់ទុកថាជាឧបសគ្គក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា ។ គោលនយោបាយចម្បងរបស់ខ្មែរក្រហមគឺការផ្លាស់ប្តូរប្រទេសកម្ពុជាទាំងមូលឲ្យទៅជាសង្គមអ្នកស្រែបរិសុទ្ធមួយនិងបំផ្លាញរាល់អំពើពុករលួយទាំងអម្បាលម៉ានដែលមានប្រភពមកពីជីវិតទីក្រុង ។ គោលការណ៍ដ៏សំខាន់បំផុតរបស់របបនេះគឺការបន្សុទ្ធប្រជាជនដែលនេះអាចរកឃើញពីបទសុន្ទរកថារបស់ សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិនៃកម្ពុជាប្រជាធិបតេយ្យ ។ នៅឆ្នាំ១៩៩៧ សុន សេន បានធ្វើសេចក្តីប្រកាសមួយថា កម្ពុជាប្រជាធិបតេយ្យត្រូវតែបោះជំហានទៅមុខក្នុងការ «កសាងសង្គមមួយថ្មី ហើយដើម្បីសម្រេចបាននូវលទ្ធផលនេះ យើងត្រូវការប្រជាជនដែលមានឧត្តមគតិថ្មី ។ ដើម្បីផ្តួចផ្តើមសង្គមបដិវត្តន៍មួយ យើងត្រូវតែរើបម្រះ ។

ចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាត្រូវបានបង្ខំឲ្យរស់នៅតាមសហករណ៍និងធ្វើការនៅតាមវាលស្រែ ។ អ្នកស្រែចម្ការក្លាយជាអ្នកដឹកនាំ ។ អ្នករដ្ឋការរបស់របបមុន បញ្ញាជន អ្នកមានទ្រព្យសម្បត្តិ និងប្រជាជនទីក្រុងត្រូវបានបង្ខំឲ្យធ្វើការងារជាទម្ងន់ដើម្បីគ្រាន់តែបានរបបអាហារបន្តិចបន្តួចប៉ុណ្ណោះ ។ មនោគមវិជ្ជាប្រឆាំងនឹងប្រជាជនកេងប្រវ័ញ្ចត្រូវបានបង្ហាញនៅតាមបទចម្រៀង ពាក្យស្លោក រឿង និងសៀវភៅសិក្សារបស់កុមារ ។ ការរើសអើងចំពោះក្រុមមនុស្សប្រភេទនេះ

មាននៅគ្រប់ទីកន្លែងទាំងអស់ ។ ជាលទ្ធផលប្រជាជនកម្ពុជាជិតពីរលាននាក់នៃចំនួនប្រជាជនសរុប៨លាននាក់បានបាត់បង់ជីវិតដោយសារកង្វះអាហារ ការធ្វើការហួសកម្លាំង ជំងឺ កង្វះជីវជាតិ និងការកាប់សម្លាប់ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំពុំទាន់មានប្រព័ន្ធយុត្តិធម៌ ឬដំណើរការការផ្សះផ្សាជាតិណាមួយនៅកម្ពុជានៅឡើយទេ ។ នៅចន្លោះឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩១អារម្មណ៍នៃការស្អប់ខ្ពើម ការឈឺចាប់ និងការសងសឹកចំពោះខ្មែរក្រហម ត្រូវបានបង្វែរតាមរយៈយុទ្ធសាស្ត្រនយោបាយពីសំណាក់របបកុម្មុយនិស្តដែលស្ថិតនៅក្រោមការកាន់កាប់តំណែងរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជា ។ ហេតុដូច្នេះហើយឯកសារជាច្រើនដែលទាក់ទងនឹងការស្អប់ខ្ពើម ការឈឺចាប់ និងការសងសឹកត្រូវបានដាក់បង្ហាញតាមរយៈសៀវភៅសិក្សារបស់កុមារ កំណាព្យ ចម្រៀង ពាក្យស្លោក កន្លែងចងចាំ និងការបង្កើតឲ្យមាន «ទិវាចងកំហឹង» ។

នៅខែតុលា ឆ្នាំ១៩៩១ កិច្ចព្រមព្រៀងសន្តិភាពដែលមានការឧត្ដម្ភពីអង្គការសហប្រជាជាតិ ត្រូវបានធ្វើឡើងដោយមានចុះហត្ថលេខាពីសំណាក់គ្រប់ភាគីបក្សនយោបាយទាំងអស់នៅកម្ពុជាដើម្បីបញ្ឈប់សង្គ្រាម ។ ការបោះឆ្នោតជាតិមួយក៏ត្រូវបានធ្វើឡើងជាសន្សឹមៗនៅក្នុងខែឧសភា ឆ្នាំ១៩៩៣ ។ ខ្មែរក្រហមដែលជាហត្ថលេខីមួយនៃកិច្ចព្រមព្រៀងសន្តិភាពបានដកខ្លួនចេញពីការបោះឆ្នោត ហើយបន្តបង្កឲ្យមានសង្គ្រាមរ៉ាំរ៉ៃនៅកម្ពុជារហូតដល់ឆ្នាំ១៩៩៩ ។

ដើម្បីបញ្ឈប់សង្គ្រាមស៊ីវិលនៅកម្ពុជា នៅទសវត្សរ៍ឆ្នាំ១៩៩០ រដ្ឋាភិបាលកម្ពុជាបានចាប់ផ្ដើមបង្កើតឲ្យមានដំណើរការការទូតមួយឲ្យឈ្មោះថា «គោលនយោបាយឈ្នះៗ» ដើម្បីផ្ដល់ការលើកលែងទោសដល់ខ្មែរក្រហមដែលប៉ុនប៉ងចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា ។ អៀង សារី អតីតរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបខ្មែរក្រហមនិងកម្មាភិបាលខ្មែរក្រហមជាច្រើនរូបទៀត ក៏ត្រូវបានផ្ដល់ការលើកលែងទោសដែរ ។

នៅខែមិថុនា ឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំអង្គការសហប្រជាជាតិជួយបង្កើតឲ្យមានតុលាការមួយដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមដែលបានប្រព្រឹត្តការកាប់សម្លាប់ចាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ការពិភាក្សាជាច្រើនរវាងទីប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ ហេន កូរែល និងឧបនាយករដ្ឋមន្ត្រី សុខ អាន បាននាំឲ្យមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងចុងក្រោយស្ដីពីច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមនៅខែមិថុនា ឆ្នាំ២០០៣ កន្លងទៅនេះ ។ ពេលនោះកិច្ចព្រមព្រៀងនៅរង់ចាំតែសេចក្ដីអនុម័តពីសភាជាតិកម្ពុជាប៉ុណ្ណោះ ។

## ២) កេរដំណែលប្រវត្តិសាស្ត្រ

រយៈពេល២៥ឆ្នាំបន្ទាប់ពីសង្គ្រាមផុតរលត់ទៅ ប្រជាជនកម្ពុជានៅតែរស់នៅជាមួយនឹងការឈឺចាប់ ហើយមកទល់នឹងពេលនេះមិនទាន់មានដំណើរការផ្សះផ្សាជាក់លាក់ណាមួយត្រូវបានធ្វើឡើងសម្រាប់ប្រជាជនកម្ពុជានៅឡើយទេ ។ ទាំងជនដៃដល់និងជនរងគ្រោះគឺរស់នៅក្នុងភូមិជាមួយគ្នា ។ ម្យ៉ាងវិញទៀតដំណើរការតុលាការដែលកំពុងប្រព្រឹត្តទៅជាបណ្ដើរៗនេះដែលគ្រាន់តែនឹងកាត់ទោសតែមេដឹកនាំមួយចំនួនតូចមិនអាចផ្សះផ្សារវាងជនដៃដល់និងជនរងគ្រោះ ក៏ដូចជាស្នាមរបួសយ៉ាងជ្រៅរបស់ជនរងគ្រោះបានឡើយ ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅជនរងគ្រោះមួយចំនួនបានក្លាយទៅជាជនដៃដល់ អតីតកម្មា-ភិបាលខ្មែរក្រហមមួយចំនួនត្រូវជនរងគ្រោះសម្លាប់និងមានមួយចំនួនទៀតត្រូវបានចាប់ខ្លួនដោយរាជរដ្ឋាភិបាលកម្ពុជា ។

ដោយគ្មានដំណើរការផ្សះផ្សានៅក្នុងប្រទេស ។ អតីតរបបកុម្មុយនិស្តកម្ពុជាបានជំរុញឲ្យប្រជាជនរើសអើងចំពោះអតីតសមាជិកខ្មែរក្រហម ។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជាបានបែងចែកប្រជាជនកម្ពុជាជាពីរផ្នែក គឺជនរងគ្រោះនៃរបបខ្មែរក្រហមនិងកម្មាភិបាលខ្មែរក្រហម ដែលមកដល់បច្ចុប្បន្ននេះក្រុមទាំងពីរត្រូវបានទទួលស្គាល់ថាសុទ្ធសឹងតែទទួលរងនូវស្នាមរបួសដូចៗគ្នា ។ ជនដៃដល់មួយចំនួនភ័យខ្លាចនិងអាម៉ាស់ចំពោះជនរងគ្រោះដែលពោរពេញទៅដោយកំហឹង ការស្អប់ខ្ពើម និងការសងសឹក ។ តាមលក្ខណៈនេះ ឥរិយាបថនិងអារម្មណ៍ត្រូវបានផ្ទេរមកឲ្យកូនចៅជំនាន់ក្រោយរបស់ជនរងគ្រោះនិងជនដៃដល់ដោយមិនដឹងខ្លួន ។

វ៉ាន់ ណាត អតីតអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោស ៧នាក់ដែលបានរួចរស់ជីវិតពីគុកទួលស្លែង (ស-២១) ធ្លាប់ត្រូវខ្មែរក្រហមចាប់ដាក់គុកនិងធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ។ វ៉ាន់ ណាត អាចរួចជីវិតបានដោយសារតែជំនាញគូររូបរបស់គាត់ ។ វ៉ាន់ ណាត និយាយថា «សម្រាប់ខ្ញុំជាជនរងគ្រោះ ខ្ញុំមិនអាចបំភ្លេចបានទេ ពីព្រោះយើងនៅតែយល់សប្តិអាក្រក់ជាប់ជានិច្ច... ។ អ្នកដឹងទេថាទាំងយប់ទាំងថ្ងៃខ្ញុំបន់តែទេវតា ឲ្យតែមេឃភ្លឺ ហើយអរគុណទេវតាដែលផ្តល់ជីវិតឲ្យរស់បានមួយយប់ទៀត ។ ដល់ពេលយប់អរគុណទេវតាទៀតហើយដែលផ្តល់ជីវិតឲ្យបានរស់មួយថ្ងៃទៀត ។ សូមជួយឲ្យយើងបានដេកលង់លក់ទៅដោយសុខស្រួលផងទៅចុះ ។ ប៉ុន្តែមិនអ៊ីចឹងទេ ខ្ញុំនៅជាមួយនឹងសុបិនអាក្រក់ៗជារៀងរហូត» ។

នៅតាមបណ្តាភូមិនានានៅក្នុងប្រទេសកម្ពុជា អតីតកម្មាភិបាលខ្មែរក្រហមនិងជនរងគ្រោះនៃរបបនេះរស់នៅក្នុងភូមិផងរបងជាមួយគ្នា ។ វាច្បាស់ណាស់ថា ជនរងគ្រោះមិនអាចបំភ្លេចបាននូវអ្វីដែលអតីតកម្មាភិបាលខ្មែរក្រហមទាំងនោះបានប្រព្រឹត្តចំពោះខ្លួនឡើយ ។ តាមរយៈបទសម្ភាសន៍មួយជាមួយបុរសម្នាក់ឈ្មោះ អ៊ឹន ញ៉ាន ដែលបានបាត់បង់កូនប្រុសពីរនាក់នៅក្នុងរបបខ្មែរក្រហម គាត់បាននិយាយថា «ខ្ញុំនៅតែខឹងឥឡូវហ្នឹងរាល់ពេលដែលខ្ញុំឃើញកម្មាភិបាលទាំងនោះម្តងៗ ។ អតីតខ្មែរក្រហមទាំងនោះនៅរស់ដល់សព្វថ្ងៃនិងមិនមានខ្វល់រវល់អ្វីទាំងអស់ ហើយដើរកាត់មុខផ្ទះខ្ញុំរាល់ថ្ងៃ» ។ បុរសម្នាក់នេះមិនបានដឹងច្បាស់ថានរណាម្នាក់ជាអ្នកសម្លាប់កូនៗរបស់គាត់ទេ ប៉ុន្តែគាត់គ្រាន់តែនិយាយពីកំហឹងឈឺចាប់របស់គាត់និងការប៉ុនប៉ងចង់សងសឹកអតីតខ្មែរក្រហមតែប៉ុណ្ណោះ ។

លោកស្រី ជា វ៉ាន់ណាត នាយិកាមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម បានផ្តល់មតិចំពោះគំនិតរបស់ប្រជាជនកម្ពុជាចំពោះអតីតខ្មែរក្រហមដូចខាងក្រោម÷

ទាក់ទិននឹងរឿងខ្មែរក្រហម ប្រជាជនមានការឈឺចាប់ចំពោះរបបនេះខ្លាំងណាស់ ពីព្រោះគាត់មានអារម្មណ៍ថាខ្មែរក្រហមបានប្រព្រឹត្តអំពើយង់ឃ្នងជាច្រើនប៉ុន្តែមិនដែលទទួលកំហុសហើយក៏មិនដែលសុំអភ័យទោសចំពោះអំពើរបស់ខ្លួនទេ ។

ទន្ទឹមនឹងនេះ មានកម្មាភិបាលថ្នាក់ក្រោមជាច្រើននៃរបបខ្មែរក្រហមបានចាត់ទុកខ្លួនជាជនរងគ្រោះនៃរបបនេះដូចប្រជាជនកម្ពុជាទូទៅដទៃទៀតដែរ ។ ឧទាហរណ៍ អតីតកម្មាភិបាលទាំងនោះត្រូវបានបង្ខំឲ្យរស់នៅផ្សេងពីក្រុមគ្រួសារ ហើយសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនេះជាច្រើនក៏ត្រូវបានសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ កម្មាភិបាលទាំងនេះបាននិយាយថា ខ្លួនត្រូវតែប្រព្រឹត្តតាមបញ្ជារបស់អង្គការ (មេដឹកនាំនៃរបបខ្មែរក្រហម) ប្រសិនបើចង់រួចជីវិត ។ ការណ៍នេះផ្ទុយស្រឡះពីការស្ទាបស្ទង់មតិចំពោះកម្មាភិបាលថ្នាក់ក្រោមនៃរបបខ្មែរក្រហមដែលមានចុះផ្សាយនៅក្នុងទស្សនាវដ្តី «ស្វែងរកការពិត» គឺមានតែ២៩,៩៥ភាគរយប៉ុណ្ណោះដែលយល់ស្របថាកម្មាភិបាលថ្នាក់ក្រោមក៏ជាជនរងគ្រោះ ហើយមានតែ២៣,៨៩ភាគរយ ដែលចាត់ទុកថាជាជនដៃដល់ ។ គួរឲ្យចាប់អារម្មណ៍មាន៤១,២៩ភាគរយយល់ថាកម្មាភិបាលថ្នាក់ក្រោមជាជនរងគ្រោះផងនិងជាជនដៃដល់ផង ។ នៅក្នុងសំណួរមួយនៃការស្ទាបស្ទង់មតិនេះសួរថា «តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះកម្មាភិបាលថ្នាក់ក្រោមដែលជាជនដៃដល់?» មាន១៦,៦០ភាគរយបានឆ្លើយថា ខ្លួនមានការអាណិតអាសូរនៅពេលដែលមានដល់ទៅ៥៣,៨៥ភាគរយឆ្លើយថា មិនមានការអាណិតអាសូរចំពោះបុគ្គលទាំងអស់នោះទេ ។ មកទល់នឹងពេលនេះមិនទាន់មានការផ្តល់ឱកាសណាមួយសម្រាប់ទាំងជនរងគ្រោះនិងជនដៃដល់ស្វែងយល់អំពីគ្នាទៅវិញទៅមកនៅឡើយទេ ។

ជាទូទៅយើងអាចមើលឃើញថា មិនមែនមានតែជនដៃដល់ទេដែលប្រឈមមុខនឹងការភ័យខ្លាច ប្រជាជនកម្ពុជាស្លូតត្រង់ជាច្រើនក៏ភ័យខ្លាចចំពោះអំពើខ្មែរក្រហមពីអតីតកាលដែរ ។ រវាងឆ្នាំ១៩៩៦និងឆ្នាំ១៩៩៩ នៅពេលដែលរចនាសម្ព័ន្ធរបស់ខ្មែរក្រហមត្រូវបានបំបែកទាំងស្រុង កម្មាភិបាលរាប់រយរាប់ពាន់អ្នកបានវិលត្រឡប់មករស់នៅភូមិកំណើតរបស់ខ្លួនវិញ ។ អតីតតំបន់ខ្មែរក្រហមក៏បានបើកចំហសម្រាប់ប្រជាជនកម្ពុជាទៅរស់នៅដែរ ។ ដោយមូលហេតុនេះហើយបានជាមានជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហមជាច្រើនកំពុងរស់នៅលាយឡំគ្នាទាំងមិនស្ងប់អារម្មណ៍ គឺរស់នៅក្នុងភាពភ័យខ្លាចចំពោះគ្នា

នៅវិញទៅមក ។

ស្ត្រីម្នាក់ឈ្មោះ យ៉ាន បានមកតាំងទីលំនៅនៅលើអតីតតំបន់ខ្មែរក្រហម ដែលនៅទីនោះគាត់មានអ្នកជិតខាងជាអតីតកម្មាភិបាលខ្មែរក្រហម ។ យ៉ាន បានអះអាងថាគាត់ត្រូវរស់នៅប្រឈមមុខនឹងភ័យខ្លាចជារៀងរាល់ថ្ងៃ ។ គាត់ព្យាយាមទប់អារម្មណ៍ចំពោះការភិតភ័យទាំងនោះហើយសម្របខ្លួនជាមួយអ្នកជិតខាងរបស់គាត់ ទោះបីគាត់ដឹងថា អ្នកទាំងនោះនឹងត្រូវកាត់ទោសតាមផ្លូវច្បាប់ជាពីបទសម្លាប់មនុស្សមិនខាន ។ យ៉ាន នៅតែរក្សាភាពស្ងប់ស្ងាត់ដោយសារគាត់ភ័យខ្លាចថា អតីតខ្មែរក្រហមទាំងនោះនឹងប្រព្រឹត្តបទឧក្រិដ្ឋបន្ថែមទៀត ។ ពាក្យចុងក្រោយនៃបទសម្ភាសន៍ជាមួយស្ត្រីនេះគាត់បាននិយាយថា «ដឹងទេថាពួកនេះធ្លាប់សម្លាប់មនុស្សណា!» ។

ការភ័យខ្លាចរបស់ជនរងគ្រោះមិនមែនមានតែចំពោះជនដែលដល់តែឯងនោះទេ ប៉ុន្តែគឺកូនចៅរបស់ជនដែលដល់ទាំងនោះទៀត ដោយសារថាមនុស្សជំនាន់ក្រោយទាំងនោះទទួលឥទ្ធិពលនៃភាពឃោរឃៅពីអតីតកាលរបស់ឪពុកម្តាយ ។ ចាប់តាំងពីមានហេតុការណ៍ប្រវត្តិសាស្ត្រនេះមក កូនចៅជំនាន់ក្រោយរបស់អតីតខ្មែរក្រហមត្រូវបានរើសអើង ។ នៅក្នុងសំណួរមួយទៀតដែលដកស្រង់ចេញពីការស្ទាបស្ទង់មតិរបស់ទស្សនាវដ្តី «ស្វែងរកការពិត» ដែលសួរថា «ប្រសិនបើអ្នកដឹងថាកូនចៅរបស់អ្នកដែលបានសម្លាប់ឪពុកម្តាយឬសាច់ញាតិរបស់អ្នកជាមិត្តរួមថ្នាក់នឹងកូនៗរបស់អ្នក តើអ្នកនឹងប្រាប់ឲ្យកូនចៅរបស់អ្នករើសអើងនឹងកូនចៅអ្នកទាំងនោះដែរទេ?» មាន៦៧,៧០ភាគរយឆ្លើយថា «ទេ» ដោយមូលហេតុថាខ្លាចកូនចៅជនដែលដល់ទាំងនោះនឹងសងសឹកចំពោះកូនចៅរបស់ខ្លួននៅថ្ងៃណាមួយវិញ ។

កាលពីអាយុ៦ឆ្នាំ អៀ ម៉េងទ្រី ចងចាំថា ម្តាយរបស់គាត់ប្រាប់គាត់កុំឲ្យទៅលេងជាមួយក្មេងៗដែលមានឪពុកម្តាយជាអតីតខ្មែរក្រហម ។ ការពន្យល់របស់ម្តាយ ម៉េងទ្រី គឺ បើហ៊ានលេងជាមួយក្មេងទាំងនោះ នៅពេលដែលមានជម្លោះឪពុកម្តាយរបស់ក្មេងទាំងនោះនឹងវាយគាត់ជាមិនខានដោយសារគាត់យល់ថា «ក្មេងៗទាំងនោះជាក្មេងអាក្រក់ ព្រោះជាកូនចៅរបស់មនុស្សអាក្រក់» ។

សព្វថ្ងៃនេះប្រជាជនកម្ពុជាចែកចេញជាពីរផ្នែក គឺអតីតសមាជិកនៃរបបខ្មែរក្រហម និងជនរងគ្រោះនៃរបបនេះ ។ ការបែងចែកនេះមិនមែនមានតែចំពោះមនុស្សចាស់ៗដែលបានឆ្លងកាត់របបខ្មែរក្រហមនោះទេ ប៉ុន្តែរួមទាំងកូនចៅជំនាន់ក្រោយដែរ ។ ទន្ទឹមនឹងពេលដែលមានការចាប់ផ្តើមបង្កើតដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរ ក៏មានការព្រួយបារម្ភជាច្រើនខ្លាចក្រែងតុលាការនេះនឹងរើរើដំបៅចាស់ដែលនឹងគំរាមកំហែងសុវត្ថិភាពប្រជាជនកម្ពុជាជាថ្មីម្តងទៀត ។ ដោយមូលហេតុនេះដើម្បីបញ្ជាក់ថាមានសន្តិភាពចំពោះប្រជាជនកម្ពុជាដំណើរការមួយទៀតផ្សេងពីតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគួរតែត្រូវបានបង្កើតដើម្បីព្យាបាលរបួសផ្លូវចិត្តក៏ដូចជាផ្លាស់ប្តូរការគិតរបស់ប្រជាជនកម្ពុជាចំពោះគ្នាទៅវិញទៅមកដែរ ។

ដោយក្តីសង្ឃឹមជឿជាក់ ការអប់រំអំពីសន្តិភាព (ឬហៅថាការអប់រំដើម្បីផ្លាស់ប្តូរសង្គម) អាចជួយស្តារភាពនៅក្នុងប្រទេសកម្ពុជាឲ្យបានប្រសើរឡើង ។

ជំពូកបន្ទាប់នឹងបង្ហាញអំពីទ្រឹស្តីនៃការអប់រំអំពីសន្តិភាពចេញពីបទពិសោធន៍ប្រទេសដទៃនិងនៅក្នុងសង្គមកម្ពុជា ។

**(នៅមានត)**

**គីម កែវកន្និដ្ឋា**


# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# កិច្ចព្រមព្រៀងបង្កើតបណ្ណសារប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ នៅសាកលវិទ្យាល័យរ៉ាត់ហ្គើ-ញូវ៉ាក

កិច្ចព្រមព្រៀងមួយរវាងសាកលវិទ្យាល័យរ៉ាត់ហ្គើ-ញូវ៉ាក (រដ្ឋញូជឺស៊ី) និងអង្គការសិទ្ធិមនុស្សមួយនៅកម្ពុជា បានធ្វើឲ្យសាកលវិទ្យាល័យនេះក្លាយជាសាកលវិទ្យាល័យមួយក្នុងចំណោមសាកលវិទ្យាល័យពីរនៅសហរដ្ឋអាមេរិកដែលដើរតួនាទីជាកន្លែងសម្រាប់តម្កល់ឯកសារនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

កិច្ចព្រមព្រៀងរវាងមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាកលវិទ្យាល័យខាងលើមានលក្ខណៈដូចកិច្ចព្រមព្រៀងមួយដែលបានបញ្ចប់រួចមកហើយរវាងមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាកលវិទ្យាល័យយែលដែលថែរក្សាឯកសារខ្មែរក្រហមមួយចំណែក ។ កិច្ចព្រមព្រៀងនេះបានបង្កើតជាបណ្ណសារមួយដ៏មានតម្លៃនិងថែរក្សាឯកសារដើមនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងទម្រង់ជាសម្ភារឌីជីថលនិងមីក្រូហ្វីល ។ ឯកសារទាំងនេះនឹងផ្តល់ភាពងាយស្រួលយ៉ាងច្រើនដល់និស្សិតសាកលវិទ្យាល័យរ៉ាត់ហ្គើ-ញូវ៉ាកក្នុងការសិក្សាស្រាវជ្រាវ ក៏ដូចជាផ្តល់ភាពងាយស្រួលដល់អ្នកស្រាវជ្រាវជាន់ខ្ពស់និងអ្នកស៊ើបអង្កេតទាំងឡាយនៅទូទាំងលោកខាងលិច ។ បណ្ណសារនេះមានផ្ទុកឯកសារដូចជានិក្ខេបបទ រូបថត ខ្សែភាពយន្ត និងឯកសារផ្សេងៗទៀតដែលជាប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍របស់របបកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥ដល់១៩៧៩ ដែលបានសម្លាប់ប្រជាជនអស់ស្ទើរតែមួយភាគបួននៃចំនួនប្រជាជនកម្ពុជាសរុប៨លាននាក់ ។

ភាពជាដៃគូរវាងសាកលវិទ្យាល័យរ៉ាត់ហ្គើ-ញូវ៉ាកនិងមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាការរំឭកដល់ខួបលើកទី៣០នៃការឡើងកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យនិងការរៀបចំនាពេលថ្មីៗរបស់កម្ពុជាក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដើម្បីជំនុំជម្រះទោសអ្នកដែលបានបង្កើតជា«របបវាលពិឃាត»នៅកម្ពុជា ។ ឯកសារភាគច្រើននៅក្នុងបណ្ណសារនេះនឹងត្រូវប្រើប្រាស់ជាភស្តុតាងនៅក្នុងសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ ។

ស្ទីវិន ដាញូន័រ នាយកសាកលវិទ្យាល័យរ៉ាត់ហ្គើ-ញូវ៉ាក បានកត់សម្គាល់ថា «នៅក្នុងការបង្កើតគម្រោងដែលផ្តោតលើសិទ្ធិមនុស្សដ៏មានសារសំខាន់មួយនេះ សាកលវិទ្យាល័យរ៉ាត់ហ្គើ-ញូវ៉ាកកំពុងតែពង្រឹងតួនាទីរបស់ខ្លួនជាមជ្ឈមណ្ឌលសំខាន់មួយក្នុងការអប់រំជាសកលនិងការវិវត្តនៃនយោបាយសាធារណៈអន្តរជាតិ ។ ទីតាំងរបស់សាកលវិទ្យាល័យរ៉ាត់ហ្គើ-ញូវ៉ាកប្រហែលជាមិនល្អដូចនៅក្នុងទីក្រុងញូវយ៉កឬតំបន់ប្រជុំជនរបស់រដ្ឋញូជឺស៊ីទេ ប៉ុន្តែទីតាំងនេះស្ថិតនៅចំកណ្តាលតំបន់មួយដែលមានប្រជាជនមកពីផ្នែកផ្សេងៗនៃពិភពលោក» ។

បន្ថែមពីលើឱកាសក្នុងការសិក្សាស្រាវជ្រាវពីរបបកម្ពុជាប្រជាធិបតេយ្យដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបាននាំទៅផ្តល់ជូនប្រទេសលោកខាងលិច មជ្ឈមណ្ឌលឯកសារកម្ពុជាក៏នឹងផ្តល់ឱកាសឲ្យនិស្សិតជម្រើសរបស់សាកលវិទ្យាល័យរ៉ាត់ហ្គើដែលមានចំណាប់អារម្មណ៍នឹងរបបកម្ពុជាប្រជាធិបតេយ្យបានមកធ្វើស្ម័គ្រចិត្តឬធ្វើការស្រាវជ្រាវទាំងនៅការិយាល័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងសាកលវិទ្យាល័យរ៉ាត់ហ្គើនិងនៅការិយាល័យកណ្តាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងប្រទេសកម្ពុជា ។

ការិយាល័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅសហរដ្ឋអាមេរិកក៏នឹងផ្តល់ឱកាសឲ្យបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដូចជា អៀ ម៉េងទ្រី និង ហ៊ុយ វណ្ណៈ ដែលកំពុងសិក្សាថ្នាក់អនុបណ្ឌិតនិងបណ្ឌិតផ្នែក «ការសិក្សាអំពីសកលលោក» នៅសាកលវិទ្យាល័យរ៉ាត់ហ្គើ-ញូវ៉ាក ឯកសារ «បំប្រែបំប្រួលនៃសកលលោកនិងការដឹកនាំ» បង្ហាញនិងរៀបចំការពិភាក្សាជាមួយនិស្សិតនៅសាកលវិទ្យាល័យអំពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យច្បាប់អន្តរជាតិនិងប្រធានបទទាក់ទងដទៃទៀត ។

កិច្ចព្រមព្រៀងត្រូវបានបង្កើតឡើងដោយមានការរួមចំណែករបស់សាស្ត្រាចារ្យផ្នែកនរវិទ្យានៃសាកលវិទ្យាល័យរ៉ាត់ហ្គើ-ញូវ៉ាក គឺលោក អាឡិកសាន់ដឺ ហ៊ីនតុន ខណៈពេលដែលគាត់កំពុងតែសិក្សាស្រាវជ្រាវសៀវភៅមួយដែលទើបតែចេញផ្សាយនៅពេលថ្មីៗនេះ ។ សៀវភៅនេះមានចំណងជើងថា «ហេតុអ្វីបានជាសម្លាប់មនុស្ស?: កម្ពុជាក្នុងស្រមោលនៃអំពើប្រល័យពូជសាសន៍» ។ គាត់បានជួបលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលកំពុងសិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា ។

ទស្សនៈក្រាញនៀលរបស់ប្រជាពលរដ្ឋកម្ពុជាដែលថាពលរដ្ឋរបស់ខ្លួនមិនអាចធ្វើការងារដូចខាងលើនេះ បានកែប្រែទិសដៅនៃការស្រាវជ្រាវរបស់ ហ៊ីនតុន ដោយគាត់បានចាប់ផ្តើមងាកទៅរកការស្រាវជ្រាវអំពីប្រល័យពូជសាសន៍ផ្សេងៗនៅទូទាំងសកលលោក ។ ហ៊ីនតុន បានសញ្ជឹងគិតថា តើអំពើប្រល័យពូជសាសន៍កើតឡើងយ៉ាងដូចម្តេច? តើអ្វីដែលអាចជំរុញមនុស្សឲ្យប្រព្រឹត្តទង្វើយង់ឃ្នងយ៉ាងនេះ?

បទពិសោធន៍ផ្ទាល់ខ្លួនរបស់លោក ឆាំង យុ ដែលធ្លាប់ឆ្លងកាត់ការធ្វើទារុណកម្មនិងការដាក់ពន្ធនាគារដោយយោធាខ្មែរក្រហម បានជំរុញឲ្យគាត់ប្រមូលឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលឥឡូវនេះត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជានិងនៅការិយាល័យរបស់មជ្ឈមណ្ឌលនៅសហរដ្ឋអាមេរិក ។

លោកនាយកបាននិយាយថា «ទាំងនេះជាការប្តេជ្ញាចិត្តរបស់ខ្ញុំដោយសារតែបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនមិនយល់អំពីអ្វីដែលបានកើតឡើងនៅក្នុងរបបនេះទេ ។ ការខកខានមិនបានពន្យល់អំពីអ្វីដែលបានកើតឡើងធ្វើឲ្យខ្ញុំមានអារម្មណ៍មិនស្រណុកចិត្តទាល់តែសោះ ។ សម្រាប់ខ្ញុំ ទាំងអស់នេះមិនមែនត្រឹមតែដើម្បីពលរដ្ឋកម្ពុជានោះទេ ប៉ុន្តែដើម្បីភាពជាមនុស្សទាំងអស់គ្នា» ។

## សេចក្តីប្រកាសរកបងប្រុសពីរនាក់


ថោង សុវណ្ណផល្លា

នាងខ្ញុំឈ្មោះ ថោង សុវណ្ណផល្លា ឪពុកឈ្មោះ ថោង ប៊ូ ម្តាយឈ្មោះ សំ សារិន ។ នាងខ្ញុំមានបងប្អូន៤នាក់ៈទី១)បងប្រុស (មិនចាំឈ្មោះ), ទី២ ពៅ (ប្រុស) ទី៣) រូបខ្ញុំ និង ទី៤) ថោង សុវណ្ណផល្លី (ស្លាប់) ។ នាងខ្ញុំសូមសួររកបងប្រុសទី១និងទី២ ដែលបានបែកគ្នាកាលពីជំនាន់ប៉ុលពត ។ មុនឆ្នាំ១៩៧០ ក្រុមគ្រួសារខ្ញុំមានទីលំនៅក្នុងទីក្រុងភ្នំពេញម្តុំទួលគោក ។ ឆ្នាំ១៩៧០ ក្រុមគ្រួសាររបស់នាងខ្ញុំផ្លាស់ទីលំនៅមកខេត្តកំពង់ចាម ស្នាក់នៅភូមិមេម៉ាយ ។ ចំណែកបងប្រុសទីមួយធ្វើការនៅភ្នំពេញ ។

ឆ្នាំ១៩៧៥ ប៉ុលពត បានជម្លៀសក្រុមគ្រួសារនាងខ្ញុំទៅនៅស្រុកចំការលើនៅភូមិខ្វាកោណ ជាប់ព្រំប្រទល់ភូមិស្ពោ ។ រស់នៅទីនោះបានរយៈពេលបីខែ ឪពុកម្តាយនិងប្អូនស្រីបានស្លាប់ដោយសារជំងឺគ្រុនចាញ់ ។ ក្រោយមកនាងខ្ញុំបានបែកពីបងប្រុសទីពីរក្នុងពេលជម្លៀសទៅភូមិបន្តទៀត ។

ប្រសិនបើសាមីខ្លួនបានឮ ឬបងប្អូនណាបានស្គាល់ឈ្មោះទាំងពីរខាងលើ សូមផ្តល់ដំណឹងមកនាងខ្ញុំតាមអាសយដ្ឋាននៅភូមិត្នោតជុំ ឃុំសំបួរ ស្រុកទ្រាំង ខេត្តតាកែវ ឬតាមទូរស័ព្ទលេខ ០១២ ៥២៧ ២៣៩ ដោយអនុគ្រោះ ។ សូមអរគុណ ។

## សេចក្តីប្រកាសរកឪពុកម្តាយនិងប្អូនប្រុសពីរនាក់

នាងខ្ញុំឈ្មោះ ចាន់ ធី អាយុ៤៥ឆ្នាំ និង យ៉ា នីន អាយុ៤៦ឆ្នាំ បច្ចុប្បន្នរស់នៅភូមិស្ទឹងសែន ឃុំកំពង់ក្របៅ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ដែលពីមុនរស់នៅភូមិបឹងពៃ ឃុំសាលាវិស័យ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ នាងខ្ញុំសូមសួររក ១)ឪពុកឈ្មោះ សង់ ស៊ីលី ជនជាតិបារាំង ២)ម្តាយឈ្មោះ មុំ ៣)ប្អូនប្រុស ស៊ីណូ និង៤)ប្អូនប្រុស សុង សេត ។ អ្នកទាំងអស់បានបាត់ខ្លួននៅក្នុងពេលរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ។ កាលពីដើមឆ្នាំ១៩៧០ ឪពុកម្តាយនិងប្អូនពីរនាក់របស់នាងខ្ញុំបានទៅនៅទីក្រុងភ្នំពេញ ហើយទុកនាងខ្ញុំទាំងពីរនាក់នៅភូមិសិន ដោយសន្យាថានឹងមកយកនាងខ្ញុំទាំងពីរនៅពេលក្រោយ ។ ប៉ុន្តែជាអកុសលនៅពេលអ្នកទាំងបួនចេញទៅ ខ្មែរក្រហមបានចូលមកគ្រប់គ្រងឃុំសាលាវិស័យនិងចម្ការកោះស៊ូបឹងពៃរ ធ្វើឲ្យគាត់មិនអាចវិលត្រឡប់ចូលភូមិបាន ។ ចាប់តាំងពីពេលនោះមកនាងខ្ញុំទាំងពីរក៏រស់នៅជាមួយមេដោះម្នាក់ឈ្មោះ សាន់ កួយ ដែលជាជនជាតិខ្មែរកាត់វៀតណាម (ស្លាប់នៅឆ្នាំ១៩៨៣) ។

អាស្រ័យហេតុនេះ បើពុកម៉ែនិងប្អូនប្រុសទាំងពីរបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានស្គាល់ សូមទាក់ទងតាមទូរស័ព្ទលេខ ០១១ ៦៩៥ ៩០៥ ឬ ០១១ ៧៦៥ ៩០៤ ដោយសួររកឈ្មោះ ចាន់ ធី និង គង់ សារុន (ប្តី) ឬ ទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬអ៊ីមែលៈ dccam@online.com.kh ។ សូមអរគុណ ។



រូបថតអនុស្សាវរីយ៍កម្មាភិបាលខ្មែរក្រហមនិងកម្មាភិបាលចិន

# តុលាការខ្មែរក្រហម: គឺជាការព្រមានអ្នកជំនាន់ក្រោយ

បច្ចុប្បន្នមានប្រជាពលរដ្ឋខ្មែរប្រមាណ៥០ភាគរយប៉ុណ្ណោះដែលដឹងនិងនៅចាំរឿងរ៉ាវជាប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាពីឆ្នាំ១៩៧៥-៧៩ ។ សួរថាហេតុអ្វីបានជាមានមនុស្សតិចម៉្លេះដែលដឹងរឿងរ៉ាវដ៏ជូរចត់របស់ប្រជាពលរដ្ឋខ្មែរបែបនេះទៅវិញ? មិនពិបាកឆ្លើយនោះទេ បើរាប់ពីពេលប្រទេសកម្ពុជាបានរំដោះផុតពីរបបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៩ នោះអ្នកដែលមានអាយុច្រើនជំនាន់មុនបានស្លាប់ជាបន្តបន្ទាប់មិនតិចទេ ។ ដូច្នេះអ្នកដែលដឹងរឿងពិតប្រាកដនិងអ្នកដែលឆ្លងកាត់របបខ្មែរក្រហមនោះគឺនៅមួយចំនួនតូចប៉ុណ្ណោះ ។ រីឯក្មេងជំនាន់ក្រោយភាគច្រើនមិនជឿថាមានរឿងបែបនេះកើតឡើងទៀតទេ ទោះបីជាក្មេងខ្លះបានស្តាប់ការរៀបរាប់ប្រាប់របស់ជីដូនជីតាឬឪពុកម្តាយបងប្អូនក៏ដោយ ។ ក្មេងខ្លះនិយាយថាចាស់ៗជំនាន់មុនចូលចិត្តភូតភរណាស់អាងតែក្មេងមិនឃើញ ។ ទោះបីជាក្មេងជំនាន់ក្រោយមិនចង់ជឿរឿងខ្មែរក្រហមយ៉ាងណាក្តីក៏ព្រឹត្តិការណ៍ពីអតីតកាលជំនាន់នោះនៅតែជារឿងដែលមិនអាចបដិសេធនិងមិនអាចបំភ្លេចបានសោះឡើយ ។

ឆ្នាំ១៩៧៥ គឺជាឆ្នាំដែលប្រទេសកម្ពុជាត្រូវផ្លាស់ប្តូររបបគ្រប់គ្រងពីរបបសាធារណរដ្ឋខ្មែរដែលដឹកនាំដោយសេនាប្រមុខ លន់ ណុល ទៅជារបបកម្ពុជាប្រជាធិបតេយ្យដែលមាន ប៉ុល ពត ជាអ្នកដឹកនាំវិញ ។ ពេលនោះប្រជាពលរដ្ឋខ្មែរភាគច្រើនមិនបានដឹងអំពីការផ្លាស់ប្តូររបបគ្រប់គ្រងនេះទេ ប៉ុន្តែគ្រាន់តែដឹងថាមុនពេលមានការផ្លាស់ប្តូរបែបនេះ ប្រទេសកម្ពុជាត្រូវទទួលរងនូវសង្គ្រាមពីគ្រប់ផ្នែកទាំងអស់ ទាំងនយោបាយ សេដ្ឋកិច្ច និងការរស់នៅជាពិសេសការរស់នៅរបស់ប្រជាពលរដ្ឋនៅតាមតំបន់ដាច់ស្រយាលដែលរត់គេចពីគ្រាប់រំសេវនិងបោះបង់ចោលផ្ទះសម្បែង ស្រែចម្ការ ។

ចាប់ពីឆ្នាំ១៩៧០-៧៥ ប្រទេសកម្ពុជាស្ថិតនៅក្នុងភាពអាសន្នជានិច្ច រហូតដល់មានការប្រកាសឲ្យដឹកលេណដ្ឋានទៀតផង ។ រដ្ឋាភិបាល លន់ ណុល បានប្រកាសឲ្យប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅស្ម័គ្រចិត្តចូលទៅបម្រើនៅក្នុងជួរកងទ័ព ដើម្បីការពារបូរណភាពដែនដីប្រទេសកម្ពុជាឲ្យចៀសផុតពីសង្គ្រាមពីគ្រប់និន្នាការ ។ ប៉ុន្តែប្រទេសកម្ពុជានៅតែមិនអាចគេចផុតពីសង្គ្រាម ដោយហេតុថាសភាពការណ៍នយោបាយរបស់ប្រទេសកម្ពុជាបានជួបប្រទះភាពចម្រូងចម្រាសនិងស្មុគស្មាញច្រើនពេកតាំងពីអ្នកដឹកនាំជំនាន់មុនមក ។ ក្នុងនាមនាងខ្ញុំដែលសរសេរអត្ថបទនេះ នាងខ្ញុំនៅចងចាំរឿងខ្លះៗរវាងឆ្នាំ១៩៧០មកទល់ឆ្នាំ១៩៧៥ ។

កាលណោះនាងខ្ញុំរៀននៅវិទ្យាល័យក្រុងតាខ្មៅពីឆ្នាំ១៩៧០-៧៤ ប៉ុន្តែការសិក្សារបស់ខ្ញុំពុំសូវបានរៀនជាប់លាប់ទេព្រោះគ្រាប់កាំភ្លើងធំបានបាញ់ផ្លោងស្ទើររាល់ថ្ងៃចូលមកទីក្រុងតាខ្មៅ ជួនកាលបាញ់ចូលមកក្បែរវិទ្យាល័យ ជាហេតុធ្វើឲ្យសិស្សមានការភ័យខ្លាចស្ទើរតែមិនចង់ចេញពីផ្ទះទៅរៀន ។ ទំនិញចេះតែឡើងថ្លៃរហូត រីឯប្រាក់រៀលចេះតែចុះថ្លៃទៅៗ ។ ជីវភាពប្រជាពលរដ្ឋជួបការលំបាកកាន់តែខ្លាំងឡើង ប្រជាពលរដ្ឋដែលរស់នៅទីឆ្ងាយៗបានរត់គេចពីកំណែនទាហានរបស់រដ្ឋាភិបាល លន់ ណុល ។

នៅថ្ងៃ១៧ មេសា ១៩៧៥ សភាពការណ៍ច្របូកច្របល់កើតមានឡើងនៅក្នុងទីក្រុងភ្នំពេញ ។ កងទ័ពខ្មែរក្រហមវាយសម្រុកចូលពេញទីក្រុង ។ កងទ័ពខ្មែរក្រហមបានឃោសនាអំពីជ័យជម្នះរបស់ខ្លួនដោយបញ្ជាក់ថាខ្លួនបានវាយកម្ទេចរបបសេរីនិយមរបស់អាមេរិកាំងហើយ ។ ក្រោយពេលកងទ័ពកាន់កាប់ទីក្រុងភ្នំពេញខ្មែរក្រហមបានបណ្តេញប្រជាពលរដ្ឋឲ្យចាកចេញពីលំនៅឋានរៀងៗខ្លួន ដោយយកលេសថា ចាំអង្គការបោសសម្អាតខ្មាំងអាមេរិកឲ្យអស់សិន ទើបអនុញ្ញាតឲ្យប្រជាពលរដ្ឋចូលមកកាន់ផ្ទះសម្បែងវិញ ។

អ្នកជំងឺនៅតាមមន្ទីរពេទ្យខ្លះត្រូវកងទ័ពខ្មែរក្រហមបាញ់សម្លាប់ចោលនិងខ្លះទៀតត្រូវបង្ខំចិត្តទុកចោលឲ្យស្លាប់ទៅតាមយថាកម្ម ។ ការិយាល័យរបស់មន្ត្រីរាជការធំៗជាច្រើនត្រូវ

ខ្មែរក្រហមដុតបំផ្លាញចោលជាមួយឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ។ ក្រោយពេលខ្មែរក្រហមចូលមកកាន់កាប់ទីក្រុងភ្នំពេញ គ្រាប់កាំភ្លើងបានស្ងប់ស្ងាត់ជាបណ្តើរៗ យើងឮតែសំឡេងយំស្រែករកក្រុមគ្រួសារដែលរត់បែកខ្ញែកគ្នា សំឡេងកង់ម៉ូតូរទេះ រថយន្តដែលកំពុងដឹករបស់របរយកទៅជាប់ខ្លួនពេលចេញដំណើរពីលំនៅឋានរៀងៗខ្លួនទៅកាន់មូលដ្ឋានដែលទ័ពខ្មែរក្រហមបានចង្អុលប្រាប់ ។

គ្រួសាររបស់នាងខ្ញុំដែលរស់នៅក្នុងភូមិគ្រឹះមួយនៅខាងជើងស្ពានថ្មក្រុងតាខ្មៅបានចេញដំណើរឆ្ពោះទៅស្រុកស្អាងខេត្តកណ្តាល ។ ក្រុមគ្រួសាររបស់ខ្ញុំមិនបានគិតទុកថានឹងទៅរស់នៅទីណានោះទេ គឺចេះតែធ្វើដំណើរទៅឲ្យផុតពីមុខកងទ័ពខ្មែរក្រហមតែប៉ុណ្ណោះ ។

ក្រុមគ្រួសារនាងខ្ញុំបានទៅស្នាក់នៅក្នុងភូមិមួយឈ្មោះភូមិព្រែកស្អាយ ។ នាងខ្ញុំក៏មានសាច់ញាតិនៅទីនោះដែរ ប៉ុន្តែដោយសារគាត់ដាច់ការទាក់ទងជាមួយក្រុមគ្រួសារខ្ញុំយូរឆ្នាំពេកម្ល៉ោះហើយគាត់មិនសូវរាក់ទាក់ជាមួយក្រុមគ្រួសារនាងខ្ញុំទេ ។ ឃើញសភាពបែបនេះ ក្រុមគ្រួសាររបស់នាងខ្ញុំបង្ខំចិត្តចាកចេញពីភូមិនោះទៅភូមិភាគពាយ័ព្យតាមការដាក់ទិសរបស់អង្គការខ្មែរក្រហម ។

វេលាថ្ងៃត្រង់នៅថ្ងៃមួយក្នុងឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ខ្ញុំត្រូវជញ្ជូនអីវ៉ាន់ដែលមានជាប់នឹងខ្លួនបន្តិចបន្តួចនោះទៅកាន់ចំណតកប៉ាល់ដែលត្រៀមចាំដឹកប្រជាជន១៧មេសានៅម្តុំផ្សារព្រែកតូច ។ ការធ្វើដំណើរតាមកប៉ាល់ធំៗនោះមិនចេញដំណើរនៅពេលថ្ងៃទេ ព្រោះខ្លាចប្រជាជនចំណាំផ្លូវ ។ លុះដល់ពេលព្រលប់ទើបខ្មែរក្រហមប្រកូកប្រកាសឲ្យប្រជាជនរៀបចំអីវ៉ាន់ចេញដំណើរ ។ គ្រាន់តែមេឃងងឹតភ្លាម កប៉ាល់ធំៗទាំងនោះចាប់ផ្តើមចេញដំណើរពីព្រែកតូចឆ្ពោះទៅប៉ែកខាងជើង ។ គ្មាននរណាម្នាក់ដឹងថាកប៉ាល់នោះឆ្ពោះទៅគោលដៅណាទេ ថែមទាំងមិនដឹងអំពីជោគវាសនាខ្លួនឯងទៀតផង ។ ម្នាក់ៗមានតែបន់ស្រន់ព្រះជាម្ចាស់តែប៉ុណ្ណោះ ។ កប៉ាល់ចេះតែធ្វើដំណើរទាំងយប់រហូតដល់ភ្លឺ ។ ម៉ោង៤រសៀលថ្ងៃបន្ទាប់ កប៉ាល់បានទៅដល់ខេត្តកំពង់ឆ្នាំង ចូលចតនៅមាត់ទន្លេផ្សារក្រោម ។

ក្រុមគ្រួសាររបស់ខ្ញុំត្រូវស្នាក់នៅទីរួមខេត្តកំពង់ឆ្នាំងអស់រយៈពេលប្រហែលមួយសប្តាហ៍ ហើយក៏ត្រូវបន្តបញ្ជូនទៅខេត្តពោធិសាត់ទៀត ។

គ្រាន់តែព្រលប់ភ្លាម កងទ័ពខ្មែរក្រហមយករថយន្តមកតម្រៀបគ្នាជាខ្សែ ដើម្បីដឹកប្រជាជន១៧មេសាទៅខេត្តពោធិសាត់ ។ កាលណោះនាងខ្ញុំនៅក្មេងមិនស្គាល់ថាជាភូមិសាស្ត្រអ្វីទេ គ្រាន់តែដឹងតាមរយៈឪពុកម្តាយនិងឮកងទ័ពខ្មែរក្រហមនិយាយគ្នាតែប៉ុណ្ណោះ ។ ពេលកំពុងធ្វើដំណើរទៅខេត្តពោធិសាត់នាងខ្ញុំឆ្ងល់យ៉ាងខ្លាំង ព្រោះឃើញមនុស្សកំពុងភ្ជួរស្រែនៅក្បែរថ្នល់ជាតិទាំងកណ្តាលយប់ ។ ក្រោយមកទើបខ្ញុំដឹងថាខ្មែរក្រហមលត់ដំមនុស្សឲ្យចេះធ្វើស្រែ ។

ព្រឹកឡើងប្រហែលម៉ោង១០ព្រឹក ខ្មែរក្រហមដេញប្រជាជនឲ្យឡើងរថភ្លើងឆ្ពោះទៅខេត្តបាត់ដំបងទៀត ប៉ុន្តែមិនបានទៅដល់ទីរួមខេត្តទេ គឺនៅត្រឹមស្រុកមោងឫស្សី ហើយក៏ដាក់ចោលនៅទីនោះតែម្តង ។ កងទ័ពខ្មែរក្រហមគ្រាន់តែប្រាប់ថាឲ្យរកកន្លែងស្នាក់នៅមួយយប់សិនទៅ ព្រឹកឡើងអង្គការនឹងដឹកទៅឲ្យរស់នៅតាមភូមិ ។ ម្តាយឪពុករបស់ខ្ញុំព្រួយបារម្ភចំពោះប្អូនៗខ្ញុំណាស់ ព្រោះយើងមិនដែលជួបរឿងបែបនេះ ។ ខ្ញុំចេះតែសួរទៅឪពុកម្តាយថា តើពេលណាទើបយើងបានទៅផ្ទះវិញ? គាត់ទាំងពីរឆ្លើយថា គ្មានសង្ឃឹមទេ យើងគ្មានថ្ងៃត្រឡប់ទៅផ្ទះវិញឡើយ យើងប្រាកដជានៅទីនេះរហូតហើយ ត្រូវចោលឆ្អឹងនៅទីនេះផងក៏មិនដឹង ។ មិនយូរប៉ុន្មានមានប្រជាជនមូលដ្ឋានម្នាក់មកប្រាប់ឲ្យប្រជាជនដែលធ្វើដំណើរតាមរថភ្លើងនោះឲ្យជញ្ជូនលីអីវ៉ាន់ចុះទៅភូមិដែលនៅឆ្ងាយពីផ្លូវរថភ្លើងប្រមាណ១ ឬ២គីឡូម៉ែត្រ ។ គ្រួសារខ្ញុំរស់នៅក្នុងភូមិសាយ ។ នៅក្នុងភូមិនោះគ្មានឃើញផ្ទះឬមនុស្សម្នាអ្វីទាំងអស់ ឃើញតែព្រៃឫស្សីផ្នូរខ្មោចនិងវត្តបាក់បែកមួយនៅដើមភូមិ ។ ពេលនោះភាពអស់សង្ឃឹមបានមកគ្របដណ្តប់លើចិត្តរបស់ខ្ញុំ ។ ក្រុមគ្រួសាររបស់ខ្ញុំនិងប្រជាជនជម្លៀសផ្សេងទៀតត្រូវឆ្ការព្រៃដើម្បីសម្រាកមួយយប់សិន ។ ព្រឹកឡើងទើបយើងនាំគ្នាកាប់ឫស្សី កាប់ស្បូវយកមកធ្វើរោងនៅជាបណ្តោះអាសន្នរង់ចាំទទួលបញ្ជាពីអង្គការ ។ ការរស់នៅក្នុងភូមិនោះ ដំបូងគឺមិនការតឹងតែងទេ ប៉ុន្តែអង្គការប្រមូលយកសម្ភារហូបចុករបស់ប្រជាជនអស់ពីខ្លួនទើបសម្រេច

លែងឲ្យមានការហូបចុកនៅតាមផ្ទះរៀងៗខ្លួនតទៅទៀត គឺត្រូវហូបបាយរួមនៅឯមន្ទីរចាត់ការមួយនៅក្នុងភូមិ ។ យើងមិនត្រឹមតែមិនបានទទួលអាហារគ្រប់គ្រាន់ទេ ថែមទាំងត្រូវបង្ខំឲ្យធ្វើការនៅទីឆ្ងាយៗទៀត ។ យុវវ័យត្រូវបង្ខំឲ្យចូលជាកងយុវជន និងបញ្ជូនទៅធ្វើការតាមការដ្ឋានដាច់ស្រយាលពីភូមិ ។ បងប្អូនប្រុសស្រីរបស់ខ្ញុំប្រាំនាក់ត្រូវកងទ័ពខ្មែរក្រហមបង្ខំឲ្យទៅធ្វើការនៅជិតព្រំដែនខ្មែរ-ថៃរហូតស្លាប់អស់ដោយសារខ្វះចំណីអាហារ និងធ្វើការហួសកម្លាំង ។ ចំណែកឪពុកម្តាយខ្ញុំនិងក្មួយតូចៗត្រូវអង្គការចាត់ឲ្យទៅមើលគោរើសក្អួរស្រូវ ជម្រះស្មៅ និងរកខសដាក់រោងបាយ ។

ពីចុងឆ្នាំ១៩៧៦ដល់ដើមឆ្នាំ១៩៧៧ក្រុមគ្រួសាររបស់នាងខ្ញុំដែលមានសមាជិកជិត២០នាក់បានស្លាប់ជាបន្តបន្ទាប់ដោយសារកង្វះអាហារ ។

ក្រោយពេលក្រុមគ្រួសារនាងខ្ញុំស្លាប់អស់ទៅ នាងខ្ញុំក៏សម្រេចចិត្តសុំផ្ទាក់លើចេញពីភូមិសាយទៅរស់នៅការដ្ឋានផ្សេងទៀត ដូចជាការដ្ឋានឈៀស ការដ្ឋានហប់ ការដ្ឋានភ្នំធិបតី ការដ្ឋានសង្ឃទីញ៉ាន (ជិតព្រំដែនថៃ) និងការដ្ឋានជាច្រើនទៀតដែលនាងខ្ញុំមិនចាំឈ្មោះ ។ ការរស់នៅការដ្ឋានសង្ឃទីញ៉ាន នាងខ្ញុំមានជំងឺជាទម្ងន់រង់ចាំតែថ្ងៃស្លាប់ប៉ុណ្ណោះ ប៉ុន្តែដោយសារអាយុមិនទាន់អស់ខ្ញុំត្រូវបានអ្នកស្រុកដឹកតាមរទេះគោយកទៅដាក់នៅមន្ទីរពេទ្យស្រុកហប់ ។ នៅទីនោះពេទ្យខ្មែរក្រហមបានចាក់ថ្នាំនិងឲ្យថ្នាំគ្រាប់នាងខ្ញុំលេបរហូតដល់បានជាសះស្បើយ ។ ខ្ញុំបានត្រឡប់ទៅកាន់ការដ្ឋានធំវិញដើម្បីធ្វើការងារដកស្ទូងច្រូតកាត់តទៅទៀត ។

ការរស់នៅក្នុងការដ្ឋានជួរមុខមិនមែនងាយស្រួលទេ ។ ដកស្ទូងរួចខ្ញុំត្រូវលើកទំនប់ជីកប្រឡាយទាំងយប់ទាំងថ្ងៃ ។ យប់ខ្លះខ្ញុំមិនបានដេកទល់ភ្លឺ ព្រោះនៅលើដីបូកគ្មានកន្លែងចងអង្រឹង គ្មានដីទំនាបដែលអាចឲ្យដេកស្រួល ម្យ៉ាងទៀតគ្មានក្រណាត់កៅស៊ូសម្រាប់បាំងការពារទឹកភ្លៀង ។ ការរស់នៅរបៀបនេះមិនយូរប៉ុន្មានៗ ម្នាក់ៗត្រូវឈឺយ៉ាងធ្ងន់ធ្ងរ ។ បងប្រុសខ្ញុំម្នាក់បានស្លាប់យ៉ាងអាណោចអាធ័មនៅលើដីបូកមួយនៅក្នុងព្រៃដីសែនជ្រៅ ដោយគ្មានបងប្អូនណាដឹងក្រៅពីនាងខ្ញុំម្នាក់ប៉ុណ្ណោះ ។ ខ្ញុំមិនអស់ចិត្តសោះចំពោះការស្លាប់របស់ក្រុមគ្រួសារខ្ញុំសោះ ព្រោះអ្វីៗទាំងអស់កំពុងមានជីវិតរស់នៅដោយសុខស្រួល គ្រាន់តែមួយប៉ព្រិចភ្នែកសោះ អ្នកទាំងអស់បែរជាមកស្លាប់ដោយគ្មានហេតុផល ។ ខ្ញុំចេះតែនឹកគិតឆ្ងាយទៅៗ ប្រសិនបើគ្មានរបបខ្មែរ



យោធាខ្មែរក្រហមចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ក្រហមទេ ជីវិតមនុស្សជាច្រើនលាននាក់ក៏មិនស្លាប់ដល់ថ្នាក់នេះដែរ ។ អ្វីដែលខ្ញុំចេះគិតតែទៀតនោះគឺនៅត្រង់ថាតើខ្មែរក្រហមសម្លាប់មនុស្សច្រើនសន្ធឹកសន្ធាប់បែបនេះបានប្រយោជន៍អ្វី?

នៅក្នុងឆ្នាំ១៩៧៨ នាងខ្ញុំបានឮដំណឹងខ្លះៗតាមរយៈអ្នកដែលមានវិទ្យុស្តាប់និយាយខ្សឹបគ្នាថាមានកងទ័ពវៀតណាមវាយលុកចូលប្រទេសកម្ពុជា ។ ខ្ញុំចេះតែសម្គាល់រហូតមក ឃើញកងទ័ពខ្មែរក្រហមដើរនៅពេលយប់មានការប្រុងប្រយ័ត្នខ្លាំងណាស់ ។ ចុងឆ្នាំ១៩៧៨ កម្លាំងក្រុមចល័តរបស់នាងខ្ញុំត្រូវទៅកាប់គាស់ដំបូកដើម្បីដឹកដីកប់ស្រូវ អង្ករ ត្រីងៀត អំបិល ។ល។ គ្មាននរណាម្នាក់បានដឹងអំពីគម្រោងការរបស់ថ្នាក់លើខ្មែរក្រហមឡើយ ។ គួរឲ្យអាណោចអាធ័មណាស់ កម្លាំងដែលខ្មែរក្រហមឲ្យទៅដឹកដីកប់ស្រូវអង្ករនោះ ត្រូវអង្គការយកទៅបាញ់ចោលនៅក្នុងព្រៃស្ងាត់ឬនៅលើភ្នំដើម្បីបំបាត់ភ័ស្តុតាង ។ ចំណែកក្រុមចល័តរបស់នាងខ្ញុំមិនបានទទួលភ័ព្វវាសនាអាក្រក់បែបនោះទេ ។

មិនយូរប៉ុន្មានស្រាប់តែឮដំណឹងថាកងទ័ពវៀតណាមបានវាយលុកចូលកាន់កាប់ទីក្រុងភ្នំពេញបានជាស្ថាពរ ធ្វើឲ្យកងទ័ពខ្មែរក្រហមរត់បែកខ្ញែកគ្នាអស់ទៅ ។ នាងខ្ញុំចេះតែធ្វើដំណើរតាមគេតាមឯងកាត់ព្រៃមិនដឹងថាជាព្រៃអ្វីទេ ។ ដើរយូរៗទៅក៏មកដល់ខាងលិចខេត្តពោធិសាត់ បន្ទាប់មកបានមកដល់ខេត្តកំពង់ឆ្នាំង ។

ពេលមកដល់ខេត្តកំពង់ឆ្នាំងវិញ នាងខ្ញុំនៅសល់តែម្នាក់ឯងគត់ ។ បីថ្ងៃក្រោយមក កងទ័ពវៀតណាមយករថយន្តមកដឹកជញ្ជូនប្រជាជនឡើងមកភ្នំពេញ ប៉ុន្តែរថយន្តដែលនាងខ្ញុំជិះមកនោះមិនបានចូលមកដល់ទីក្រុងភ្នំពេញទេ គឺឈប់នៅត្រឹមកំពង់ចម្លងព្រែកក្តាម ។ ខ្ញុំចេះតែដើរផ្សងព្រេងសួរគេឯងហើយក៏បានជួបបងស្រីម្នាក់ដែលធ្លាប់នៅជិតផ្ទះម្តាយមីងខ្ញុំនៅពញាឮ ។ គាត់បានប្រាប់ខ្ញុំថាក្រុមគ្រួសារមាមីងរបស់ខ្ញុំនៅរស់ទេ ។ នាងខ្ញុំក៏បានជួបម្តាយមីងពីរនាក់និងកូនចៅរបស់គាត់ ។

ខ្ញុំបានស្នាក់នៅក្នុងស្រុកពញាឮអស់រយៈពេលជិតមួយឆ្នាំទើបធ្វើដំណើរមកភ្នំពេញនិងបង្ហួសមកមើលផ្ទះកំណើតនៅទីក្រុងតាខ្មៅ ។ នាងខ្ញុំក៏បានជួបបងស្រីបង្កើតម្នាក់ដែលធ្វើដំណើរបែកគ្នាពេលចេញពីព្រៃ និងឪពុកមាម្នាក់ទៀតដែលត្រូវជាប្អូនរបស់ម៉ាក់ព្រមទាំងកូនគាត់ពីរនាក់ ជាមួយនឹងបងប្អូនអ្នកភូមិផងរបងជាមួយជាច្រើនទៀត ។ នាងខ្ញុំត្រូវបានបងប្អូនជួយរកការងារឲ្យធ្វើនៅរោងចក្រតម្បាញមួយ នៅទួលគោក ។

បច្ចុប្បន្ននាងខ្ញុំជាបុគ្គលិកនិពន្ធនៅក្នុងអង្គការសារព័ត៌មានយុត្តិធម៌ ។

ដូច្នេះ រឿងដ៏ស្មុគស្មាញនៅក្នុងរបបខ្មែរក្រហមមិនមែនជារឿងដែលគួរឲ្យអត់ឱនឬបំភ្លេចចោលនោះទេ ។ ថ្វីដ្បិតតែថាជនរងគ្រោះខ្លះបានរួចរស់ជីវិតហើយក៏ដោយ ប៉ុន្តែការឈឺចាប់នៅតែដក់ក្នុងអារម្មណ៍ប្រជាជនខ្មែរជានិច្ច ។

មនុស្សជំនាន់ក្រោយគួរតែរៀនសូត្រឲ្យបានច្បាស់អំពីអតីតកាលរបស់ប្រជាជនខ្មែរ ជាពិសេសសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីចៀសវាងការប្រព្រឹត្តខុសនិងការដឹកនាំប្រទេសឆ្ពោះទៅរកគ្រោះមហន្តរាយទៀត ។ ការកាត់ទោសគឺជាការព្រមានដល់អ្នកជំនាន់ក្រោយ រីឯការលើកលែងទោសគឺជារឿងរបស់អ្នកដែលត្រូវការភាពស្ងប់ស្ងាត់មិនចង់ឲ្យមានការសងសឹកកើតឡើងជាថ្មីតែប៉ុណ្ណោះ ។

ប្រសិនបើរារាំងមិនឲ្យជនរងគ្រោះសង្កត់ធ្ងន់ទៅលើជនដៃដល់ ឬលើកលែងទោសដោយមិនចាំបាច់មានតុលាការកាត់ទោសឲ្យត្រឹមត្រូវ ឬឲ្យបំភ្លេចការឈឺចាប់នោះ វាពុំមែនជាការត្រឹមត្រូវនោះទេ ។

ដូច្នេះសំណងដែលត្រូវសងទៅជនរងគ្រោះនៃរបបខ្មែរក្រហមនោះគឺត្រូវផ្តល់យុត្តិធម៌មួយតាមរយៈតុលាការការកាត់ទោសដ៏សុក្រឹតមួយដែលប្រជាជនកម្ពុជាត្រូវការឲ្យមានដោយខានមិនបាន ។

បច្ចុប្បន្ន ឧក្រិដ្ឋជនខ្មែរក្រហមនិងប្រជាពលរដ្ឋខ្មែរដែលទទឹងពីការកាត់ទោសកំពុងឈរនៅលើចំណុចមួយផ្សេងគ្នាដោយហេតុថាឧក្រិដ្ឋជនសុទ្ធតែជាបេក្ខភាពដែលមានវ័យហួសពីការកាត់ទោស ប៉ុន្តែអ្នករងគ្រោះនៅតែលើកឡើងថាមិនអាចអនុគ្រោះឲ្យបានដដែល ។

ប្រជាជនកម្ពុជាកំពុងតែរង់ចាំមើលជានិច្ចនូវលទ្ធផលនៃការកាត់ទោសមេដឹកនាំខ្មែរជាន់ខ្ពស់ខ្មែរក្រហម ទោះបីជាត្រូវលើកពេលវេលា ពន្យារពេល ឬក៏បង្រួមមកក្នុងរយៈពេលឆាប់ក៏ដោយ ។

**គីម សុផាន់នី**

# ជីវិតក្នុងភាពនឹងថ្កល់

សុខ ហេង
ចុងភៅ

*(បទសម្ភាសន៍ជាមួយកូនស្រីឈ្មោះ ហ៊ួច ហុង អាយុ៥០ឆ្នាំ នៅស្រុកស្អាង ខេត្តកណ្ដាល)*



សុខ ហេង ថតប្រហែលក្នុងឆ្នាំ១៩៦៦

ឪពុកខ្ញុំជាអ្នករកស៊ីតូចតាច គាត់ទិញជ្រូកមកធ្វើម្ហូបការ ។ គាត់ជាមនុស្សទៀងត្រង់និងមិនដែលទាស់ទែងជាមួយអ្នកណាម្នាក់ទេ ។ គាត់មិនត្រឹមតែចេះអក្សរខ្មែរទេ ថែមទាំងចេះនិយាយភាសាផ្សេងទៀតយ៉ាងស្ទាត់ជំនាញដូចជាភាសាចិននិងវៀតណាមជាដើម ។ ខ្ញុំនៅចាំថា កាលខ្ញុំនៅតូចគាត់នាំខ្ញុំទៅញ៉ាំគុយទាវនៅភ្នំពេញ ខ្ញុំឮគាត់និយាយភាសាវៀតណាមជាមួយអ្នករត់តុ ។

ថ្ងៃមួយ ប្រធានភូមិនិងប្រធានឃុំបានហៅឪពុកខ្ញុំឲ្យចូលកងចុងភៅរបស់បដិវត្តន៍ ។ កាលណោះឪពុកខ្ញុំមិនចង់ទៅទេ ប៉ុន្តែបើគាត់មិនព្រមខ្មែរក្រហមពិតជាចោទគាត់ថាក្បត់អង្គការ ។ ដូច្នេះគាត់មានតែទៅតាមអង្គការដោយគ្មានការតវ៉ា ។ ក្រោយពីនោះ ខ្មែរក្រហមបញ្ជូនគាត់ទៅគុកកោះគរនៅក្នុងស្រុកស្អាង ខេត្តកណ្ដាល ។ តាំងពីពេលនោះមកយើងមិនបានទទួលដំណឹងអ្វីពីគាត់ទាល់តែសោះ ។ ខ្មែរក្រហមសម្លាប់ប្រជាជននៅកោះគរស្ទើរតែទាំងអស់ ដោយសារតែអ្នកទាំងនោះមានសម្បុរសនិងរៀនសូត្របានជ្រៅជ្រះ ។

ពេលឪពុកខ្ញុំចេញទៅ ម្ដាយខ្ញុំលួចយំមិនឲ្យអ្នកណាឃើញទេ ។ បើអង្គការដឹងថាគាត់យំ អង្គការនឹងសម្លាប់គាត់ចោលជាមិនខាន ។ ខ្ញុំស្ទើរតែឆ្កួតដោយសារហត់នឿយនឹងការងាររផង នឹកឪពុកផង ខ្ញុំមិនចង់រស់តទៅទៀតទេ ។

ថ្ងៃមួយពេលដែលប្អូនស្រីខ្ញុំឈ្មោះ ទូច កំពុងរែកអាចម៍គោស្រាប់តែអង្គការមកចាប់វាយកទៅ ។ អង្គការចោទវាថា ជាប់ពាក់ព័ន្ធនឹងឪពុកម្ដាយ ។ ដំបូងវាត្រូវបញ្ជូនទៅកោះគរ ក្រោយមកទៀតទៅទួលក្រសាំងដើម្បីរៀនសូត្រ ។ ខ្ញុំដើររកវាគ្រប់ទីកន្លែងតែរកមិនឃើញ ។ ខ្ញុំបានជួបអ្នកភូមិម្នាក់ គាត់ប្រាប់ពីកន្លែងដែលប្អូនស្រីខ្ញុំនៅ ។ គាត់ប្រាប់ខ្ញុំឲ្យប្រយ័ត្នខ្លួន ព្រោះអង្គការក៏រកខ្ញុំដែរ ។ ពេលឮដូច្នោះខ្ញុំលែងសួរនាំអ្វីពីប្អូនស្រីខ្ញុំទៀត ។

កាលជំនាន់បដិវត្តន៍ ខ្ញុំរែកដីនិងលើកទំនប់ ។ កុមារទាំងប្រុសទាំងស្រីជាច្រើននាក់បានស្លាប់ដោយសារដីបាក់សង្កត់ចំណែកអ្នកផ្សេងទៀតស្លាប់ដោយសារភាពអត់ឃ្លាននិងការបង្ខំឲ្យធ្វើការហួសកម្លាំង ។ អ្នកទាំងនោះខូចសុខភាពដោយសារតែធ្វើការមិនឈប់មិនឈរនៅក្នុងទឹកនិងហូបចុកមិនគ្រប់គ្រាន់ ។ យើងធ្វើការរហូតដល់សម័យរំដោះ ។

ដំបូងខ្ញុំស្មានថាឪពុកខ្ញុំស្លាប់នៅកោះគរ តែក្រោយការរំដោះ អ្នកភូមិខ្ញុំនាំគ្នាទៅមើលគុកទួលស្លែង ។ កាលណោះខ្ញុំមិនបានទៅជាមួយអ្នកភូមិខ្ញុំទេ ដោយសារតែខ្ញុំក្ររកតែកង់ជិះគ្មាន ។ អ្នកដែលទៅទួលស្លែងប្រាប់ខ្ញុំថាបានឃើញរូបថតឪពុកខ្ញុំនៅទីនោះ ។ ក្រោយមកខ្ញុំបានទៅលេងវាំងនៅភ្នំពេញ ខ្ញុំគិតថារូបថតឪពុកខ្ញុំពិតជានៅកន្លែងហ្នឹងហើយ ប៉ុន្តែខ្ញុំរកមិនឃើញទាល់តែសោះ ។ ◆◆◆

# អ៊ី ថាល់
# កងភស្តុភារ

*(បទសម្ភាសន៍ជាមួយម្តាយឈ្មោះ សេង សាមិត អាយុ ៧៣ឆ្នាំ និងមិត្តភក្តិឈ្មោះ ញ៉ែម ញៀន អាយុ៥២ឆ្នាំ នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម)*

**សេង សាមិត:** ដោយមានការច្បាំងគ្នានៅភូមិយើងនៅឆ្នាំ១៩៧០ សាលារៀនត្រូវបិទទ្វារ ហើយកូនខ្ញុំបន្តរៀនកាត់ដេរនៅភ្នំពេញ ។ កាលណោះ ថាល់ អាយុ១៨ឆ្នាំ ។


អ៊ី ថាល់

នៅឆ្នាំ១៩៧៣ ខ្ញុំជិះយន្តហោះទៅយក ថាល់ ពីភ្នំពេញមកវិញ ក្រោយមកវាត្រឡប់ទៅទីក្រុងម្តងទៀត ។ ចុងឆ្នាំនេះប្រធានភូមិហៅ ថាល់ ចូលធ្វើបដិវត្តន៍ ។ ថាល់ បានផ្ញើសំបុត្រប្រាប់ខ្ញុំថាចង់ទៅប្រទេសថៃ ។ វាថាមានអ្នកទិញសំបុត្រធ្វើដំណើរឲ្យ ប៉ុន្តែកាលណោះខ្ញុំខ្លាចមិនចង់ឲ្យកូនទៅស្រុកក្រៅទេ ។ ខ្ញុំក៏និមន្តព្រះសង្ឃមួយអង្គឲ្យលោកជួយនាំ ថាល់ ត្រឡប់មកភូមិវិញ ។

ដំបូង ថាល់ ធ្វើស្រែនៅកងចល័ត ។ ថាល់ លែងកាន់កាំភ្លើងហើយកាន់តែចបមួយ ។ ក្រោយមកទៀតអង្គការបញ្ជូនវាទៅធ្វើពេទ្យនិងធ្វើជាងកាត់ដេរ ។ ក្រោយរំដោះអង្គការវាចូលបម្រើទ័ពប្រចាំការនៅភ្នំពេញ ។ ថាល់ ធ្វើការនៅទីនោះទល់ឆ្នាំ១៩៧៦ ទើបត្រូវអង្គការបញ្ជូនមកព្រៃឈរនិងកន្លែងផ្សេងទៀត ។ វាត្រូវគេផ្លាស់តែរហូតហ្នឹង ។


អ៊ី ថាល់

ថាល់ មកលេងផ្ទះញឹកញាប់ដែរ មកម្តងបានមួយម៉ោងឬពីរម៉ោង ។ ថាល់ ប្រាប់ខ្ញុំឲ្យឆាប់ចាយលុយឲ្យអស់ទៅ ព្រោះបន្តិចទៀតយើងឈប់ចាយលុយហើយ ។ ខ្ញុំមិនជឿកូនទើបទុកលុយមិនព្រមចាយ ។

ឆ្នាំ១៩៧៥ ប្តីខ្ញុំបានទៅលេង ថាល់ ហើយប្រាប់ខ្ញុំថាកូនសុខសប្បាយទេ ។ ថាល់ ផ្ញើអំបិល ប្រហុក និងសំឡីកប្បាសហើយប្រាប់ឲ្យចែកគ្នាប្រើ ។ ខ្ញុំលួចកប់អំបិលទុកខ្លះ ព្រោះខ្លាចខ្មែរក្រហមដឹង ។ ឆ្នាំនោះ ថាល់ បានមកលេងផ្ទះដែរ ។ វាមិនបាននិយាយអ្វីច្រើនទេ គ្រាន់តែថានៅភូមិមិនបានយូរទេ ស្ថានការណ៍មិនស្រួលត្រូវតែត្រឡប់ទៅវិញ ។

បងរបស់វាឈ្មោះ ប៊ុន ថុល និងប្អូនឈ្មោះ ណាន់ ថេង ក៏ទៅជាមួយវាដែល ។ ណាន់ ថេង នៅរស់ដល់សព្វថ្ងៃនេះ ។

នៅឆ្នាំ១៩៧៩ ពេលវៀតណាមចូលស្រុក ខ្ញុំឮដំណឹងថា ថាល់ រត់ទៅតាមឡានដែលដឹកសុទ្ធតែម៉ាស៊ីនដេរនិងក្រណាត់ ។ ក្រោយមកនៅឆ្នាំ១៩៨១ អ្នកដឹកប្រឡាយនៅតាមព្រំដែនថៃប្រាប់ខ្ញុំថា បានជួប ថាល់ និងហៅវាត្រឡប់មកស្រុកវិញ តែវានិយាយថា «ខ្ញុំទៅវិញធ្វើអីបើម្តាយឪពុកខ្ញុំបាត់ខ្លួនអស់ហើយនោះ» ។ គ្រូទាយនិយាយថា ថាល់ នៅរស់នៅឡើយទេ ។

**ញ៉ែម ញៀន:** នៅឆ្នាំ១៩៦៨ ខ្ញុំទៅរៀននៅភ្នំពេញ

ប៉ុន្តែដោយសារគ្រួសារខ្ញុំក្រពេក ខ្ញុំបែរទៅរៀនកាត់ដេរ ។ ពេលខ្ញុំត្រឡប់មកផ្ទះវិញនៅដើមឆ្នាំ១៩៧៣ ខ្មែរក្រហមស៊ើបសួរអំពីប្រវត្តិរូបខ្ញុំរាល់ថ្ងៃ ហើយពេលយប់មានឈ្លបលបចូលផ្ទះខ្ញុំដើម្បីយកការណ៍ទៀត ។ ខ្មែរក្រហមសង្ស័យថាខ្ញុំជាអ្នករដ្ឋការ ។ ខ្ញុំស្ថិតនៅក្នុងស្ថានភាពមួយដ៏លំបាក ។ ខ្ញុំមិនចង់ចាកចេញពីគ្រួសារទេ ព្រោះឪពុកម្ដាយខ្ញុំមានកូនតែម្នាក់គត់ ប៉ុន្តែបើខ្ញុំនៅភូមិទៀតខ្មែរក្រហមពិតជាសម្លាប់ខ្ញុំមិនខាន ។ ដូច្នេះខ្ញុំសម្រេចចិត្តទាំងឈឺចាប់គឺចូលសមរភូមិជាមួយខ្មែរក្រហម ។ ខ្ញុំនៅជាមួយខ្មែរក្រហមតាំងពីឆ្នាំ១៩៧៣ រហូតដល់ឆ្នាំ១៩៧៩ ទាល់តែវៀតណាមចូលកម្ពុជា ។

ខ្ញុំកាន់កាំភ្លើងច្បាំងសម្លាប់មនុស្សនៅតាមព្រំដែនវៀតណាម ប៉ុន្តែខ្ញុំនៅតែគោរពព្រះពុទ្ធសាសនា ។ ខ្ញុំដឹងថាអ្វីដែលល្អអ្វីដែលអាក្រក់ ។ ពេលខ្ញុំច្បាំងគ្នា ខ្ញុំតែងតែបួងសួងកុំឲ្យខ្ញុំសម្លាប់អ្នកណាម្នាក់ឲ្យសោះ ព្រោះសង្គ្រាមនោះជាការបង្ហូរឈាមគ្នារវាងខ្មែរនិងខ្មែរគ្នាឯង ។ អង្គការចង់លើកខ្ញុំធ្វើជាប្រធានក្រុម ប៉ុន្តែខ្ញុំបដិសេធ ព្រោះបើខ្ញុំធ្វើប្រធានក្រុម អង្គការពិតជាបញ្ជាឲ្យខ្ញុំសម្លាប់ប្រជាជនខ្មែរជាមិនខាន ។ ខ្ញុំមិនចង់ធ្វើអីចឹងទេ ។ ខ្ញុំគិតតែធ្វើយ៉ាងម៉េចឲ្យរស់ ។ ខ្ញុំសប្បាយចិត្ត ព្រោះខ្ញុំបានរួចជីវិត ។ ◆◆◆

## ញ៉ែម សូផាន
## ពេទ្យទាហាន

*(បទសម្ភាសន៍ជាមួយសាមីខ្លួននៅស្រុកព្រៃឈរ ខេត្តកំពង់ចាម)*

សព្វថ្ងៃនេះខ្ញុំរស់នៅផ្ទះដដែល គឺកន្លែងដែលខ្ញុំកើតកាលពី៤៩ឆ្នាំមុន ។ ក្នុងគ្រួសារខ្ញុំមានបងប្អូនប្រាំនាក់បានចូលរួមបដិវត្តន៍ខ្មែរក្រហម ហើយក្នុងចំណោមនោះមានតែខ្ញុំម្នាក់ទេដែលនៅរស់ ។ បងប្រុសខ្ញុំឈ្មោះ នឿន ចូលធ្វើមុនគេ ។ គាត់បានយកប្អូនស្រីខ្ញុំពីរនាក់ទៅតាមគឺ ថាច់ និង ថុល រួមទាំងខ្ញុំដែរ នៅឆ្នាំ១៩៧៣ ។ កាលណោះគ្មានអ្នកណាបង្ខំឲ្យខ្ញុំចូលរួមទេ ។

ដំបូងខ្ញុំធ្វើការនៅមន្ទីរ តែក្រោយមកខ្ញុំរៀនខាងឆ្មបអស់រយៈពេលបីខែនិងរៀនខាងពេទ្យទាហានអស់រយៈពេលបីខែទៀត ។ នៅពេទ្យខ្ញុំច្រើនតែលាងមុខរបួសឲ្យកងទ័ព ។ អ្នកជំងឺភាគច្រើនជាកងទ័ពខ្មែរក្រហមដែលត្រូវរបួសនៅសមរភូមិមុខ ។



ញ៉ែម សូផាន អាយុ១៥ឆ្នាំ ក្នុងសម្លៀកបំពាក់ជាពេទ្យ ថតនៅឆ្នាំ១៩៧៥

ខ្ញុំព្យាបាលតែអ្នករបួសស្រាលប៉ុណ្ណោះ ។ បើមានអ្នកណាត្រូវរបួសធ្ងន់ យើងបញ្ជូនទៅពេទ្យធំ ។

ខ្ញុំបានយករូបថតនេះពីមិត្តខ្ញុំឈ្មោះ គា និងប្ដីឈ្មោះ តាំង ។ តាំង ជាមេកងពល ។ គាត់បានបញ្ជូនប្រពន្ធទៅពេទ្យដែលខ្ញុំធ្វើការដើម្បីឲ្យនាងសម្រាលកូននៅទីនោះ ។ ក្រោយមកអង្គការបញ្ជូន តាំង និង គា ទៅសហករណ៍អំពិលទាប ។ តាំង បាត់ខ្លួនមុន ទើប គា និងកូនតូចរបស់នាងបាត់ខ្លួនតាមក្រោយ ។

នៅឆ្នាំ១៩៧៥ ខ្ញុំទៅលេង បងនឿន នៅខេត្តសៀមរាបបានបីថ្ងៃ ។ បងនឿន ឲ្យអ្នកនៅកងរបស់គាត់ជូនខ្ញុំទៅ ។ គាត់និយាយថាគាត់ស្ទើរតែចំណាំខ្ញុំមិនបានព្រោះយើងបែកគ្នាយូរពេក ។ គាត់អង្អែលក្បាលខ្ញុំ ហើយថតរូបខ្ញុំនៅមុខផ្ទះរបស់គាត់ ។ ខ្ញុំសប្បាយចិត្តដែរព្រោះពីមុនមកមិនដែលមានរូបថតមើលនឹងគេទេ ។

ឆ្នាំ១៩៧៥ ខ្ញុំចាប់ផ្ដើមធ្វើពេទ្យធ្មេញនៅខេត្តកំពង់ចាម ។



គា មិត្តភក្តិរបស់ ញ៉ែម សូដាន ថតជាមួយប្តីឈ្មោះ គាំង នៅឆ្នាំ១៩៧៥

អង្គការយកគ្រូពេទ្យធ្មេញពីភ្នំពេញនិងកំពង់ធំមកបង្រៀនខ្ញុំបានមួយរយៈខ្លីដែរ ក្រោយមកអ្នកទាំងនោះស្រាប់តែបាត់ខ្លួនអស់។ អ្នកជំងឺដែលខ្ញុំព្យាបាលភាគច្រើនជាអ្នកភូមិ។ អ្នកជំងឺមួយចំនួនឈឺធ្មេញ ខ្លះទៀតចង់ដកធ្មេញនិងដាក់ធ្មេញ។ ឈ្មោះ កែពក លេខាធិការភូមិភាគឧត្តរ បានមកកន្លែងខ្ញុំដើម្បីដាក់ធ្មេញថ្មី។ ខ្ញុំបានចាប់ដៃគាត់ដែរ ប៉ុន្តែពេលមានមេៗឯទៀតមក ខ្ញុំមិនហ៊ានទាំងសម្លឹងចំអ្នកទាំងនោះផង។ ខ្ញុំកាន់ការងារនេះ ទាល់តែក្រុមពេទ្យធ្មេញត្រូវអង្គការរំសាយ។

នឿន ត្រូវចាប់ខ្លួននៅប្រហែលឆ្នាំ១៩៧៧-៧៨។ ខ្មែរក្រហមមិនបានប្រាប់ខ្ញុំពីរឿងនេះទេ គ្រាន់តែប្រាប់ថាបងប្រុសខ្ញុំក្បត់បដិវត្តន៍តែប៉ុណ្ណោះ។ អង្គការហៅខ្ញុំទៅប្រជុំនិយាយពីរឿងចាប់ខ្លួនបងប្រុសខ្ញុំ ក្រោយមកបញ្ជូនខ្ញុំទៅសហករណ៍នៅព្រៃទទឹង។

ក្រោយមកមេកងខ្ញុំប្រាប់ខ្ញុំថា ឈ្មោះខ្ញុំត្រូវផ្ញើឡើងទៅឲ្យឈ្មោះ គូស នៅភូមិភាគបស្ចិម។ បន្ទាប់មក គូស ផ្ញើសំបុត្រទៅខាងស្រុក។ គណៈស្រុកមើលសំបុត្រនោះរួចរក្សាទុក ហើយចាប់ផ្តើមតាមដានខ្ញុំ។ ថ្ងៃមួយមនុស្សម្នាក់ហៅខ្ញុំឡើងឡាន។ ខ្ញុំមិនបានដឹងជាមុនថាអង្គការមានគម្រោងអ្វីទេ ប៉ុន្តែខ្ញុំចេះតែគិតថា ប្រហែលជាអង្គការយកខ្ញុំទៅសម្លាប់ហើយ។ អ្នកនៅក្នុងឡានប្រាប់ខ្ញុំថាយកខ្ញុំទៅធ្វើការងារខាងកសិកម្មវិញ ព្រមទាំងបានឲ្យខោអាវប៉ុន្មានកំផ្លេមកខ្ញុំ។ ខ្ញុំដឹងថាខោអាវអស់នេះប្រាកដជារបស់ប្រជាជនដែលខ្មែរក្រហមបានសម្លាប់រួច។ ប៉ុន្តែបើតាមខ្ញុំស្មានអង្គការមិនសូវជាច្បាស់នឹងប្រវត្តិរូបខ្ញុំទេ ព្រោះអង្គការឲ្យខ្ញុំទៅនៅភូមិខ្ញុំវិញដដែល។

ក្រោយវៀតណាមចូលអ្នកភូមិសម្លាប់ប្រធានភូមិនៅអំឡុងឆ្នាំ១៩៨២-៨៣។ មេភូមិទាំងនោះបានធ្វើបាបប្រជាជនតាំងពីឆ្នាំ១៩៧៥រហូតដល់១៩៧៨ ដូច្នេះអ្នកភូមិក៏សម្លាប់ដើម្បីជាការសងសឹកវិញទៅ។ ខ្ញុំឮសូរថាប៉ុន្មាននាក់នោះត្រូវចងព្យួរឲ្យអ្នកភូមិមើល។ បើអ្នកទាំងនោះល្អជាម៉្លេះសមបានរស់ហើយ ប៉ុន្តែមេភូមិអស់នោះចិត្តអាក្រក់ឃោរឃៅទើបត្រូវអ្នកភូមិសម្លាប់ចោល។ ◆◆◆

## ប៉ែន ផេង
## កម្មកររោងចក្របារី

*(បទសម្ភាសន៍ជាមួយ ប៉ែន ហង្ស អាយុ៤៥ឆ្នាំ ត្រូវជាប្អូនប្រុស នៅស្រុកចម្ការលើ ខេត្តកំពង់ចាម)*

ខ្មែរក្រហមមកយកបងស្រីខ្ញុំកាលគាត់ឈប់រៀនថ្នាក់ទី៩។ ពេលនោះទាហានលន់ណុលនិងទាហានវៀតណាមកំពុងតែច្បាំងគ្នាពេញទំហឹង ហើយយន្តហោះចាប់ផ្តើមទម្លាក់គ្រាប់បែកស្លាប់អស់ប្រជាជនជាច្រើននាក់និងគោក្របីរាប់សិបក្បាល។

បងផេង មិនចង់ទៅទេ ប៉ុន្តែអង្គការនិយាយថាគាត់ចាំបាច់ត្រូវតែទៅ។ ឪពុកម្តាយខ្ញុំយំ ព្រោះមិនចង់ឲ្យកូនទៅចូលរួមបដិវត្តន៍ទេ។ បងផេង ឱបម៉ែពុកហើយយំទាំងអស់គ្នា។

ដំបូងខ្មែរក្រហមយក បងផេង បងប្រុសខ្ញុំឈ្មោះ ដាម និងប្រជាជនជាច្រើននាក់ទៀត ដឹកតាមរទេះសេះឲ្យទៅលើកទំនប់ក្បែរភូមិនេះ។ បន្ទាប់មក បងផេង ទៅធ្វើទាហាន។ ពីរឆ្នាំក្រោយគាត់បានមកលេងផ្ទះម្តង មិនបានប៉ុន្មានម៉ោងផងក៏ត្រឡប់ទៅវិញ។ គាត់បានយកប៉ែលមកជាមួយដែរ ប៉ុន្តែខ្ញុំមិនដឹងថា



ប៉ែន ផេង នៅមន្ទីរស-២១ ថតក្នុងឆ្នាំ១៩៧៦-១៩៧៧

ហេតុម៉េចទេ ។ បងផេង ឱបក្រុមគ្រួសារហើយនិយាយថា យើងបែកគ្នារហូតហើយ ។

បុរសម្នាក់ឈ្មោះ កែក ឥឡូវនេះគាត់ស្លាប់ហើយ បានប្រាប់ខ្ញុំថា បងផេង ទៅភ្នំពេញធ្វើការនៅរោងចក្រមួយដ៏អាថ៌កំបាំង ។ ក្រោយខ្មែរក្រហមដួលរលំខ្ញុំទៅរកគ្រូទាយ ។ គ្រូទាយប្រាប់ថា បងផេង ស្លាប់ហើយ ទើបខ្ញុំមិនទន្ទឹងចាំគាត់ត្រឡប់មកវិញ ។

ឪពុកខ្ញុំស្លាប់នៅឆ្នាំ១៩៧៣ គឺក្រោយពេលបងប្រុសបងស្រីខ្ញុំចាកចេញទៅ ។ គាត់ធ្លាក់ខ្លួនឈឺដោយសារតែនឹកកូនៗ មុនពេលគាត់ស្លាប់គាត់និយាយថា "ខ្ញុំនឹងទៅជួបកូនស្រីខ្ញុំហើយ" ។

អំឡុងបដិវត្តន៍ ខ្ញុំធ្វើពេទ្យដំបូងនៅពេទ្យឃុំ ក្រោយមកទៀតធ្វើជាអ្នកបាញ់ថ្នាំមូស ។ ខ្ញុំដើរបាញ់ថ្នាំតាមភូមិក្បែរៗនោះ ពេលដើរបាញ់សព្វអស់ហើយ ខ្ញុំចាប់ផ្ដើមធ្វើសាដើមឡើងវិញ ។ ពេលល្ងាចខ្ញុំធ្វើស្រែ ។

នៅឆ្នាំ១៩៧៨ ត្រឹមតែមួយខែប៉ុណ្ណោះមុនរបបខ្មែរក្រហមដួលរលំ អង្គការចាត់តាំងឲ្យខ្ញុំរៀបការ ។ ស្អែកឡើងខ្ញុំអង្គុយលើកៅអីនៅក្នុងពិធីរៀបការ គាំងចិត្តថាធ្វើតាមអ្វីដែលអង្គការបញ្ជា ។ ពិធីនោះរៀបការយុវជនយុវនារីសរុប១៦០គូ ។ ខ្ញុំនិងប្រពន្ធខ្ញុំបានសច្ចាថានៅរួមរស់ជាមួយគ្នា និងមានកូនមួយក្នុងពេលមួយឆ្នាំ ។ ខ្មែរក្រហមបានឲ្យខោអាវខ្មៅនិងក្រមាមួយមកយើង ហើយមានរៀបចំម្ហូបអាហារឲ្យហូប ។ ក្រោយបដិវត្តន៍ ខ្ញុំនិងប្រពន្ធខ្ញុំវិលមកផ្ទះវិញ ។ ឥឡូវយើងមានកូន៥នាក់ ។

## សៀង ហាន
## សមាជិកសហករណ៍

*(បទសម្ភាសន៍ជាមួយសាមីខ្លួននៅស្រុកអូររាំងឪ ខេត្តកំពង់ចាម)*

រូបនេះថតប្រហែលជាបួនប្រាំខែមុនរំដោះ ។ កាលណោះនៅតាមផ្លូវអូររាំងឪ មនុស្សម្នាជាច្រើនតម្រៀបគ្នាថត ខ្ញុំក៏ថតនឹងគេដែរទៅ ។ ខ្ញុំចង់ថតមួយសន្លឹកទុកគ្រាន់ឲ្យកូនមើលពេលដែលខ្ញុំស្លាប់ ។ ចំណោមបងប្អូនខ្ញុំទាំង៧នាក់ មានតែ៤នាក់ទេដែលនៅក្នុងរូបថតនេះ ចំណែកប្អូនៗបីនាក់ទៀតស្លាប់អស់ហើយ ។

ពេលខ្មែរក្រហមចូលភូមិខ្ញុំ លុយកាក់ផ្ទះសម្បែងខ្ញុំទាំងអស់ត្រូវដាក់ជារបស់រួមក្នុងសហករណ៍ ។ ក្រោយពីនេះ ខ្ញុំនៅ



រូបឈរកណ្ដាលៈ សៀង ហាន ថតជាមួយកូន យ៉ាត, ញ៉ិ, យ៉យ និងសម្បត្តិ នៅខែកញ្ញា ឆ្នាំ១៩៧៥

សល់តែសំបកផ្ទះនិងសំបកខ្លួនប៉ុណ្ណោះ ។

ខ្ញុំឃើញអង្គការហៅអ្នកភូមិយកទៅសម្លាប់ចោល ។ ពេលដែលអ្នកណាម្នាក់ចេញទៅហើយមិនដែលឃើញអ្នកនោះត្រឡប់មកវិញឡើយ ។ ខ្ញុំមិនដឹងថាអ្នកទាំងនោះខុសអ្វីទេ ប៉ុន្តែឃើញខ្មែរក្រហមចាប់ទម្លាក់ក្នុងអណ្តូងទឹកនៅក្បែរសាលារៀន ។ ខ្ញុំអាណិតប្រជាជនទាំងនោះណាស់ ជាពិសេសម្តាយនិងក្មេងតូចៗដែលខ្មែរក្រហមវាយសម្លាប់នឹងអង្កត់ឈើ ។

កូនៗខ្ញុំឃ្លានខ្លាំងពេកស្រែកយំ ខ្ញុំស្រក់ទឹកភ្នែកខ្លោចចិត្តអាណិតកូន ។ ពេលរំឭករឿងនេះ ចិត្តខ្ញុំពេញទៅដោយទុក្ខព្រួយ ។

## រស់ ផល
## នារីពេទ្យ

*(បទសម្ភាសន៍ជាមួយ ឡុង ឈួន អាយុ៦៥ឆ្នាំ ជាបងថ្លៃ ខេត្តកណ្តាល)*

ផល ស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍នៅឆ្នាំ១៩៧២ ពេលដែលវាមានអាយុ១៧ឆ្នាំ ។ ម្តាយរបស់ ផល យល់ថាបើកូនស្រីបានធ្វើពេទ្យ គាត់មុខជាមានមុខមានមាត់នឹងគេដែរ ។ ខ្ញុំគិតថា ផល មិនដឹងអ្វីច្រើនពីរឿងធ្វើបដិវត្តន៍ទេ វាគ្រាន់តែចង់មានការងារធ្វើតែប៉ុណ្ណោះ ។

អស់ពីធ្វើការនៅពេទ្យភូមិភាគ វាត្រូវផ្លាស់មកភ្នំពេញ ។ ខ្ញុំបានជួបវាដែរក្រោយថ្ងៃខ្មែរក្រហមរំដោះ តែកាលណោះខ្ញុំខ្លាចមិនហ៊ានស្នាក់នៅទីក្រុងទើបខ្ញុំទៅព្រឹករវិលល្ងាច ។ ផលឲ្យរូបនេះមកខ្ញុំ ហើយប្រាប់ថាជារូបថតជាមួយនារីៗនៅក្នុងកងជាមួយគ្នា ។

ខ្ញុំជាប្រជាជនសាមញ្ញមិនដែលចូលបដិវត្តន៍ខ្មែរក្រហមទេ ។ ខ្ញុំភ្ជួររាស់ហូតសឹងតែដាច់ខ្យល់ស្លាប់ទៅហើយ ។ មួយថ្ងៃៗយើងទទួលរបបបបរតែបីវែកប៉ុណ្ណោះ ហើយទាល់តែពាក់កណ្តាលអធ្រាត្រទើបអង្គការអនុញ្ញាតឲ្យដេក ។

យើងមិនបានធ្វើបាបប្រជាជនដែលត្រូវជម្លៀសមកភូមិនេះទេ ។ ក្រោយមកអ្នកខ្លះត្រូវបញ្ជូនទៅបាត់ដំបង និងខ្លះទៅតាមកន្លែងផ្សេងៗទៀត ។ អ្នកដែលមិនបានជម្លៀសចេញត្រូវអង្គការសម្លាប់ចោលនៅក្នុងវត្ត ។ ◆◆◆



រូបឈរខាងឆ្វេងៈ រស់ ផល ថតក្នុងឆ្នាំ១៩៧៨

# សេចក្តីប្រកាសរកបងស្រីឈ្មោះ ហម សុខថា

ខ្ញុំបាទឈ្មោះ ហម សារុនសុខធូវ៉ាន់ ហៅ ឡយ សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិក ។ ឪពុកឈ្មោះ ហម សូវ៉ាន់ ហៅ កុក ម្តាយឈ្មោះ ប៊ិន សារុន ។ សូមប្រកាសសួររកបងស្រី ហម សុខថា ហៅ ពៅ បើគិតមកដល់បច្ចុប្បន្នអាយុប្រហែល៤៥ឆ្នាំ ដែលបានបែកគ្នាកាលពីឆ្នាំ១៩៧៩ នៅខេត្តបាត់ដំបង ។







បើបងស្រីបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានស្គាល់ឈ្មោះនេះ សូមមេត្តាជួយផ្តល់ដំណឹងមកខ្ញុំបាទតាមអាសយដ្ឋានៈ LOY HALM, 464 COMMON WEALTH AVE #65 BOSTON, MA 02215 U.S.A ទូរស័ព្ទលេខ ១(៦១៧) ២៦៧-៧៣៩២ ឬ ១(៦១៧) ២៦៦-៧៥២៨ *Email: Loyofbos@yahoo.com* ។

# សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ធួន ឆាន


សាន ឃិន

នាងខ្ញុំឈ្មោះ សាន ឃិន អាយុ៧០ឆ្នាំ រស់នៅភូមិរកា ឃុំរកាជន្ទឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សូមសួររកកូនប្រុសច្បងឈ្មោះ ធួន ឆាន ហៅ ឃឿន ដែលបានចូលបដិវត្តន៍កាលពីឆ្នាំ១៩៧៣ ហើយបាត់ខ្លួនរហូតបច្ចុប្បន្ន ។ មុនពេលចូលបដិវត្តន៍ ឆាន បួសជាសង្ឃនៅវត្តស្វាយពោធិនៅក្នុងស្រុកកំណើត ។ បន្ទាប់មក ឆាន ធ្វើដំណើរទៅរៀនបន្តនៅវត្តត្នោតឫស្សីស្រុកនៅខេត្តកំពង់ចាម ។ បីឆ្នាំក្រោយ ពេលដែល ឆាន អាយុ២៥ឆ្នាំ គឺនៅឆ្នាំ១៩៧៣ ឆាន បានសឹកពីបួសហើយចូលបម្រើបដិវត្តន៍ដោយមិនប្រាប់ម្តាយឪពុកឲ្យដឹងឡើយ ។ នៅឆ្នាំ១៩៧៩ ស្រី នៅក្នុងភូមិជាមួយគ្នា បានប្រាប់ខ្ញុំថា គាត់បានជួប ឆាន នៅខេត្តកំពង់ឆ្នាំង ហើយបានបបួល ឆាន ត្រឡប់មកផ្ទះវិញ ប៉ុន្តែ ឆាន ប្រកែក ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ គ្រួសារខ្ញុំបានទទួលសំបុត្រមួយពី ឆាន សួររកក្រុមគ្រួសារនៅភូមិកំណើត ប៉ុន្តែពេលនោះយើងទាំងអស់គ្នាមិនបានយកចិត្តទុកដាក់នឹងសំបុត្រនោះប៉ុន្មានទេ ព្រោះរវល់តែខ្វាយខ្វល់នឹងឪពុករបស់ ឆាន ដែលមានជំងឺជាទម្ងន់ ។ ក្រោយពេលធ្វើបុណ្យសពឪពុករបស់ ឆាន រួចមកសំបុត្រនោះក៏បាត់រហូត ហើយខ្ញុំក៏មិនបានទទួលដំណឹងអ្វីពី ឆាន ទៀតដែរ ។

បើកូនបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានដឹងដំណឹងអំពី ធួន ឆាន សូមមេត្តាទាក់ទងនាងខ្ញុំនៅភូមិឃុំខាងលើ ឬទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារ ០២៣ ២១០ ៣៥៨ ឬតាមរយៈប្រអប់សំបុត្រ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកកូនពីរនាក់

ខ្ញុំបាទឈ្មោះ ម៉ែន បូ អាយុ៧៤ឆ្នាំ ជាឪពុក និង អ៊ុយ កាន អាយុ៧៤ឆ្នាំ ជាម្តាយ សព្វថ្ងៃរស់នៅភូមិឈើទាល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ខ្ញុំបាទមានកូនទាំងអស់៧នាក់÷ ១) ម៉ែន ខេង ២) ម៉ែន ខុម ៣) ម៉ែន រុំ ៤) ម៉ែន ឆុំ ៥) ម៉ែន ឆុន ៦) ម៉ែន ឈួន និង ៧) ម៉ែន ឈួយ ។ ខ្ញុំបាទសូមសួររកកូនពីរនាក់ឈ្មោះ ម៉ែន ខេង និង ម៉ែន ខុម ដែលបានបាត់ខ្លួនតាំងពីឆ្នាំ១៩៧៤ ។ នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០០ ខ្ញុំបាទបានឮដំណឹងថាកូនទាំងពីរបានសួររកឈ្មោះខ្ញុំចំនួនពាដង ប៉ុន្តែមិនបានជួប ។

ប្រសិនបើកូនទាំងពីរបានឮ ឬញាតិមិត្តណាបានស្គាល់ឈ្មោះទាំងពីរខាងលើ សូមមេត្តាជួយផ្តល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ។ សូមអរគុណ ។




ដើម្បីខបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ ក្នុងមួយច្បាប់តម្លៃ ៧០០០រៀល